កំរងភូមិសាស្ត្រ និង ប្រវត្តិសាស្ត្រ

# ប្រវត្តិសង្គ្រាម
# នៅអាស៊ីភាគអាគ្នេយ៍

(ពីដើមកំណើតដល់សតវត្សទី ១៨)

សោម-សំអ៊ុន

PB 2009

959

# ប្រវត្តិសង្គ្រាម

នៅ

# អាស៊ីភាគអគ្នេយ៍

00019257

ស្នាដៃ អ្នកនិពន្ធ ជាវែល

ប្រវត្តិសាស្ត្រនៃប្រទេសខ្មែរ - ភ្នំពេញ

បណ្ណាគារ ពន្លឺវិជ្ជា - ១៩៧១

កំរងភូមិសាស្ត្រនិងប្រវត្តិសាស្ត្រ

លេខ ២

# ប្រវត្តិសង្គ្រាម

នៅ

# អាស៊ីភាគអាគ្នេយ៍

(ពីដើមកំណើតដល់សតវត្សទី ១៨)

ដោយ

សោម - សំអ៊ុន

សាស្ត្រាចារ្យ ផ្នែកភូមិវិទ្យា និងប្រវត្តិវិទ្យា

(សិស្សសាលាគរុវិជ្ជាជាន់ខ្ពស់)

បោះពុម្ពលើកទី ១

បណ្ណាគារ ពន្លឺវិជ្ជា

លេខ ៨០៨ វិថីកម្ពុជាក្រោម ភ្នំពេញ

គ.ស. ១៩៧២

# សេចក្តីផ្តើម

បច្ចុប្បន្ននេះ ជនជាតិខ្មែរម្នាក់ៗ ដែលកំពុងស្ថិតនៅក្នុងពិភពលោកមួយដ៏រំជើបរំជួល ស្ថិតនៅក្នុងស្ថានភាពមួយ ដ៏ចង្អៀតចង្អល់ បណ្តាលមកពីការគំរាមកំហែង ពីអ្នកជិតខាង ដែលមានបំណងចង់លេបទឹកដីរបស់ខ្លួន ពីភូមិភាគអាស៊ីភាគអគ្នេយ៍នេះ តែងតែមានជំនឿទៅលើសមត្ថភាព សេចក្តីក្លាហាន ដែលបុព្វបុរស ដូនតារបស់ខ្លួន ធ្លាប់បានបង្ហាញក្នុងអតីតកាលមកស្រាប់ ។ ការយល់ឃើញ មានលក្ខណៈស្រពិចស្រពិលនៅឡើយ អាចជាគ្រោះថ្នាក់មួយសំរាប់ខ្មែរនិងប្រជាជាតិខ្មែរ បើប្រសិនណាមានការពន្យល់ បន្ថែមពីសំណាក់បញ្ញាមិត្ត ។ ដូច្នេះការដឹងអំពីប្រវត្តិសាស្ត្រនៃដែនដី **អាស៊ីភាគអគ្នេយ៍** ប្រកបដោយព្រឹត្តិការណ៍ដ៏រំជើបរំជួល មិនចេះចប់នេះ ត្រូវតែមានជាការចាំបាច់ ដើម្បីបង្កើនសម្បជញ្ញៈជាតិឲ្យបានដល់

គីរីខ្ពស់ ៗ

បើកាលណាគេធ្វើដំណើរពីប្រទេស ឥណ្ឌា ទៅកាន់ ប្រទេស ចិនដីគោក គេនឹងត្រូវឆ្លងកាត់តំបន់មួយ ប្រកប ដោយ ជ្រោយ ឆក ឈូងសមុទ្រ និងកោះជាច្រើនពាន់ រាយប៉ាយ តាំងពីមហាសមុទ្រ ឥណ្ឌា រហូតដល់មហា សមុទ្រ ប៉ាស៊ីហ្វិក ។ គឺដែនដី **អាស៊ីអាគ្នេយ៍** ។ តាមស្ថានភាពភូមិសាស្ត្រ គេអាចចែក ភូមិភាគនេះ ជាពីរ ផ្នែកធំ ២ គឺ ៖

អាស៊ីភាគអាគ្នេយ៍ ដីគោក ដែលមានរាជាណាចក្រ ថៃ លាវ សាធារណរដ្ឋខ្មែរ សាធារណរដ្ឋ វៀត-ណាមខាងត្បូង សាធារណរដ្ឋប្រជាធិបតេយ្យ វៀត-ណាមខាងជើង និងសហភាពភូមា ។

– អាស៊ីភាគអាគ្នេយ៍ ជាកោះ ដែលមានប្រទេស ម៉ាឡេ ស៊ី សាធារណរដ្ឋ សិង្ហបុរី សាធារណរដ្ឋឥណ្ឌូនេស៊ី

និងសាធារណរដ្ឋ ហ្វីលីពីន ។

គឺជាភូមិភាគមួយស្ថិតនៅក្រោម ឥទ្ធិពលនៃដំណើរខ្យល់ មូសុង ដែលមានរដូវពីរ ផ្លាស់ប្តូរជានិច្ច គឺរដូវភ្លៀងពីខែឧសភាដល់ខែតុលា និងរដូវក្តៅពីខែតុលាដល់ខែឧសភា ។ គឺជាភូមិភាគមួយដ៏ធំទូលាយ មានផ្ទៃក្រឡាជាង ៤លាន គ.ម២ និងមានប្រជាជនរស់នៅរហូតដល់ទៅ ៣០០លាន នាក់ ។

មនុស្សនៅ អាស៊ីអាគ្នេយ៍ មានជាតិសាសន៍ប្លែកៗ ជាច្រើន ។ ជាង ២/៣ នៃប្រជាជនច្រើនរស់នៅតាមក្នុងតាមវាលទំនាប និងដីសណ្តសំបូរដោយផលដំណាំ ។ បើមិនគិតទៅតាមការបែងចែកផ្នែករដ្ឋបាល គេអាចចែកប្រភេទមនុស្សជាពីរក្រុមធំៗ គឺ:

- ក្រុម ខ្មែរ-មន-ចាមជ្វា ដែលមានសម្បុរស្បែកពណ៌ត្នោត និងមានភាសាមួយប្រហាក់ប្រហែលគ្នា ហើយ

ដែលទទួលឥទ្ធិពលពីអរិយធម៌ ឥណ្ឌា ។

- ក្រុម យួន ភូមា ថៃ-លាវ ដែលមានសម្បុរស្បែកលឿងជ្រះ ហើយដែលមានភាសា ជំនឿ ចេញពីអរិយធម៌ ចិន ។

ប៉ុន្តែជនជាតិទាំងនេះ មានវប្បធម៌ប្រហែលគ្នាក្រៃណាស់ ក្រៅអំពីអរិយធម៌របស់ខ្លួន ដែលមានតាំងពីសម័យបុរេប្រវត្តិ មានអរិយធម៌ ឥណ្ឌា ចិន អ៊ីស្លាម និងអរិយធម៌ បស្ចិមប្រទេស ទៀតផង ។

ក្រុមមួយៗ ដូចដែលបានរៀបរាប់ ដោយសង្ខេបមកនេះ បង្ហាញឲ្យឃើញនូវវត្តមាននៃមនុស្សក្នុងប្រវត្តិ-សាស្ត្រ ប្រកបដោយភាពរុងរឿង សង្គ្រាមកើតឡើង រវាងជាតិនានាក្នុងតំបន់នេះ និងបណ្ដាលមកពីអន្តរាគមន៍នៃមហាអំណាចពិភពលោក ។ ប៉ុន្តែនៅក្រោយសង្គ្រាមពិភពលោកលើកទី ២ ជនជាតិទាំងនោះ បានរំដោះខ្លួនពី

អាណានិគមនិយមរឹងប៉ឹង ហើយ ដោយបានការតស៊ូប្រយុទ្ធ យ៉ាងសំបើម ៗ រហូតមកដល់ពេលនេះ ព្យុះភ្លើង សង្គ្រាម នេះនៅតែបន្តមក ឆាបឆេះជានិច្ច រវាងអ្នកប្រកាន់ មនោគមវិជ្ជា ខៀវក្រហម ដែលទំនងជានៅតែបន្តទៅមុខ ទៀត គ្មានពេលឈប់ ដរាបណាបញ្ហានយោបាយ សង្គម និងសេដ្ឋកិច្ច នៅដោះស្រាយមិនទាន់បាន ។ រីឯសន្តិភាព ក៏មិនងាយនឹងរកឃើញដែរ ៗ

យើងនឹងលើកយកមកបរិយាយក្នុងពេលនេះ នូវ ចំណុចសំខាន់ ៗ ជាបន្តបន្ទាប់គ្នា ដូចតទៅនេះ :

១- កំណើតវៀតណាម នៅក្នុង រវាងសម័យបុរាណកាល ។

២- សង្គ្រាម ពង្រីកអំណាចនៃជនជាតិ ខ្មែរ-ចាម-វៀត ។

៣- វិបត្តិនៅក្នុង រវាងសម័យបុរាណកាល ដល់សតវត្ស ទី ១៣ ។

៤ សង្គ្រាមរាតទឹកដី នៃពួក អឺរ៉ុប ស្បៀប ព្រះ-ភូមា ។

៥- ចលនា ជាតិនិយម ប្រយុទ្ធនឹងអាណានិគមនិយមអឺរ៉ុប ។

៦- ការលុកលុយ នៃ យោធានិយមជប៉ុន ក្នុងសម័យសង្គ្រាមលោកលើកទី ២ ។

៧- ចលនា រំដោះជាតិពីអាណានិគមនិយមអឺរ៉ុប ។

៨- ការប៉ះទង្គិច រវាង មនោគមវិជ្ជា នៅអាស៊ីអាគ្នេយ៍ ។

# ជំពូកទី១

## កំណើតរដ្ឋនានានៅក្នុងអាស៊ីភាគអគ្នេយ៍

[ សតវត្សទី ១ ដល់ សតវត្សទី ៩ ]

១- អាស៊ីភាគអគ្នេយ៍ ជាផ្លូវខ្វែងនៃឥទ្ធិពលចិន ឥណ្ឌា និងអ៊ីស្លាម - ២- នគរភ្នំចម្ប៉ា និងម៉ាឡាយូ - ៣- អាណាចក្រ ស្រីវិជ័យ - ៤- នគរចិនឡា និងចម្ប៉ា - ៥- រដ្ឋព្យូ និងមន

---

ជាតិមនុស្សដែលគេបានរកឃើញ នៅលើដែនដីអាស៊ីភាគអគ្នេយ៍ មានអាយុតាំងពីសម័យ ប៉ាឡេអូលីទិក ( Paléolithique ) ឬ យុគ ថ្មគ្រើម មកម្ល៉េះ ។ ប៉ុន្តែ ដំណោះប្រជាជនដែលមានចំនួនច្រើន គឺតាំងពីសម័យ នេអូលីទិក ( Néolithique ) ឬ យុគ ថ្មរំលីង ក្នុងរវាង ៣ ឬ ២០០០ ឆ្នាំមុន គ.ស. ។ គឺប្រជាជនអូស្ត្រូ-អាស៊ី ( Austro-asie ) ដែលបានចុះមកជាបន្តបន្ទាប់គ្នា ពីតំបន់

ប្រទេសចិនមកកាន់ដែនដី សណ្ឋិតជិតឆ្នេរសមុទ្រ ។ ក្នុងបណ្ដាជនជាតិទាំងឡាយនៃមហាគ្រួសារ អូស្ត្រូ អាស៊ី នេះ មានតែជនជាតិខ្មែរ ទេដែលបានបង្កបង្កើតជារដ្ឋមុនគេ ហើយបានទទួលស្គាល់ការលូតលាស់ ក្រោមម៉ែ ដាំងគេក្នុងចំណោមរដ្ឋតូចៗ ។ ដែលធ្លាប់បានទទួលឥទ្ធិពល ឥណ្ឌា និង ចិន ដូចគ្នា ។

## ១- អាស៊ីអាគ្នេយ៍ ជាផ្លូវខ្វែងនៃ ឥទ្ធិពល ចិន ឥណ្ឌា និងរ៉ូម៉ាំង

មុនពេលដែល ឥណ្ឌា និង ចិន ចូលមកដល់ ប្រជាជននៅលើអាស៊ីអាគ្នេយ៍ អាចចែកជាក្រុមចំនួន ៧ ក្រុម បើគិតទៅតាមអំបូរភាសា និងតាមភូមិសាស្ត្រ៖

– ក្រុមទី ១ ៖ ពួក ជ្វា នៅទីប្រជុំកោះធាតានៃប្រទេស ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ហ្វីលីពីន

– ក្រុមទី ២ ៖ ពួកមន តាំងនៅក្នុងតំបន់ខាងក្រោមនៃទន្លេ

អ៊ីរ៉ាវ៉ាឌី និងចំណោមខាងក្រោមនៃទន្លេ មេណាម

- ក្រុមទី ៣ : ពួក ខ្មែរ ដែលរស់នៅត្រង់ប្រទេស លាវ
ខាងក្រោម, ប្រទេស ថៃ ភាគខាងកើត,
ប្រទេសកម្ពុជាទាំងមូល និងប្រទេសវៀត
ណាមខាងត្បូងផ្នែកដីសណ្ដ ។

- ក្រុមទី ៤ : ពួក ចាម រស់នៅតាំងពី ប៊ិញ ថ្វាន់
វៀតណាមខាងត្បូង រហូតដល់ ង៉ែ អាន
វៀតណាមខាងជើង ។

- ក្រុមទី ៥ : ពួកយួន តាំងនៅពីង៉ែអាន រហូតដល់វាល
ចំណោមទន្លេក្រហម និងប្រទេសចិនភាគខាង
ត្បូង (កន្តុង) ។

- ក្រុមទី ៦ : ពួក ថៃ តាំងនៅតំបន់ យូណាន់
(ប្រទេសចិនខាងត្បូង) ។

- ក្រុមទី ៧ : ពួក ភូមា ដែលជាប់ពាក់ព័ន្ធជាមួយពួក ទីបេ

ហើយមកតាំងនៅតំបន់ក្នុងនៃប្រទេសភូមា ខាង
កើត ។

នៅក្នុងរវាងសតវត្សទី ៣ និងទី ២ មុន គ.ស ប្រជាជនទាំងនេះធ្លាប់ប្រកាន់នូវអរិយធម៌ដើមរបស់សម័យ ណេអូលីទិក ហើយក្រោយនោះ បានទទួលពីជនជាតិចិនទិស ត្បូង នូវអរិយធម៌ថ្មី ខុសប្លែកពីអរិយធម៌របស់ខ្លួន ។

ប្រហែលជាក្នុងសម័យ [illegible] បានផ្សាយអរិយធម៌របស់ខ្លួន មកលើតំបន់ ទន្លេក្រហម ហើយ ៗ ក្រោយមកក្នុងភូមិ ដុងសឺន (Dang Son) គេបាន ឃើញ កណាយ ជាច្រើន ដែលជាកណ្ដាយចាស់ជាង គេបន្សល់របស់ចិនទៅ ឥណ្ឌូចិន ។ គឺនៅតំបន់នេះហើយ ដែលជនជាតិ យួន ណាំវៀត បានបង្កើតប្រវត្តិសាស្ត្រ មុនគេ ប្រហែលនៅឆ្នាំ ២០៨ មុនគ្រិស្តសករាជ ដោយ យកក្រុង ហ៊ានហ៊ុង ធ្វើជា រាជធានី ។ រដ្ឋនេះហៅថាជា ខេត្តការ:

គឺខេត្ត គាវពឈីវ (Olao chi) និង គីវចន (cuu chan) នៅវៀតណាមខាងជើងសព្វថ្ងៃ ។ រដ្ឋណាំវៀត បាន ធ្វើការតាក់តែងជាមួយតំបន់ សី ឈ្យូន (យូនណាន់) ដែល ជាដែនដីរបស់ជនជាតិ ថៃ ។

ប៉ុន្តែលុះមកដល់រាជវង្ស ហាន (Han) ដែលបានគ្រប់គ្រងប្រទេសចិនពីឆ្នាំ ២០៦ មុន គ.ស. ដល់ គ.ស. ២២០ ប្រទេសចិនបានបើក "ផ្លូវ ភូមា" (១២៥ មុន គ.ស.) និងវាយលុកប្រទេសណាំវៀត (១១១ មុន គ.ស.) ដើម្បីបើកផ្លូវពាណិជ្ជកម្ម ជាមួយបស្ចិមប្រទេស ។ តាំងពីនោះមក ណាំវៀត ស្ថិតនៅក្រោមអាណានិគមនិយម ប្រទេសចិនអស់រយៈ ជិត ១ ពាន់ឆ្នាំ ។

ក្នុងពេលជំណាលគ្នានេះ ប្រទេសហ្វូណនក៏បានជ្រួត-ជ្រាបមកដល់តាស៊ីការគ្រឿងហើយដែរ ។ តាមរឿងពីរ រាមាយណ ដែលជាឧទាហរណ៍ ដាស់តឿនគេបំផុត

ឥណ្ឌា បានមកដល់អាស៊ីអាគ្នេយ៍តាំងពីសតវត្សទី ៦ មុនគ្រិស្តសករាជ ។ ស្តេច អាសោក នៃសន្តតិវង្ស ម៉ូរិយៈ បានបញ្ជូនបេសកជន នាំព្រះពុទ្ធសាសនាមកផ្សាយដល់ដែនដី «សុវណ្ណភូមិ» ក្នុងសតវត្សទី ៣ មុន គ.ស. ទៀតផង ។

នៅដើមសតវត្សទី ១ នៃគ្រិស្តសករាជ ជនជាតិឥណ្ឌា តំបន់ អូរិស្សា ( Orissa ) បានសង់សំពៅសមុទ្រធំៗ ចំណុះដល់ទៅ ៧០០ នាក់ ធ្វើដំណើរគេចចេញពីការកៀក ក្សាតនៃពួក ស៊ីត ( Scyths ) និងពួក គូសាន ( Kushans ) ឬមកធ្វើជំនួញទិញលក់គ្រឿងទេស គ្រឿងក្រអូបពីអាស៊ី-អាគ្នេយ៍ដើម្បីយកទៅលក់នៅបស្ចិមប្រទេស ។

ក្រៅពីប្រទេសចិននិងឥណ្ឌា ប្រជាជនអាស៊ីអាគ្នេយ៍ បានធ្វើការទាក់ទងជាមួយបស្ចិមប្រទេសដែរ ។ គេបានរកឃើញសំណាកជាច្រើន ដូចជាចង្កៀងក្រួន រ៉ូម

នៅពង្សទឹក ( P'ong TuK ) គាត់ខាងក្រោម នៃចង្កៀងប-ណាប់ រូបយ័ន្តនៃស្ដេច អង់តូនីនឡឺពៀ (Antonin le-pieux ) និង ម៉ាកអូរ៉ែល ( Marc Aurèle ) នៅកំពង់ផែអូកែវ ឆ្នេរសមុទ្រខាងលិចវៀតណាមខាងត្បូង សព្វថ្ងៃ ។

ការរីកចំរើន ក្នុងវិស័យសេដ្ឋកិច្ច ចំរុះមកពីប្រទេស ចិន ឥណ្ឌា និង រ៉ូម បានធ្វើឲ្យអាស៊ីអាគ្នេយ៍ចូលទៅក្នុងប្រវត្តិសាស្ត្រមួយថ្មីទៀត ។ កុលសម្ពន្ធសំខាន់ៗ ដូចជា កុលសម្ពន្ធ ឃ្យូន នៅ ដុងសុន កុលសម្ពន្ធ ចាម នៅតំបន់ ហ្វេ និង ញ៉ាត្រាង, កុលសម្ពន្ធ ខ្មែរ នៅតំបន់ ព្រៃកប្បាស អូកែវ, កុលសម្ពន្ធ មន នៅតំបន់ ពុងទឹក និង ថាតុន ( Thaton ) និងកុលសម្ពន្ធ ម៉ាឡាយូ នៅដីសន្ទុះ ក្រា (Isthme de kra) ដែលបានទទួលនូវឥទ្ធិពល វប្បធម៌ថ្មី នេះគឺបានរីកលូតលាស់យ៉ាងឆាប់រហ័សៗ ឈ្មួញឥណ្ឌាជាច្រើន ដែលមកជ្រកកោននៅតំបន់ទាំងនោះ មិនគ្រាន់តែ

ធ្វើវឌ្ឍនាទេ តែះចះទាក់ទង យ៉ាងជិតស្និទ្ធជាមួយអ្នកស្រុក ហើយប្រកាសខ្លួនជាស្ដេច លើតំបន់នោះ រួចបង្កើតជារដ្ឋតូចៗ ឡើងដូចជា អាណាចក្រ វ៉ាំ, អាណាចក្រ ចម្ប៉ា អាណាចក្រ ម៉ាឡាយូ-មន ។ល។

## ២- នគរភ្នំ ចម្ប៉ា និង ម៉ាឡាយូ

នៅដើមគ្រិស្តសករាជ ប្រទេសខ្មែរធ្លាប់បានធ្វើការទាក់ទងជាមួយប្រទេសចាមយ៉ាងជិតស្និទ្ធ, ជាមួយរដ្ឋនៅម៉ាឡាយូជាធម្មតា និងប្រហែលជាមួយរដ្ឋមនដែរ ប៉ុន្តែតែឯកសារពុំសូវគ្រប់គ្រាន់ ។

អាណាចក្រ វ៉ាំ ចិនហៅថា ហ្វូណន ស្ថិតនៅតំបន់កាតខាងក្រោមនៃទន្លេមេគង្គ ។ រដ្ឋនេះបានចាប់បង្កើតឡើងនៅរវាង គស ៥០ ដោយព្រាហ្មណ៍ក្ដិន្ទម្នាក់ នាម " កៅណ្ឌិន្យ ", ឬ ហ៊ុនទៀន ដែលក្សត្រីខ្មែរ នាម លីវយី ឬ សោមា យកធ្វើជាស្វាមីដើម្បីជួយ

រៀបចំប្រទេសឲ្យបានល្អតាស់ទៀង ។ រាជធានីនៃ
អាណាចក្រភ្នំស្ថិតនៅ វ្យាធបុរៈ (បាភ្នំខេត្តព្រៃវែង
សព្វថ្ងៃ) កំពង់ផែ ពោកអង្គរ ស្ថិតនៅឆ្នេរសមុទ្រ
សៀមខាងលិចវៀតណាមខាងត្បូងសព្វថ្ងៃ បញ្ជាក់
ឲ្យឃើញថាអាណាចក្រនេះជារដ្ឋសំខាន់បំផុត ខាងពាណិជ្ជ-
កម្មនៅអាស៊ីអាគ្នេយ៍ ។

រដ្ឋខ្មែរមិនមែនតែត្រឹម ដីសណ្ឋាននៃខេត្តបាភ្នំ
ប៉ុណ្ណោះទេ ។ តាំងពីគ្រិស្តសតវត្សទី ៦ មកម្ល៉េះ
រដ្ឋខ្មែរពីរទៀត បានតាំងនៅភាគកណ្តាលឥណ្ឌូចិន ។
រដ្ឋទី ១ ហៅថា ក្បុរទេស ឬ កម្ពុជទេស គ្រងតំបន់
ខេត្តកំពង់ធំ ព្រះវិហារ ស្ទឹងត្រែង កំពង់ចាម សៀមរាប
ខេត្តសៀមផ្នែកខាងខ្លះ សេរីប្ឫន ដែនខេត្តលាវ តំបន់ ចំប៉ា-
សក្តិ ប៉ាក់សេ សុវណ្ណខេត្ត ដែលមានរាជធានីតាំង
នៅ វរពិតរេរា ឬ វត្តភូ ឬ សំបូរព្រៃគោះ ។ រដ្ឋទី ២

ដែលប្រើពលដាយន្តនិ កាពពកៈ ខេត្ត កំពង់ស្ពឺផង
កន្តាទី ពេញពេលបញ្ចូលរួមគ្នាតាមដំបូង ចង្អុល ទិសដៅ
បក ។

នៅត្រីស្ដុះបកវត្សរ៍ទី ៣ ផែនការនេះ បានរួមជា
អាណាចក្រតែមួយ ហៅថាកណៈក្រ រ៉ូប៊ួ រៀបពិពាក
ដែលមាន ពោធិបេចីក ស្រីរោះ ជាបញ្ហាកដាក់ផង ហើយ
បានទ្រុតគ្រារ៉ង្កជាច្រើនទៀត ដើម្បីយកស្លួយសារពេក
មិនដើម្បីបើកផ្លូវពាណិជ្ជកម្មទៅកាន់ប្រទេសវណ្ណា ពិ-
សេសគឺវត្ថុចុ ១ ទៅតាមដីសង្ខុះ ប្រៀ ។

ផែនការនេះបានបាប់បង់សន្ធិឡើង ក្នុងត្រីស្ដុសត-
វត្សរ៍ទី២ ដោយសារចន្លោះនៃការដឹកនាំផ្ទង់កាត់ ឬការស-
ចភ្ជាប់មួយគ្រា នៃឈ្មួញសំពៅចាន ក្នុងការធ្វើការពី
បម្រុងក្រុងញ្ញោមកកាន់កំពង់ផែ ពោធិអូរៃវ ដោយមិនបាច់
កណ្ដាលព្រែក ប៉ាល្លីសា ។ ផែនការនេះ ១ គឺផ្លូវល្បៀក

សុកា (Langkasuka) និងរដ្ឋ តាក្កោលៈ (Takkola) ។ មិនតែប៉ុណ្ណោះ ហ្វូណនថែមទាំងវាយដណ្ដើមយករដ្ឋមួយទៀតនៅ ពេននសេរីម ដែលចិនហៅថា គិន-លិន (កំពែងមាស) ទៀតផង តែត្រូវសុគតនៅទីនោះ ។

កេរ្តិ៍សម្បត្តិអាណាចក្រភ្នំ បានធ្លាក់ទៅលើអំណាចរបស់ ហ្វាន់ផាន ដែលបានសោយរាជ្យបាន ៣០ ឆ្នាំពី គ.ស. ២២០ ដល់ ២៤៩ ។ ហ្វូណាន បានទាក់ទងយកផ្លូវសារទានផ្លូវទូតជាមួយប្រទេសចិន និងប្រទេសឥណ្ឌា ដោយនៅក្នុង គ.ស. ២៤៣ បានបញ្ជូនទូត ព្រមទាំងស្លូយសារពើភ័ណ្ឌទៅថ្វាយស្ដេចក្រុងចិន "សម័យរាជាណាចក្រទាំង ៣" ។ អធិរាជចិនបានថ្វាយបកវិញនូវទូតពីរនាក់ឈ្មោះ កាំងថៃ និង ចូយីង តែប៉ុន្តែទូតទាំងពីរនាក់នេះមិនបានមកដល់ទេ ព្រោះស្ដេចអង្គ

បានសុគតទៅហើយ តែបានថ្វាយបណ្ដាំទាល់អធិរាជកុំមួយ អង្គទៀតនាម ហ្គានស៊ីយ៉ុន ។

ហ្គានស៊ីយ៉ុន បានបញ្ជូនទូតទៅកាន់ប្រទេសបរណ្ណា វឌ្ឍប៉ុន្ត្រ ស្ដេចទៅតាមផ្លូវខ្មែរគង្គាដែរ ។

ការពាក់ព័ន្ធជិតស្និទ្ធជាងគេគឺរវាង អាណាចក្រភ្នំ និង អាណាចក្រចម្ប៉ា ។ ដើមឡើយប្រទេសចម្ប៉ាពុំមាន ព្រំដែនជាប់ខ្មែរនៅឡើយទេ គ្រាន់តែជាស្រុកតូចៗប៉ុណ្ណោះ ដូចជា:

– ស្រុក អមរាវតី (នគរវត្រូវប៉ូរ) ខេត្ត ក្វាងណាម ។
– ស្រុក វិជ័យ (នគរវិជ័យ) ខេត្ត ប៊ិញឌិញ ។
– ស្រុក កៅឋារៈ (នគរយ៉ាន់បូ) ខេត្ត ខាញ់ហ្វា ។
– បាណ្ឌុរង្គ (នគរវិរបូរប្តុកអូរ) ខេត្ត ហ្វានរ៉ាង ។

លុះមកដល់ឆ្នាំ ១៩២ ទើបមានក្សត្រតាមួយអង្គ ចិនហៅថា គ្រុយលាន បានចេញកាន់តំណែងហើយ

ខេត្តប៉ិច ដែលត្រួតត្រានៅពីមុនៈ ក្រោយរៀបការត្រួត
ត្រើមស្រុកចាមឲ្យមានឯករាជភាពហើយ ។ ស្តេចចាមដែល
ម៉ាច់គេហៅយកជ័យតបតទៀតគឺ ហ្វានស៊ីយុង នេះអាចបង្វារពី
បានបន្តចំប៉ុនប៉ងក្តោបយកខេត្តតាបមានដើម ដែលកំពុង
ត្រួតត្រាដោយពីរក្សត្រខ្មែរ ហ្វាន់ស៊ីយុង ឲ្យមកជួយផង
(គ.ស. ២៧០ ដល់ ២៨០) ។

នៅឆ្នាំ គ.ស. ៣៣៦ ក្សត្រចាមមួយអង្គទៀតឈ្មោះ
ហ្វានវើន បានលើកជ្រើស ព្រុយពោធ ក្រោយមក
ហោយកផ្សរញ្ជូនដល់ គ.ស. ៤២០ ហើយបន្តសង្គ្រាម
មួយចំនួនទៀត ដោយមានប្រើសំពៅជំនួញផង ។
ភទ្រវរ្ម័ន ជាហ្វានវើន បានកសាងកំពង់ពាណិជ្ជព្រៃព្រឹក
ព្រមទាំងបានកសាងប្រាសាទបែបសិល្បៈវិទ្យាល័ក្ខណ៍ នៅ
មីសឺន (My-Son) ជិតក្រុង ហ្វេ (ទួរ៉ាន) ដើម្បីលើក
ដល់ព្រះ សិវលិង្គ ឈ្មោះ "ព្រះភទ្រេស្វរ" ។ សិលា

ហាក់គឺនៅ ត្រាកៀវ (Tra-kieu) ជាភាសាសំស្ក្រឹតមួយ ជាភាសាចាមមួយ បានបង្ហាញនូវឧត្តមភាព ក្នុងការគោរពបដិបត្តិព្រះឥសូរ ។ អ្នកប្រវត្តិចិនបានកត់សំគាល់ថា ប្រទេសចម្ប៉ាជាប្រទេសសំបូរទៅដោយដើមគីប៉ីឈ (Kipel) ភេស សំបកអណ្តើក ខ្យង សំពត់ធ្វើជាលុយក្នុងរបរពាណិជ្ជកម្មផង ។

## ៣ - អាណាចក្រជ្វាស្រីវិជ័យ

នៅក្នុងសម័យសន្តតិវង្ស ថង់ (618-907) នៃមហាប្រទេសចិន ការរកស៊ីខាងជំនួញ ក៏បានបើកឡើងវិញទៅតាម ផ្លូវសូត្រ ក្នុងតំបន់ អាស៊ីកណ្តាល រីឯតំបន់ផែនៅក្នុងសមុទ្រខាងត្បូង ក៏បានបើកទ្វារចំហសំរាប់ពាណិជ្ជកម្ម គ្រឿងទេស (epices) ដែរ ។ កាំតុង ក្នុងសតវត្សទី៨ បានក្លាយជាកំពង់ផែមួយដ៏ធំ មានសំពៅនៃពួកឈ្មួញមកពីគ្រប់ប្រទេស ដោយឆ្លងកាត់តាមច្រក ម៉ាឡាកា

( Détroit de Malacca ) ។ គឺនៅក្រោមលក្ខខណ្ឌទូទៅ ខាងសកម្មភាពពាណិជ្ជកម្ម ជាអន្តរជាតិនេះហើយ ដែល បង្ហាញនូវសន្ទុះដ៏ខ្លាំង នៃអាណាចក្រ ស្រីវិជ័យ ( Criv ijaya ) ។

ទីតាំងនៃអាណាចក្រ ស្រីវិជ័យ ដែលកើតឡើងបន្ទាប់ ពីការចុះដុនដាបនៃអាណាចក្រ ហ្វូណន នោះ ស្ថិតនៅ ក្នុងតំបន់ ប៉ាឡឹមបាង ( palembang ) នាឆ្នេរសមុទ្រខាងត្បូងនៃកោះ ស៊ូម៉ាត្រា ។ ការរីកចំរើននៅតំបន់នេះ បាន ទាក់ទាញ និងពង្រីកសហគមពុទ្ធសាសនាមហាយានឲ្យរីក កាន់តែខ្លាំង ។ អ្នកដំណើរជាតិចិនម្នាក់ឈ្មោះ យីស៊ីង ( YI tsing ) បានទៅដល់តំបន់នោះចំនួន ៣ ដងហើយបាន ពិពណ៌នាអំពីការរៀបចំរៀនសូត្រព្រះពុទ្ធសាសនា យ៉ាង ច្បាស់ ។

គឺដោយធនធានដ៏សំបូរនេះហើយ ដែលបណ្តាលឲ្យ

អាណាចក្រ ស្រីវិជ័យ មានកំលាំងជាមហាអំណាច ក្នុង តំបន់អាស៊ីអាគ្នេយ៍ ។ នៅក្នុងរវាងពាក់ចុង សតវត្សទី ៧ ចៅអធិរាជ ជា ជ័យនាគ ( jayanâca ) បានលើក ការវាយលុកដណ្ដើមយកនគរ ម៉ាឡាយូ ( តំបន់ ចាមប៊ី ) និងភាគខាងលិច នៃកោះ ជ្វា (គួរកត់សំគាល់ថា តំបន់នេះ មានកើតរដ្ឋតាំងពីសតវត្សទី៥ម្ល៉េះ ។ មកដល់ពាក់កណ្ដាល សតវត្សទី ៨ ប្រទេសនេះ កាន់តែរីកធំឡើង ហើយបន្តការ ទាក់ទងនាំផ្ញើទូតជាមួយចិន . ព្រមទាំងបានលើកទ័ពទៅ វាយយកឧបទ្វីបម៉ាឡេ នៅ លីគ័រ ( Ligor ) រហូតដល់ កំទេចទីក្រុងនានានៅប្រទេស ចម្ប៉ា អាណ្ណាមសម្រុកចូលនិង កំទេចក្រុង សម្បូរ តាមផនទខ្មែរគង់ , អាណាចក្រចិន ឡាវផង ។ គឺនៅពេលនោះហើយ ដែលពួកជ្វាបានកសាង ប្រាសាទមួយដ៏ធំឈ្មោះ បូរ៉ូប៊ូឌួ ( Borobudour ) ក្នុង គ.ស. ៧៧២ ដើម្បីរំលឹកព្រះពុទ្ធសាសនាមហាយាន ។

## ៤- នគរចិនឡានិងចម្ប៉ា

នៅពេញមួយសតវត្សទី ៤ អាណាចក្រ ហ្វូណន ទំនងជាមានការវឹកវរ ធ្លាក់ចុះអន់ថយយ៉ាងខ្លាំង ។

ប៉ុន្តែ ហ្វូណន បានលូតលាស់ឡើងមកវិញ នៅក្នុងសតវត្សទី ៥ ដោយមានរាជវង្សមួយថ្មីទៀត យាងពីឥណ្ឌាមកគ្រប់គ្រង ។ មានមហាក្សត្របួនអង្គ បានឡើងសោយរាជ្យបន្តបន្ទាប់គ្នារហូតដល់សតវត្សទី ៦ គឺ កៅណ្ឌិន្យទី២, ស្រេស្ឋវម្ម ឥន្ទ្រវរ្ម័ន (៤៦៤-៤៩៣), កៅណ្ឌិន្យជ័យវរ្ម័ន និង រុទ្រវរ្ម័ន ដែលបានសុគតចុងក្រោយបង្អស់ ក្នុង គ.ស ៥៣៩ ។

រីឯនៅប្រទេសចម្ប៉ា មានរាជវង្សថ្មីសោយរាជ្យនៅឥន្ទ្របុរៈ តាមរយៈយ៉ឹងម៉ាសេ ក្នុងរវាង គស ៦២០ ហើយបានបន្តចំបាំងជាមួយចិន ដើម្បីសុំគ្រប់គ្រងខេត្ត ការវឈើរ ។ តែចិនមិនព្រម ។ យ៉ឹងម៉ាស បានពឹងក្សត្រខ្មែរនាម

ឥន្ទ្រវរ្ម័ន ឲ្យជួយ តែក្សត្រខ្មែរមិនព្រមលើកទ័ពទៅជួយ
ឡើយ ។ ពេលនោះចាមក៏ត្រូវមេទ័ពចិនឈ្មោះ ពាន់ហ្វើ
វាយកំទេចកាត់ផ្តាច់បាន ( ៤៤៦ ) ។ រាជាធិបតេយ្យ
កើតភាពចលាចលពេញផ្ទៃចម្ប៉ា ។ ក្សត្រចាមដែលសោយ
រាជ្យតពី យ៉ាងម៉ាស បានត្រូវស្ដេចជ្រែករាជ្យមួយអង្គនាម-
ក្លុ-ឡុង-ឡៀ ដណ្ដើមយករាជ្យសម្បត្តិ ។ ដើម្បីជួយឧបត្ថម្ភ
ក្សត្រចាម ស្ដេចខ្មែរនាម កៅណ្ឌិន្យជ័យវរ្ម័ន បានបញ្ជូន
ព្រះសង្ឃរក្ខិតនាម នាគសេន ទៅកាន់ប្រទេសចិនដើម្បី
ឲ្យចិនជួយក្នុងរឿងនេះ តែចិនមិនព្រម ។ ប៉ុន្តែលុះ
មកដល់ គ ស ៤៩១ ស្ដេចជ្រែករាជ្យនោះ បានត្រូវពល
ឧត្ដមស្ដេច យ៉ាងម៉ាបេ ធ្វើគត ហើយឡើងសោយរាជ្យ
ប្រទេសចម្ប៉ា រហូតមកដល់ពាក់កណ្ដាលនៃសត្វ-
វត្សទី ៩ ។

លីវបាវិវ បានបះបោរឡើង ។ ប្រកាសឯករាជ្យពីការត្រួតត្រាប្រទេសចិន ។ ពេលនោះស្តេចចាម បានជួយបង្ក្រាបពួកឧទ្ទាមដល់តែបានជ័យជំនះ ។ តែចិនមិនបានសងរឿងនេះ បែរជាលើកទ័ពមកវាយកំទេចប្រទេសចាមវិញ ។ រាជធានី ពិត្រឿវ បានត្រូវសេនាធិបតីចិន នាយ លីវហ្វាង វាយដណ្ដើមបាននៅ គ.ស. ៦០៥ ។

នៅប្រទេសខ្មែរវិញ ក្រោយដែលស្តេច រុទ្រវរ្ម័ន បានសុគតក្នុង គ.ស. ៥៣៩ ការវឹកវរកើតមានឡើងដែរ ។ ភវវរ្ម័ន ត្រូវជាកូនចៅស្តេច រុទ្រវរ្ម័ន ដែលសោយរាជ្យនៅ « កម្ពុជទេស » ជាវង្សខ្មែរទី ២ បានជ្រាបរឿងនេះ ក៏លើកទ័ពមកកាន់រាជធានី អាណាចក្រភ្នំ ( ប្រហែលនៅ ព្រៃក្បាស ) តែនៅក្នុងរាជធានីនោះ មានស្តេចត្រកូលរាជ្យឡើងសោយរាជ្យទៅហើយ បណ្ដាលឲ្យមានការប្រយុទ្ធគ្នាយ៉ាងតឹងតែងបំផុត អស់រយៈពេលជាង ៥០ ឆ្នាំ ។

នៅ គ.ស. ៦១៦ ហើយ ឥសានវរ្ម័ន ដែលគេថា ក្មួយស្តេច ចិត្រសេន ធ្វើអោយសោយរាជលើកម្ពុជាទាំងមូល ដោយបានតាំងរាជធានី នៅ ឥសានបុរ (សំបូរព្រៃគុក ខេត្តកំពង់ធំសព្វថ្ងៃ) ។ ជនចិនហៅថា "ពិនល្បា" គឺបានប្រែប្រួលមួយវិញដោយរួមតាំងរដ្ឋទី ៣ ទៅ ឥន្ទ្របុរៈផង ។

ឥសានវរ្ម័ន បានធ្វើការពង្រីកដែនជាប្រទេសចាមយ៉ាងជិតស្និទ្ធ ដូចជាបងប្អូន ដោយបានរៀបអភិសេករាជបុត្រីនាម ស្រីសិរីវារី ទៅក្សត្រចាមដែលមកគង់នៅចិនឡានាម ជគតិធម្ម ។

ប៉ុន្តែនៅពាក់កណ្តាលសតវត្សទី ៨ មានរាជវង្សថ្មីមួយទៀតបានគ្រប់គ្រងលើប្រទេសចាម ហើយផ្លាស់រាជធានីមកតាំងនៅ វីរបុរ ក្នុងរដ្ឋ បាណ្ឌុរង្គ វិញ ។ ក្នុងពួករាជវង្សថ្មីនេះកើតឡើង ខ្មែរនិងចាមក្លាយទៅជាសត្រូវនឹងគ្នាទៅវិញទៅមកដល់ទៅមានចំបាំងនឹងគ្នាមិនឈប់ឈរ ។

ពេញមួយសតវត្សទី ៨ នេះ អាណាចក្រកម្ពុជា មានការរើករើ ហើយបានបែកបាក់គ្នា រហូតដល់ទៅចែកជាពីរ គឺ កម្ពុជាលើ និង កម្ពុជាក្រោម ។ មូលហេតុនៃការបែកបាក់នេះបណ្តាលមកពីរដ្ឋចំណុះទាំងឡាយ នាំបះបោរប្រកាសឯករាជ្យរៀងខ្លួន ហើយពិសេស គឺមកពីអសន្តិសុខពីខាងក្រៅ ។ ព្រោះនៅក្នុងសតវត្សទី ៨ នេះ អាណាចក្រ ស្រីវិជ័យ ក្នុងកោះ ស៊ូម៉ាត្រា សព្វថ្ងៃ បានរីកលូតលាស់យ៉ាងសម្បើម ដោយរាជវង្ស "សៃលេន្ទ្រា" បានប្រកាសជាស្តេចក្រុងភ្នំ ជាស្តេចចក្រពត្តិ ហើយរកអំណាចរបស់ខ្លួន ពាសពេញអាស៊ីអាគ្នេយ៍ទាំងមូល ព្រមទាំងបានលុកលុយតាំងពីឆ្នេរសមុទ្រចិន ពីពាមទន្លេក្រហមរហូតដល់ទន្លេមេគង្គ ។

## ៥- រដ្ឋព្យសនិខមន

ក្នុងវេនពាក់កណ្តាលសតវត្សទី ៦ ពេលដែល

អាណាចក្រ ហ្វូណន ត្រូវធ្លាក់ចុះអំណាច មានរដ្ឋពីរ ទៀតបានលេចឡើងក្នុងប្រវត្តិសាស្ត្រឥណ្ឌូចិន គឺប្រទេស ព្យូស៊ុ ( pyus ) និងប្រទេស ម៉ន ។

រដ្ឋព្យូស៊ុ តាំងនៅតំបន់ ព្រូម សព្វថ្ងៃមានធ្វើការទាក់ទងជាមួយ ឥណ្ឌា និង ចិន យូរយារមកហើយ ។ គេបានរកឃើញ ព្រះពុទ្ធរូបចំបីអង្គ ជំនាន់រាជវង្សឥណ្ឌា គុប្តៈ ( សតវត្សទី ៥ ) ព្រមទាំងរូបបូជនីយវត្ថុ ធ្វើអំពីប្រាក់និងវិស្ណុ រូបអវលោកិតេស្វរៈ និងពោធិសត្វជំនាន់ក្រោយ អមរាវតី នៅប្រទេសឥណ្ឌាទក្សិណ ( សតវត្សទី ២-ទី៤ ) ។ ការនេះបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាបានហូរចូលមកក្នុងឧបទ្វីបឥណ្ឌូចិនតាមប្រទេសទាំងពីរនេះ ។

ម្យ៉ាងទៀត នៅភាគខាងលើនៃទន្លេអ៊ីរ៉ាវតី បានកើតរដ្ឋ "ណាននចៅ" ដែលកើតឡើងដោយបុព្វបុរសសៀម រាយផណ្ដីមយក ដើម្បីភ្ជាប់ការទាក់ទង ជាមួយ

សម្ពន្ធមិត្តទៅ ប៊ីរ៉េម ។ ប៉ុន្តែក្នុង គ.ស ៧៩១ ប្រទេស ណានចៅ ត្រូវប្រទេសចិនវាយយកផែរ ដើម្បីបើកផ្លូវ មកកាន់សមុទ្រ ។ អាណាចក្រ ព្យូស៍ និងប្រទេសចិន រាជវង្ស ថាំង (T'ang) ក៏បានបង្កើតទាក់ទងទៅវិញទៅមក ទូវ ការរួមមិត្តសម្ពន្ធភាព ពាណិជ្ជកម្ម និងនយោបាយ ។ ប៉ុន្តែនៅដើមសតវត្សទី ៩ ទីក្រុង ព្យូស៍ បានត្រូវដេញជាតិ សៀម ណានចៅ វាយដណ្តើមយកម្តងទៀត បណ្តាល ឲ្យវង្សនេះធ្លាក់ចុះអាប់អោនទៅ ។

ចៀសចេញពីនេះ ពួក មន ដែលធ្លាប់រស់នៅកាត់គ្នា ក្រោមវិធីទន្លេ ប៉េណាម តំបន់ ទ្វារាវតី នោះ ក៏បានពង្រីក អំណាចរហូតដល់ក្រុង ថាតុន (Thaton) តាមទន្លេ ស៊ី តាំង (Sittang) ហើយធ្វើការទាក់ទងប្តូរ វប្បធម៌ជាមួយ ក្រុង នៅតំបន់ តេលិង្គ (Telingana) នៃក្រុង ម៉ាប្រៀលេ គង់ ព្រោះនៅក្រុង ព្រះបថម និង ពុងទឹក គេបានរក

ឃើញសិលាចារឹក នៅ ស្រីទេព (សតវត្សទី ៥-ទី ៦)។ ទីផុដ្ឋរបស់រដ្ឋដំខាន់ក្រុង អមរាវតី នៅ នគរាជ ។ នៅក្នុង គ.ស ៨២៥ រាជធានីថ្មីបាន បង្កើតនៅ ប៉ិគ្យ ហើយធ្វើការទាក់ទងខាងពាណិជ្ជកម្មជាមួយប្រទេសឥណ្ឌា ហេតុដល់ប្រទេស ពែរ្ស (perse) និង អារ៉ាប់ ផង ។

ប៉ុន្តែ មកដល់សតវត្សទី៩ ជាតិ មន បានត្រូវជាតិភូមា ដែលធ្វើដំណើរចុះមកពីខាងជើង រំលុបត្រួតត្រា បណ្តាលឲ្យអាណាចក្រ មន និង ព្យូស ធ្លាក់ចុះ អន់ថយជាមួយគ្នាតែម្តង ។

នៅក្នុងផ្ទៃ អាស៊ីភាគអគ្នេយ៍ ឥទ្ធិពល ឥណ្ឌា មានកំរិតកាន់តែខ្ពស់ ក្នុងចំណោមប្រទេសទាំងឡាយ នៅភាគខាងត្បូងនិងភាគកណ្តាល ។ ពិតមែនតែឥទ្ធិពល ចិន មិនទាន់មានសន្ទុះខ្លាំងក្លាក្តីក៏គេអាចសំគាល់ឃើញជាលើកទី១ ហើយ ដែលមានវត្តមាននៃអំណាច ចិន មកលើភូមិភាគ

យួនអស់រយៈពេលជាង១ពាន់ឆ្នាំ ។ គឺដំណើរស្រុតចុះមកខាងត្បូងនៃជនជាតិ ថៃ នេះហើយ ដែលញុាំងឲ្យជនជាតិកាត់កិបនានាមាន ភូមា ថៃ លាវ និង យួន រំដោះខ្លួនជ្រៀតចូលមកក្នុងអាស៊ីភាគអាគ្នេយ៍ភាគកណ្តាលសន្សឹមៗដែរ ។

ដើម្បីទប់ទល់នឹងដំណើរនេះ រដ្ឋទាំងឡាយក្នុងអំបូរ ខ្មែរ មន ចាម ជ្វា ចាំបាច់ប្រមូលកំលាំងគ្នា យ៉ាងជិតស្និទ្ធឡើងវិញ ក្រោយពេលដែលមានការបែកបាក់គ្នាអស់រយៈពេលជាច្រើនឆ្នាំខាងក្រោយនេះ ។

## ជំពូកទី ២

# សង្គ្រាមពង្រីកអំណាច
# នៃជនជាតិខ្មែរ-ចាម-យួន-ភូមា

[ ពីសតវត្សទី ៩ ដល់សតវត្សទី ១២ ]

---

៦.ខ្មែររំដោះខ្លួនពីជ្វា ហើយកសាងឯកភាពឡើងវិញ ។ ៧.ការវិវាទព្រំដែនរវាងខ្មែរ ចាម ។ ៨.ជាតិយួនរំដោះខ្លួនពីចិន ហើយវាយដណ្ដើមទឹកដីចាម ។ ៩.ចំបាំងរវាងខ្មែរចាម-យួន ។ ១០.ការបះបោរនៃពួកមន និងសៀម ។ ១១-ភូមាលេបយកដីមន ។ ១២-សុំចុះនៃកោះជ្វា ។

---

ចាប់តាំងពីសតវត្សទី៩ ទៅ ដែនដីអាស៊ីភាគអាគ្នេយ៍ទាំងមូល ស្ថិតនៅក្នុងសំទុះមួយដ៏គ្រោះគ្រាប់បណ្ដាល មកពីមហាអាណាចក្រ ខ្មែរ មហានគរ និងអាណាចក្រ ចំប៉ា ។ ប៉ុន្តែរដ្ឋទាំងនេះបានក្ដាប់ការរីកចំរើនផ្សេង

បណ្តាលមកពីចិនទាស់ នាំឲ្យសង្គមអរិយធម៌ ព្រោះទៅ ចំពោះផ្ទុយពីលំអរិយធម៌ "**មិនប៉ុងពោល**" តាមរយៈ ជនជាតិ **ភូមា យួន សៀម** ។

## ៦- ខ្មែររំដោះខ្លួនពីជ្វា ហើយកសាងឯកភាពឡើងវិញ

ពេញមួយសតវត្សទី ៨ ប្រទេសកម្ពុជា បានឆ្លងកាត់នូវអសន្តិសុខ បែកបាក់គ្នាជារដ្ឋតូចៗជាច្រើន បណ្តាលមកពីវិបត្តិក្នុងប្រទេស និងមកពីក្រៅប្រទេស ពិសេសបណ្តាលមកពីការលុកលុយនៃពួកជ្វាកវង្ស **សៃលេន្ទ្រា** (៧៧៧) ព្រមទាំងចាប់យកពូជវង្សក្សត្រស្តេចខ្មែរ ទៅស្រុកជ្វាផង ។

នៅពេល គ.ស ៨០០ **ជ័យវរ្ម័នទី ២** ដែលត្រូវស្តេចជ្វាចាប់យកទៅនោះ បានត្រឡប់មកកាន់មាតុភូមិវិញ ។ មុនដំបូង មានការរៀបចំប្រទេសដោយយកក្រុង

ឥន្ទ្របុរ (តំបន់បន្ទាយព្រៃនគរស្រុកត្បូងឃ្មុំកំពង់ចាមសព្វថ្ងៃ) មកធ្វើជារាជធានី ។ ពេលនោះប្រជានុរាស្ត្រ នៃរាជវង្ស សៃលេន្ទ្រា បានធ្លាក់ចុះអន់ថយ គឺជាឱកាសមួយដ៏ប្រសើរ ដែលខ្មែរត្រូវដោះខ្លួនឲ្យផុតអំពីការត្រួតត្រារបស់ជ្វា ។ ដើម្បីសំរេចនូវគោលបំណងនេះ ជ័យវរ្ម័នទី២ បានលើករាជធានីទៅតាំងនៅ កុដិ (តំបន់បន្ទាយឆ្មា ទៅទីទួល លំពៃ ជាទីដែលខ្មែរបានប្រតិស្ឋានទីក្រុងថាហៅជា ហរិហរាល័យ ក្រោយពីបានតែងតាំង ព្រាហ្មណ៍ម្នាក់នាម សិវកៃវល្យ ឲ្យត្រួតត្រានៅ ឥន្ទ្របុរ ។

ប៉ុន្តែក្រោយមក មានផ្លាស់រាជធានីទៅតាំងនៅ អមរេន្ទ្របុរ (ត្រង់ខាងលិចបារាយណ៍ទឹកថ្លា) និងទៅ មហេន្ទ្របព៌ត គឺភ្នំគូលែន ។ នៅពេលនោះហើយ ដែល ជ័យវរ្ម័នទី ២ បានឡើងរាជាភិសេកជាស្តេចចក្រពត្តិ ដោយរៀបចំពិធីមួយ ហៅថាពិធី ទេវរាជ ដើម្បីប្រកាស

ជាស្តេច សោរ៉ាលៃ ប៉េរផ្លេវៀរ ។ ទៅក្នុងប្រទេសកម្ពុជាទាំងមូល ។ ការផ្លាស់ប្តូររាជធានីយ៉ាងញាប់ហើសនេះ ព្រោះមានគោលបំណងមិនបង្រួបបង្រួមប្រទេស ឲ្យមានឯកភាពឡើងវិញ ។ បញ្ហាឯកភាពប្រទេសនេះ បានព្រះឥន្ទ្រវរ្ម័នទី ១ (៨៧៧-៨៩) អនុវត្តបន្តទៅទៀត ដកប់ពាល់តែប្រទេសកម្ពុជារួបរួមគ្រប់តែមួយ ដូចជាខាងមុខ ។ ក្រោយមកទៀត រាជធានីខ្មែរបានផ្លាស់មកតាំងនៅ យសោធរបុរ ក្នុងរជ្ជកាល យសោវរ្ម័នទី ១ (៨៨៩-៩០០) ។

## ៧ ការវិវាទតាមព្រំដែន រវាងខ្មែរ ចាម

តាំងពីដើមសតវត្សទី ៩ ប្រទេសកម្ពុជា ទើបតែបានបានសុខសាន្តឡើងវិញបន្តិចនោះ ស្រាប់តែស្តេចចាមនាម ហរិវរ្ម័ន ធ្វើកលឧបាយឲ្យសេនាបតីចាមម្នាក់ ឈ្មោះ ប៉ារ លើកទ័ពចូលមកប្លន់ទ្រព្យសម្បត្តិខ្មែរ នៅផ្នែកខាង

ក្បួនប្រទេសរបស់ជាច្រើន ។ បន្ទាប់ពី ប៉ារិន យកទ្រព្យ
សម្បត្តិតាំងពីបុរាណមាននោះ ទៅកសាងបានជាប្រាសាទថ្មី
នៅតំបន់ ហ្វាងរ៉ាង ហើយថែមទាំងបែរទឹកដី ស្រុកសរ
និងពល សំរាប់ថែការក្សាប្រាសាទទាំងនោះទៀតផង ។

នៅឆ្នាំ គ.ស. ៨៧៥ ស្ដេចចាមដែលគង់នៅក្រុង
វីរបុរ ក្នុងខេត្ត បាណ្ឌុរង្គ បានចេញទៅតាំងនៅក្រុង
ឥន្ទ្របុរ ( ក្បែរក្រុងហ្វេ ) វិញ ដោយជាបណ្ដាលមកពីការ
លុកលុយពីពួកជ្វាទៀត ។ នៅពេលនោះប្រទេសចម្ប៉ា
មានឈ្មោះតាមឯកសារចិនថា ឆេងចេង វិញ ។

ដើម្បីសងសឹកនឹងពួកចាម ដែលបានចូលមកលុក-
លុយកាលពីសម័យមុន ក្នុងឆ្នាំ ៩៤៥ ស្ដេច រាជេន្ទ្រ-
វរ្ម័នទី ២ ( ៩៤៤-៩៦៨ ) ដែលទើបតែត្រឡប់ពីរាជធានី
កោះកែរ មកតាំងនៅក្រុង អង្គរ វិញនោះ បានបញ្ជូនឲ្យ
ទ័ពខ្មែរចូលទៅកំទេចអាណាចក្រចាម ។ លុះទៅដល់

ខេត្ត កៅធារ (ញ៉ាត្រាង សព្វថ្ងៃ) ទ័ពខ្មែរបានលុកលុយទៅ ដល់ប្រាសាទ **ពោនគរ** ហើយកំទេចយកគ្រឿងរូបតារ ដែលស្តេចចាម **ឥន្ទ្រវរ្ម័នទី ៣** បានកសាងឡើងតាំង ពី គ.ស. ៩១៨ ។ ចំពោះខ្មែរមិនបាននៅក្នុងចម្បាំងយូរទេ ត្រូវដកថយចូលមកក្នុងប្រទេសវិញ តែត្រូវខូចខាតជីវិតពលទាហានជាច្រើន ដោយសារពួកចាម្បាតាម ។

ជំលោះរវាងចាមនិងខ្មែរនេះ គេសង្កេតភាពមិនឃើញឡើយ ថ្វីត្បិតប្រទេសចាមបានល្បងចង់មកតតាំងនឹងខ្មែរ ដើម្បីកៀរឱកាសនោះ ទៅទប់ទល់នឹងការលុកលុយរបស់ជាតិយួនមកពីខាងជើង យ៉ាងណាក៏ដោយ ។

## ៨ ជាតិយួនរំដោះខ្លួនពីចិន ហើយចាប់ផ្តើមគិតដីចាម

មកដល់ពាក់កណ្តាល សតវត្សទី ១០ ប្រទេស **ណាំវៀត** បានស្ថិតនៅក្រោមអាណាចក្រចិន អស់រយៈ

ពេលជាង ១០ សតវត្ស ។

នៅពេលដែល រាជវង្ស ថាំង ( T'ang ) នាប្រទេសចិនកំពុងធ្លាក់ចុះអំណាចដោយការរើករាយ៉ាងខ្លាំង ប្រទេសយួនក៏បានបះបោរដេញអ្នកត្រួតត្រាចិន ពីតំបន់ គាវឈីវ ថាញ់ហ្វា ង៉េអាន ក្រោមការដឹកនាំ របស់ "ង៉ោក្វៀង" ( Ngo Quyền ) ។ រដ្ឋវៀតណាមក៏បានឯករាជ្យ (៩៣៩) មានរូបរាងជារដ្ឋមួយថ្មីនៅ អាស៊ីភាគអាគ្នេយ៍ ។

ក្រោយដែល ង៉ោក្វៀង សុគតទៅ ប្រទេសវៀតណាមបានជួបប្រទះនឹងវិបត្តិជាច្រើន បណ្ដាលឲ្យមានការបែកបែកប្រទេសជាខេត្តត្រាញ់ចំនួន ១២ ។ ប៉ុន្តែនៅក្នុង គ.ស. ៩៧៩ ឡេហ្វាន ( Lê Hoan ) បានបង្រួបបង្រួមប្រទេសឡើងវិញ ដើម្បីទប់ទល់នឹងការកេតក្បាតនៃរាជវង្ស ស៊ុង ( Song ) ដែលទើបតែឡើងកាន់អំណាចក្នុងប្រទេសចិន ត្រាតែបានជួយជំនះ ។

ចាប់តាំងពីពេលនោះ ជនជាតិយួនបានបង្ហាញនូវសមត្ថភាពក្លាហានអង់អាចរបស់ខ្លួនទៅឥណ្ឌូចិន ។ ដូច្នេះ ដើម្បីរកតំបន់ដីឲ្យធំទូលាយ ជាតិនេះបានអនុវត្តនយោបាយឈ្លានពានទឹកដីប្រទេសជិតខាង ។ យួនបើកទ័ពចូលទៅវាយទីក្រុង ពន្ទ្របូរ នៃប្រទេសចម្ប៉ា ។ ជាតិចាមមិនអាចទប់ទល់បាន ក៏ផ្លាស់រាជធានី មកតាំងនៅក្រុង វិជ័យ ក្នុងខេត្ត ប៊ិញឌិញ ។ ដើម្បីរក្សាសន្តិភាពជូនប្រជាជន មហាក្សត្រចាមបានយល់ព្រមនៅចំណុះយួន ។ ប៉ុន្តែជាតិយួននេះ មិនលះបង់គោលបំណងរបស់ខ្លួនសោះ ដូច្នេះហើយបានជានៅចុងសតវត្សទី ១០ ឧបរាជយួនឈ្មោះ ហ្វាត់ម៉ា បានលើកទ័ពជើងទឹក ចូលទៅកំទេចរាជធានី វិជ័យ ហើយចាប់យកព្រះរាជវង្សានុវង្សរាប់ទៅព្រោសនៅប្រទេសយួន ។

ចាប់តាំងពីគ្រិស្តសករាជ ១០០៩ ដល់ គ.ស.

១២២៥ ប្រទេសវៀតណាម បានត្រូវរាជវង្សថ្មីឈ្មោះ លី (ly) គ្រប់គ្រង ។ គឺជាសម័យមួយប្រកបដោយសន្តិភាពខាងនយោបាយនិងសេដ្ឋកិច្ច ។ រាជធានីថ្មីគឺ ថាញ់ឡុង (ហាណូយ) ។ ប្រទេសវៀតណាម ចែកជា ២៤ ខេត្ត មានផ្លូវគមនាគមន៍ភ្ជាប់ខ្វែង និងកិច្ចការពារស្រុកយ៉ាងហ្មត់ចត់រឹងប៉ឹងបំផុត ។ វណ្ណៈអភិជនខាងវប្បធម៌ ជំនឿព្រះសាសនា បែបមហាយាន បានជ្រួតជ្រាប ក្នុងសន្តានចិត្តប្រជារាស្ត្រយួន ។ នៅ គ.ស. ១០៤៤ គេបានកសាងព្រះវិហារមួយដ៏ល្បីល្បាញ ឈ្មោះ Chùa Một- Cột ។ ស្តេច លីថាញ់តុង (Ly Thanh Tong) បានឲ្យឈ្មោះប្រទេសយួនថ្មីនេះថា « ដាយវៀត Đai.viet »

រាជវង្ស លី បានប្រកាន់យកនយោបាយរុករានលើទឹកដីចម្ប៉ាបន្តទៀត ហើយបង្ខំឲ្យប្រទេសនេះប្រគល់ខេត្តផ្សេងៗនៅភាគខាងជើង មកឲ្យយួន ។ ដូច្នេះហើយ

បានជានៅ គ.ស ១០៦៩ លិថាញ់ពុង បានលើកទ័ពដើរទឹក ចូលមកកោះគ្រក់ គីញីន ( Kul Ngon ) រហូតដល់ក្រុង វិជ័យ ។ រុទ្រវរ្ម័នទី ៣ ជាមហាក្សត្រចាមបានយល់ព្រមប្រគល់ឲ្យយួន នូវខេត្ត បីគឺ ង៉ែអាន ក្វាងប៊ិញ និង ក្វាងទ្រី ។ ក្នុងរវាង គ.ស. ១០៧៤ ប្រទេសចាមបានវាយដណ្តើមមកវិញ តែមិនបានសំរេច ។

ចំពោះមុខអំពើឈ្លានពាននេះ ប្រទេសចិនព្រមជាមួយសម្ព័ន្ធមិត្តខ្មែរ (ពេល ហសវរ្ម័នទី ៣) បានតាមវាយផ្គប់ប្រទេសយួនទាំងសងខាង ប៉ុន្តែត្រូវកងទ័ពយួនវាយរុញច្រានទៅវិញ ប្រកបដោយជោគជ័យ ។

យើងឃើញថា នៅក្នុងសតវត្សទី ១២ នេះ ប្រទេសវៀតណាមបានស្គាល់នូវវឌ្ឍនភាព សន្តិភាពដល់កំពូល ។ ការកសាងកសិកម្ម មានការជីកប្រឡាយ សង់ទំនប់ការពារទឹកជំនន់ ពាណិជ្ជកម្មក្រៅប្រទេសជា

ជួយប្រទេសចិន បានជំរុញឲ្យប្រទេសវៀតណាម កសាងអនាគតដ៏ខ្លាំ[illegible] [illegible] លីអាញ់តុង (១១៣៧-១១៧៥) ។

ប៉ុន្តែ លុះមកដល់ដើមសតវត្សទី ១៣ មហាក្សត្ររាជវង្សលី ក្រោយៗ ដែលសោយរាជ្យតមកទៀត ព្រះ-ងើយកន្តើយនឹងកិច្ចការរដ្ឋ ចូលចិត្តសប្បាយ បង្កើនពន្ធដារច្រើនៗ ។ ការបះបោរនៃប្រជារាស្ត្រ ក៏កើតមានឡើង រហូតដល់រាជវង្សថ្មីនាម ត្រាន ( Trân ). ដណ្តើមគ្រប់គ្រងលើប្រទេសយួនទាំងមូល ។

## ៩- ចំបាំងរវាង ខ្មែរ-ចាម-យួន

ប្រទេសចម្ប៉ា ថ្វីត្បិតតែបានទទួលការលុកលុយពីប្រទេសយួនយ៉ាងណាក៏ដោយ ក៏នៅមានកំលាំងពល អាចច្បាំងនឹងប្រទេសកម្ពុជាបាន ។

ដូច្នេះហើយបានជានៅដើមសតវត្សទី ១២ នោះ

ស្តេចចាមនាម ហរិវរ្ម័នទី ៤ បានចាត់សេនាធិបតី ម្នាក់ឈ្មោះ "បាំង" ឲ្យចូលមកវាយកំទេចក្រុង សម្បូរ ហើយគៀរយកឈ្លើយខ្មែរទៅបូជា ចំពោះព្រះឥសូរក្នុងប្រាសាទមួយឈ្មោះ ស្រីសានភទ្រេស្វរ ។

ម្យ៉ាងទៀត ផ្ទៀតឱកាសក្នុងពេលវេរនៅដើមព្រឹត្តិកាលស្តេច សុរិយាវរ្ម័នទី ២ ( ១១១៣-៥០ ) ពួកចាមបានចូលទៅប្លន់បំផ្លាញស្រុកភូមិខ្មែរ នៅតាមឆ្នេរសមុទ្រនិងដណ្តើមយកបាននូវគ្រឿងមានដំឡៃ ក្នុងបូជនិយដ្ឋាន ហើយគៀរយកខ្មែរជាឈ្លើយទៅស្រុកចាមជាច្រើនផង ។ បុព្វហេតុដែលបណ្តាលឲ្យចំបាំងមួយផ្ទុះឡើងឥតឈប់ឈរ រវាងប្រទេសចាមនិងប្រទេសកម្ពុជានោះ មកពីក្នុងការធ្វើសង្គ្រាមជាមួយយួន "ដាយវៀត" ប្រទេសខ្មែរតែងពឹងពាក់លើប្រជារាស្ត្រចាម និងគេចាមជាទីសំណាក់និងជាជំនួយ ។ ឧទាហរណ៍ដូចជានៅក្នុង

កងទ័ពស្តេច សុរិយាវរ្ម័នទី ២ បានលើកទ័ព ២០០០០ នាក់ ទៅវាយប្រទេស ដាយវៀត តែត្រូវសេនាបតីយួន ឈ្មោះ លីកុងប៊ីញ វាយបញ្ចេញអំពីខេត្ត ង៉ែអាន មកវិញ ។ បរាជ័យនេះបានបណ្តាលឲ្យខ្មែរលើកទ័ព វាយប្រទេសយួន ម្តងទៀត ព្រមទាំងសំពៅចំបាំង ៧០០ ជង ។ ហេតុ ដល់ខេត្ត ថាញ់ ហ្វា ( Thanh Hoa )

ក្នុងសង្គ្រាមនេះ ចាមបានបាត់បង់ជីវិតអស់ជា ច្រើន ។ ដូច្នេះហើយបានជានៅ គ.ស. ១១៣១ ប្រទេស ចាមមានការព្រួយបារម្ភខ្លាចយួនចងគំនុំ ក៏លែងជួយខ្មែរ ទៀត បែរជានាំដង្វាយទៅថ្វាយស្តេចយួនវិញ ។

ស្តេច សុរិយាវរ្ម័នទី ២ បញ្ជាឲ្យទ័ពខ្មែរចូលវាយ លុកប្រទេសចាមក្នុងរាជ្យ ជ័យឥន្ទ្រវរ្ម័នទី ៣ ដណ្តើម យកក្រុង វិជ័យ រួចកាត់យកប្រទេសចាម្ប៉ាទាំងមូល (១១៤៥) ។ ក្រោយដែលបានធ្វើគតស្តេចចាមហើយ

សូរិយោវរ្ម័នទី ២ បានដាក់ឧបរាជខ្មែរដោយបងថ្លៃឈ្មោះ ហរិទេវៈ ទៅគ្រប់គ្រងប្រទេសចាម អស់រយៈពេល ៤ ឆ្នាំ ។ លុះមកដល់គ.ស. ១១៤៩ ចាមនៅភាគខាងត្បូង បានបះបោរឡើងធ្វើឃាតឧបរាជនោះ ហើយលើកស្តេចចាម ជ័យហរិវរ្ម័នទី ១ វិញ ។ ក្រោយមកអង្គនេះបានបង្ក្រាបពួក រដែ ដែលបានប្រកាសយកព្រះអនុជថ្លៃចាម «វង្សរាជ» ធ្វើជាស្តេចរបស់ខ្លួននៅ គ.ស. ១១៥០ តែព្រះអង្គម្ចាស់នេះបានភៀសខ្លួនទៅស្រុកយួនរួចកេណ្ឌជាតិយួនមកប្រឆាំងនឹងប្រទេសចាមវិញ ។ តែត្រូវបរាជ័យ ។

ក្នុងរវាងពាក់កណ្តាលសតវត្សទី ១២ ស្តេចចាម ជ័យហរិវរ្ម័នទី ១ បានបង្ក្រាបពួកបះបោរនៅ ភាណ្ឌុរង្គ និងនៅ អមរាវតី ធ្វើឲ្យប្រទេសបានឯកភាពវិញ ហើយបញ្ជាឲ្យនាំទ័ព ធ្វើសង្គ្រាមជាមួយប្រទេស

ខ្មែរនិងប្រទេសយួនទៀត ។

នៅក្នុងប្រទេសខ្មែរ ក្រោយដែល **សូរិយោវរ្ម័នទី ២** សុគតទៅ មានកើតអសន្តិសុខយ៉ាងខ្លាំង បណ្ដាលមកពីការដណ្ដើមរាជ្យសម្បត្តិ រវាង **ធរណីន្ទ្រវរ្ម័នទី ២** ដែលជាបិតាស្ដេច **ជ័យវរ្ម័នទី ៧** និង**យសោវរ្ម័នទី ២** ។ **ធរណីន្ទ្រវរ្ម័នទី ២** បានបញ្ជូនរាជបុត្រ ដែលមានអាយុតែ ១៥ វស្សាប៉ុណ្ណោះ ឲ្យនាំទ័ពទៅសងសឹក វាយក្រុង **វិជ័យ** នៃប្រទេសចាម ។ ប៉ុន្តែត្រូវត្រឡប់មកក្នុងប្រទេសកម្ពុជា ដោយជ្រាបថាបិតាត្រូវ**យសោវរ្ម័នទី ២** ធ្វើគត់ តែមិនហ៊ានចូលក្នុងមហានគរទៀយ ។ ៤ ឆ្នាំក្រោយមក គឺនៅក្នុង គ.ស. ១១៦៥ មានមន្ត្រីម្នាក់នាម **ត្រីភូវនាទិត្យ** ជ្រៀតរាជ្យ ហើយធ្វើគត**យសោវរ្ម័នទី ២** រួចឡើងសោយរាជ្យលើមហានគរ បាន ១២ ឆ្នាំ ។

នៅពេលដំណាលគ្នានោះ ពួកក្សត្រនៅប្រទេសចម្ប៉ា ក៏ត្រូវមេបះបោរម្នាក់ធ្វើគុតដែរ ហើយឡើងសោយរាជ្យ មាននាមថា « ជ័យឥន្ទ្រវរ្ម័នទី ៤ (១១៦៧-១១៩២) ។ ស្ដេចអង្គនេះបានរៀបចំទ័ព តាមរបៀបបច្ចេកទេសយុទ្ធសាស្ត្រចិន ដោយបានប្រើសេះជាយានជំនិះជំនួសដំរី ។ មានការចងបក្ខភាពជាមួយប្រទេសយួន (រាជវង្សលី) និងប្រទេសចិន (រាជវង្សស៊ុងខាងត្បូង) ៕

ទៀតសោតកាលដែលប្រទេសខ្មែរ កំពុងជួបប្រទះនឹងស្ថានការណ៍កប់ម្សូរបែកបាក់គ្នានោះ ប្រទេសចាម បានលើកទ័ពតាមផ្លូវទឹក តាមទន្លេមេគង្គ-ទន្លេសាប ហូតដល់រាជធានីមហានគរ ដោយមានចិនម្នាក់ជាអ្នកនាំផ្លូវ ។ នៅឆ្នាំ គ.ស. ១១៧៧ ទ័ពចាមបានព័ទ្ធឡោមមហានគរជាប់ ធ្វើគុត ព្រះត្រីភុវនាទិត្យ ហើយក៏គ្រាតរឹបយកទ្រព្យសម្បត្តិខ្មែរអស់ជាច្រើនរាប់មិនអស់ ។

ចាមត្រួតត្រាមហានគរ អស់រយៈពេល ៤ ឆ្នាំ ។

ព្រឹត្តិការណ៍នេះ បានធ្វើឲ្យប្រជារាស្ត្រខ្មែរឈឺចាប់យ៉ាងក្រៃលែង ។ ស្តេច ជ័យវរ្ម័នទី ៧ ដែលបានគង់ក្នុងព្រៃ អស់រយៈពេល ១៥ ឆ្នាំហើយ ក៏បានរៀបចំកងទ័ពរួមមានប្រជាជនខ្មែរទាំងអស់ ដើម្បីកំចាត់ចាមចេញឲ្យផុតស្រឡះពីផែនដីខ្មែរ ។ មានរាជគ្រូចាមមួយអង្គនាម ស្រីវិទ្យានន្ទន៍ ក៏ចូលដៃនឹងព្រះអង្គដែរ ។ មុននឹងអនុវត្តគម្រោងការនេះជ័យវរ្ម័នទី ៧ បានបោះបង្គោលមួយនៅតំបន់ខាងលិចខេត្តបាត់ដំបង (មល្យង) ជាមុនសិន ។ លុះមកដល់ គ.ស. ១១៨១ ទើបព្រះអង្គលើកទ័ពមកវាយកម្ទេចពួកចាមមកវិញ ។ មិនតែប៉ុណ្ណោះ បានត្រាស់បញ្ជា ស្រីវិទ្យានន្ទន៍ ឲ្យទៅក្រុងវិជ័យ ដើម្បីចាប់ស្តេចចាម ជ័យឥន្ទ្រវរ្ម័នទី ៤ យកមកប្រទេសខ្មែរ ហើយយកប្រទេសចាមធ្វើជាចំណុះផង ។ ជ័យវរ្ម័នទី ៧ បានប្រគល់តំបន់ បាណ្ឌុរង្គ ឲ្យ

ស្រីវិទ្យានន្ទន៍ សោយរាជ្យមានឈ្មោះថា "ស្រីសូរិយពម្មទេវៈ ។ រីឯក្រុងវិជ័យ ត្រូវប្រគល់ទៅអនុជថ្លៃគ្រងរាជ្យជំនួស ។ ប៉ុន្តែត្រូវស្តេចតាមមួយអង្គនាម រេស្សុបតី ឬ ជ័យឥន្ទ្រវរ្ម័នទី៥ ធ្វើគត ។ ក្នុងពេលនោះ ជ័យវរ្ម័នទី ៧ បានដោះលែងស្តេចតាម ជ័យឥន្ទ្រវរ្ម័នទី ៤ ឲ្យមានសេរីភាពវិញដើម្បីចូលរួមជាមួយ ស្រីសូរិយពម្ម-ទេវៈ បង្ក្រាបស្តេចក្រុងវិជ័យគ្រាតែបានជ័យជំនះ ។

តែក្សត្រតាមដែលបានទទួលជ័យជំនះក្លាយជាសត្រូវនឹងគ្នាទៅវិញ ។ នៅ គ.ស ១១៩២ ស្រីសូរិយពម្ម-ទេវៈ បានជ័យជំនះហើយកំចាត់ពួកសត្រូវ ចេញពីប្រទេសតាម ។

តាំងពីពេលនោះ ស្រីសូរិយពម្មទេវៈ ហាក់ដូចជាចង់ប្រកាសឯករាជ្យជូនប្រទេសតាមពីការត្រួតត្រារបស់ខ្មែរ ។ ក្នុងរឿងនេះ ជ័យវរ្ម័នទី ៧ បានបញ្ជូនមា របស់ស្តេចតាម

នាង **ចិន្ដាធនបតិព្រោម** កាន់ជាយុវកថាប ឲ្យចេញទៅច្បាំងដេញ **ស្រីសូរិយពង្សទេវៈ** ត្រាតែបានសំរេច ។ ក្សត្រអង្គនេះបានភៀសខ្លួនទៅគង់នៅស្រុកយួន តែត្រូវយួនដេញចេញពីប្រទេសទៅទៀត ។

ហេតុមកដល់ គ.ស. ១៦៦២ ប្រទេសចម្ប៉ាតាំងអំពីលបានស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសកម្ពុជា រយៈពេលជាច្រើនឆ្នាំ ។ ក្នុងរយៈកាលនេះ ស្ដេចចាម និងខ្មែរបានពួតដៃគ្នា ដើម្បីទប់ទល់នឹងការជ្រៀតជ្រែករបស់យួន តាំងពី គ.ស. ១៦០៦-១៦១៦ និង ១៦១៨ ។

ប៉ុន្តែក្រោយដែល **ជ័យវរ្ម័នទី ៣** សុគតទៅ(១៦៤០) ស្ដេចខ្មែរ **ឥន្ទ្រវរ្ម័នទី ២** ( ១៦៤២-១៦៥៣ ) ដោយបានមេត្តាធម៌ស្រឡាញ់សន្តិភាព មិនគោរពព្រះពុទ្ធសាសនាដូចបិតាដែរនោះ ក៏បានឲ្យប្រទេសចម្ប៉ាបានសេរីភាពវិញ ។

វីពខ្មៅបានត្រូវគេបណ្តេញពីប្រទេសចាម មកដាក់នៅតំបន់ព្រំដែនខាងលិច ព្រោះនៅដើមសតវត្សទី ១៧ នោះ ពួក **សៀម-មន** បានធ្វើសកម្មភាព បះបោរប្រឆាំងយ៉ាងខ្លាំង ៗ

ប្រទេសចម្ប៉ា ក្រោយដែលបានរំដោះផុតពីអំណាចខ្មែរហើយ បានខិតខំស្ថាបនាប្រទេសឡើងវិញ ដើម្បីឈមមុខទប់ទល់នឹងជាតិយួន "**ដាយវៀត**" ដែលចូលមកយាយីព្រំដែនខាងជើងប្រទេសចាមគ្មានឈប់ឈរ ។

## ១០ ការបះបោរនៃពួកមននិងសៀម

ជនជាតិ **មន** ធ្លាប់រស់នៅក្រោមការត្រួតត្រារបស់ខ្មែរយូរលង់មកហើយ នៅក្នុងសម័យ **ហ្វូណន** តែបានរំដោះខ្លួន ហើយបង្កើតនិងពង្រីកនូវការគ្រប់គ្រងជារដ្ឋមួយឯករាជ្យ ៗ រដ្ឋមនចែកជាពីរសំខាន់ ៗ គឺរដ្ឋ **ទ្វារាវតី** ឬ **លុពបុរី** នៅភាគខាងក្រោមនៃវាលទំនាប ទន្លេ **មេ-**

ពេណាម ឧត្តរដ្ឋ ហរិបុញ្ញ័យ ម៉ុ ឡាំភូន នៅកាត់ខាងលើ អ្នកស្រុក មន តែងបានទទួលនូវកេរ្តិ៍ធម៌ឥណ្ឌា ពិសេស គឺអក្ខរពាលីនិងលទ្ធិពុទ្ធនិយម ដែលហូរមកពីប្រទេសឥណ្ឌា ។

នៅដើមសតវត្សទី ១០ ប្រទេសមនស្ថិតនៅក្នុងការគ្រប់គ្រងនៃប្រទេសកម្ពុជាសម័យ មហានគរ ទៀត ដោយសារស្តេច សុរិយាវរ្ម័នទី ១ ដែលធ្លាប់បានសោយរាជ្យនៅ លពបុរី ដែរ ។ សុរិយាវរ្ម័នទី ១ មានបិតាតាមសុជិត សោយរាជ្យនៅ នគរស្រីធម្មរាជ តំបន់ក្រុង លីគ័រ សព្វថ្ងៃ ។ មាតាជាក្សត្រីខ្មែរត្រូវជាញាតិនឹង ឥន្ទ្រវរ្ម័នទី១ ក្នុងវង្ស សូរ្យ ដែលមានខ្សែស្រឡាយពីឥសី កម្ពុ និងនាង មេរា ។

ក្រោយដែលបានគង់នៅ លពបុរី មិនយូរប៉ុន្មាន សុរិយាវរ្ម័នទី ១ ក៏បានចូលមកវាយដណ្តើមយក យសោធរបុរ ហើយឡើងគ្រប់គ្រងលើប្រទេសកម្ពុជា ។ បហ

នគរចាំងមូល ។ ព្រះអង្គបានលើកទ័ពទៅវាយយក ហរិបុញ្ជ័យ ទៀត ។

ប៉ុន្តែមកដល់ពាក់កណ្តាលសតវត្សទី ១២ ពេលដែល សូរិយាវរ្ម័នទី ២ កំពុងជាប់សង្គ្រាមនៅឡើយមិនចាប់ ជាតិមន ក៏បានរំដោះខ្លួនឯករាជ្យឡើង ក្រោមការដឹកនាំ នៃស្ដេចមួយនាម អាទិត្យរាជ ។

ការបះបោរសំខាន់ជាងគេ គឺបុណ្ណាលមកពីជាតិ សៀម ដែលបានចុះមកពី ណានចៅ ហើយរស់នៅ បង្កប់ខ្លួន ជាមួយជនជាតិ មន ពិសេសនៅ ហរិបុញ្ជ័យៗ លុះមកដល់ឆ្នាំ គ.ស. ១២២០ ពួកនេះបានចាប់ផ្តើមការប្រយុទ្ធគ្រប់ទិសទី យកជ័យជំនះលើជាតិ មន បាន ហើយ គ្រប់គ្រងលើដី ហរិបុញ្ជ័យ និង ទ្វារាវតី ។ ស្ដេចសៀម ដែលសោយរាជ្យដំបូងនាមថា "ផាឡុង" ឬ ឥន្ទ្របតិន្ទ្រ-ទិត្យ" ព្រមទាំងបានកេណ្ឌសេក ជាមួយស្ត្រីខ្មែរនាម "បើ-

ខាងបារាំង" ផង ហើយមានជ្រើសរើសក្រុង ស៊ុំបោ មីយ ធ្វើជារាជធានី ។ បេចពីដែលជិតស្និទ្ធជាមួយស្តេច ផ៊ោម្ប៉ូង ជាងគេឈ្មោះ បាំងថៅញ្ញារ ។ មន្ត្រីនេះបានធ្វើ ការបះបោរ ប្រឆាំងនឹងអំណាចខ្លួនទៅលើខេត្រគ្រវ៉ះជា ច្រើនលើកច្រើនសា ។ ក្រោយដែលបានសុគតទៅ រាជ បុត្រនាម "រាមាកំហែង" បានសោយរាជសម្បត្តិ ក្នុង រាជ គ ស ១២៨៣ ។

## ១១ ភូមាលេបយកជីមុន

ជនជាតិ ភូមា រស់នៅលើកលចំនាប ក្យៅក្សៃ ( Kyau Ksè ) ជិតទីប្រសព្វនៃទន្លេ អ៊ីរ៉ាវតី និងដៃទន្លេ ជិនវិន ( Chindwin ) ។ គឺជាមូលដ្ឋាននៃសេដ្ឋកិច្ចកសិកម្ម ដ៏សំខាន់ និងជាទីប្រជុំនៃការទាក់ទងរវាងប្រទេសភូមិណ្ណា អស្សាំ ( Assam ), ប្រទេសសៀមនៅ ពុកាន់ទៀ, រដ្ឋនៃជនជាតិ សៀម ( Shan ) និងសម្ព័ន្ធប្រទេសកាល ។

ជនជាតិ ព្យូ បានចុះមកពីតំបន់ ទីបេ តាមច្រកភ្នំ និងដងទន្លេ ជាមួយនឹងជនជាតិ ហោក សៀម ផង ។ គេបានដណ្ដើមយកអំណាច ពីពួក មន ហើយស្ថាបនាទីក្រុងមួយ នៅ បរ៉ែន ក្នុងឆ្នាំ គ.ស. ៨៤៩ ក្រោមការដឹកនាំនៃស្ដេច ពៀនប៉្យា ( Pyinbya ) ។ ក្រោយមក រាជសម្បត្តិបានត្រូវរាជបុត្រដណ្ដើមគ្នាគ្រប់គ្រង ទីបំផុតនៅក្នុង គ.ស. ១០៤៤ រាជបុត្រមួយអង្គនាម អនោរថៈ ( Anawrapta ) បានដណ្ដើមយកអំណាចហើយចាប់កសាងប្រទេស ភូមា ជាអធិរាជាណាចក្រ ដ៏សំខាន់នៅឥណ្ឌូចិន ប្រៀបស្មើនឹងអាណាចក្រកម្ពុជា មហានគរដែរ ។ ប្រទេសភូមាលាតសន្ធឹងតាំងពីតំបន់ បាម៉ូ ( Bhamo ) រហូតដល់ឈូងសមុទ្រ ម៉ារតាបាន ( Martaban ) និងពីផ្លូវភ្នំ អារ៉ាខាន់ រហូតដល់ផ្លូវភ្នំតេណាសេរីម ជាប់នឹងព្រំដែននៃប្រទេសកម្ពុជា ។

ក្នុងសម័យនេះ ព្រះពុទ្ធសាសនា ហីនយាន ក្នុងក ពីប្រទេស សិរីលង្កា បានជ្រួតជ្រាបយ៉ាងខ្លាំង ពេញទាំងប្រទេសភូមា ។ ដូច្នេះគឺប្រទេស ភូមា នេះហើយ ដែលបានផ្សាយដំបូងនូវលទ្ធិពុទ្ធនិយម ថេរវាទ មកលើឥណ្ឌូចិន ។

នៅវេលាពាក់កណ្ដាលសតវត្សទី ១១ មានចំនាស់គ្នាយ៉ាងធំរវាងពួក មន និងជនជាតិ ភូមា ។ ពួក ភូមា បានវាយសម្រុកក្រុង ថាតុន នៃពួក មន (១០៥៧) ហើយកៀរយកពួកនេះជាឈ្លើយជាច្រើនម៉ឺននាក់ផង ។

ពួកឈ្លើយ មន ដែលជាជាតិមួយធ្លាប់មានវប្បធម៌ខ្ពស់គ្រាន់បើដែរនោះ បានផ្សាយនូវអក្សរសាស្ត្រ សិល្បៈ និងអក្សររបស់ខ្លួនយ៉ាងទូលំទូលាយ ។ គេបានចារឹកនូវអក្សរមននៅទីក្រុង បគន ថែមទៀតផង ។ អារ្យធម៌ មន និង ភូមា បានលាយចម្រុះគ្នា បង្កើតជាវប្បធម៌មួយ

ថ្មី ។ ស្ដេចអនោរថា បានបញ្ជាឲ្យកសាង ព្រះវិហារមួយយ៉ាងធំ សំរាប់ដំកល់ព្រះទន្តព្រះពុទ្ធ ដែលគេបាននាំយកមកពីប្រទេស លង្កា ។ ក្រៅពីនេះនៅមានសង់បុស្បុកជាច្រើនទៀត តោពេញរាក្សក្បួកតា ដូចផងជាតិដើមស្រុកភាស៊ីដែរ ។

នៅក្នុងរាជស្ដេចក្យាន់ស៊ីថា ( Kyanzitha ) (១០៨៤ ១១៣២ ) អាណាចក្រ បគាន បានស្គាល់នូវភាពរុងរឿងដល់កំពូល ។ ព្រះអង្គជាព្រះពុទ្ធសាសនូបត្ថម្ភ ដ៏ប្រពៃ ។ ជំនឿក្នុងព្រហ្មញ្ញសាសនា ក៏នៅមានឥទ្ធិពលដែរ ពិសេស នៅក្នុងពិធីផ្សេងៗក្នុងព្រះបរមរាជវាំង ។ ព្រះអង្គបាន ឲ្យគេកសាងព្រះវិហារមួយដ៏ធំ ឈ្មោះ អានន្ទៈ ( Ananda ) ដែលជាស្នាដៃមួយដ៏សំខាន់ក្នុងវិស័យ សិល្បៈភូមា ។ ក្រៅពីនេះមានបញ្ជូនរាជទូតទៅកាន់ ប្រទេសចិនប្រទេសឥណ្ឌា ដើម្បីកែចំណងខាងផ្លូវនយោ

បាយនិងសេដ្ឋកិច្ចផង ។

លុះមកដល់រាជ្យស្តេច អាឡុងស៊ីធូ Alaungsithu (១១១៤-១១៦៧) ព្រះពុទ្ធសាសនាបានទទួលនូវការឧបត្ថម្ភយ៉ាងខ្លាំងថែមទៀត ។ តែដោយចិត្តជាប់ជំពាក់តែនឹងផលទៀតករបខា ក្តៅតឹងផលកិច្ចការរដ្ឋ បានជាប្រជាជនកាន់តែមិនសូវពេញចិត្ត ,រហូតដល់កដំរុតផ្ទាល់ធ្វើធុត ។ ចាប់តាំងពីពេលនោះមក អនាធិបតេយ្យបានសាបព្រោះពេញប្រទេស ។

ប៉ុន្តែមកដល់រាជ្យស្តេច ណារបតិស៊ីធូ ( Narapatisithu) ( ១១៧៣-១២១០ ) ទើបសន្តិភាព បានកើតមានឡើងវិញ ។ កសិកម្មផ្តល់ផលដ៏បរិបូរ ។ ព្រះពុទ្ធសាសនាហីនយានក្លាយទៅជាសាសនារដ្ឋ ដែលប្រជា-ពលរដ្ឋគ្រប់ស្រទាប់គោរពបូជា ។ អាស្រ័យដោយសារការប៉ុនប្រសប់ក្នុងការដឹកនាំ លទ្ធិថ្មីនេះបានជ្រួតជ្រាបយ៉ាង

ធាប់ហើយដល់ប្រទេស សៀម លាវ និងប្រទេសកម្ពុជា មហានគរ ( សម័យ ជ័យវរ្ម័នទី ៧ ) ។

ចូលមកក្នុងសតវត្សទី ១៣ ប្រទេសកម្ពុជាបានបាត់បង់នូវជាមការពយ៉ាងច្រើន ។ ប្រជារាស្ត្រជួបប្រទះនឹងទុក្ខក្រៗ បន្ទាប់មក ការលុកលុយនៃពួក ប៉ុរតោល បានបណ្ដាលឲ្យប្រទេសកម្ពុជាកាន់តែដុនដាបណាស់ទៀត ។

## ១២- សំទុះនៃកោះជ្វា

នៅខាងដើមសតវត្សទី ១០ អាណាចក្រ ស្រីវិជ័យ នៅតំបន់កោះ ស៊ូម៉ាត្រា បានធ្លាក់ចុះអំណាច បណ្ដាលមកពីសំទុះដ៏ខ្លាំងក្លានៃអាណាចក្រទាំងឡាយនៅកោះជ្វា ។ រាជធានីបានផ្លាស់ទៅតាំងនៅភាគខាងកើតនៃកោះ ត្រង់តំបន់ជ្រលងទន្លេ ប្រាតាស ( Bratas ) ក្នុង គ.ស.៩២៩ រហូតដល់ គ.ស. ១២២២ ។

គឺនៅក្នុងសម័យនោះហើយ ដែលមានការចងក្រង

រឿង រាម៉ាយណភ្ជា ក្នុងរាជ្យស្ដេច ស៊ិណ្ឌុក (៩២៩-៩៤៧) និងបកប្រែរឿង មហាភារត ក្នុងរាជ្យស្ដេច ធម្មវង្ស (Dharmavamça) (985-1006) ។ ស្ដេចខាងក្រោយបានលើកទ័ពទៅវាយស្រុក ស្រីវិជ័យ តែត្រូវស្លាប់ក្នុងសង្គ្រាមនោះ ។ នៅពេលដែលអាណាចក្រ ស្រីវិជ័យ ធ្លាក់ចុះអន់ថយ ស្ដេចជ្វានាម អៃរឡង្គា (Airlanga) (1019-49) បានរៀបចំប្រទេស បង្រួបបង្រួមផែនដីអាណាចក្រភាគខាងកើតនិងភាគកណ្ដាលវិញ ។ សន្តិភាពក្នុងរយៈពេលនោះ បានធ្វើឲ្យសេដ្ឋកិច្ចមានសកម្មភាពឡើងវិញ ។ កំពង់ផែ ស៊ូរ៉ាយ៉ា និង ទុយបាន បានទទួលពាណិជ្ជករមកពីគ្រប់ទិសទី ដូចជាពួកឥណ្ឌា នៅ កលិង្គ នៅ បឹងកាល ពួក ស៊ិនកាឡេ ចូឡា មាឡាបា តាមិល និងពួក ចាម មន ខ្មែរ មកពីឧបទ្វីបឥណ្ឌូចិន ។

ក្រោយដែលស្តេចអង្គនេះបានសុគតទៅ ប្រទេសជ្វា បានបែកជាពីរផ្នែកគឺ **ជង្គាលៈ** នៅភាគខាងកើត និង **កឌីរី** (Kediri) នៅភាគខាងលិច ។ ប៉ុន្តែមកដល់ឆ្នាំ ១០៧៧ រដ្ឋ **កឌីរី** បានរួបបញ្ចូលរដ្ឋខាងកើតវិញ ហើយបង្កើតជាអាណាចក្រជ្វា ទទួលស្គាល់នូវពន្លឺមួយថ្មីក្នុងវិស័យអក្សរសិល្ប៍ និងក្នុងវិស័យពាណិជ្ជកម្ម ។ ការលូតលាស់ដ៏សំបើមនៃកោះនេះ បានធ្វើឲ្យអ្នកដំណើរចិនឈ្មោះ **ជូ គីហ្វីយ** សរសេរក្នុង គ.ស. ១១៧៨ ថា ៖ "ក្នុងគ្រប់ប្រទេសទាំងអស់ មានតែ **អារ៉ាប៊ី** ទេ ដែលសម្បូរវត្ថុមានតម្លៃច្រើនជាងគេ បន្ទាប់មកគឺកោះ **ជ្វា** ហើយទី ៣ គឺអាណាចក្រ **ស្រីវិជ័យ**" ។

អរិយធម៌ **ខ្មែរ ចិន ចាម** ដែលមានពន្លឺចិញ្ចែងក្នុង

អាស៊ីភាគអាគ្នេយ៍ បានលាក់បង្កប់នូវគុណវិបត្តិជាច្រើន ដែលធ្វើឲ្យអារ្យធម៌នេះវិនាសអន្តរាយយ៉ាងឆាប់រហ័ស ។ គុណវិបត្តិនោះ គឺមកពីអ្នកដឹកនាំនៃប្រជាជាតិនីមួយ ៗ លើកតម្លៃឲ្យធំហួសវិស័យ ហួសហេតុ ហើយមានចំណង់ធ្ងន់ជាងប្រថពីទៅទៀត ។ អំណាចរបស់ស្ដេច មានមហិទ្ធិអស្ចារ្យ គ្រប់ដណ្ដប់ដោយការគោរពបូជាហួសហេតុពីសំណាក់អ្នកផង ពាល់តែលែងស្គាល់ការពិត ឬលក្ខណៈប្រាកដនិយមរបស់ប្រជាជាតិ បានសេចក្ដីថា អ្នកដែលហែហមស្ដេចបានបញ្ជោរ និង ញ៉ោះស្ដេចឲ្យពាល់តែផុតកំពូល រហូតដល់រលំដោយជៀសមិនផុត ។

ប្រាសាទធំ ៗ បានត្រូវកសាងយ៉ាងឆាប់រហ័ស ដោយកេណ្ឌមនុស្សពេញការឲ្យកសាង ដោយមានគោលបំណងសំរាប់តែដាក់ធាតុស្ដេចប៉ុណ្ណោះ ។ ការនេះបណ្ដាលឲ្យប្រជាជន ធ្លាក់ទៅជាមនុស្សក្រហក់ក្រៀយ ហើយ

ខ្ទោះឈាម ។ ទេពកោសល្យរបស់ស្តេចក៏ត្រូវបប ហើយភាពរុងរឿង ព្រមទាំងអនុភាពខ្លាំងក្លា នៃអរិយធម៌ ក៏ត្រូវរុះរោយជាមួយគ្នាដែរ ។

ការធ្លាក់ចុះទន់ខ្សោយនៃអរិយធម៌ ខ្មែរ មន ចាម នាសម័យសតវត្សទី ១៤ ដល់សតវត្សទី ១៧ មិនគ្រាន់តែ បណ្តាលមកពីរបៀបរបបនយោបាយផ្ទៃក្នុងប៉ុណ្ណោះទេ តែ ទាក់ទងទៅនឹងការបែកបាក់គ្នារវាងជាតិ ចាម-ខ្មែរ-មន ដែលជាបងប្អូននឹងគ្នានេះតែម្តង ។ ទំនាស់រវាងគ្នានេះ មិនគ្រាន់តែជាផលវិបាក នាំមកនូវសង្គ្រាមដ៏យូរអង្វែង ប៉ុណ្ណោះទេ តែបណ្តាលឲ្យសត្រូវក្រៅអំបូរពួកថ្មីមានអំបូរ **ចិន ប៉ុងគោល** ជាដើម ចូលមកយាយី លេបយកទឹក ដីទៀតផង ។

# ជំពូកទី ៣

# វិបត្តិនៅអាស៊ីភាគអគ្នេយ៍

## សតវត្សទី ១៣

---

ៜ ១៣- ការធ្លាក់ចុះនៃអរិយធម៌ឥណ្ឌា ។ ១៤- ការលុកលុយនៃពួកម៉ុងគោលទៅលើតំបន់ឃុនណាន ។ ១៥- ពួកម៉ុងគោលចុះទៅដែនដីអាស៊ីភាគអគ្នេយ៍ ។ ១៦- ដំណើរមកដល់នៃសាសនាអ៊ីស្លាម ។

---

សតវត្សទី ១៣ បានបង្ហាញឲ្យឃើញ នៅលើអាស៊ី[illegible] ភាគអគ្នេយ៍ទាំងមូល នូវការធ្លាក់ចុះនៃអរិយធម៌មួយដ៏ ខ្ពង់ខ្ពស់ ដែលបានស្ថិតនៅលើតំបន់នេះ តាំងពី[illegible] សតវត្សមកម៉្លេះ ។ គេបានសង្កេតឃើញថា បុព្វហេតុនៃ ក្នុងប្រទេសតែម្តង ដែលបណ្តាលឲ្យមានការទន់ខ្សោយ នេះ វិញព្រឹត្តិការណ៍នៅខាងក្នុងសតវត្ស បណ្តាលមកពី

ការលុកលុយនៃពួកម៉ុងគោល និងដំណើរបែកបាក់នៃពួកអ៊ីស្លាម ; គ្រាន់តែជាកត្តាជំរុញឲ្យឆាប់ផុតប៉ុណ្ណោះ

## ១៣- ការធ្លាក់ចុះនៃអរិយធម៌ឥណ្ឌា

ដំបូងឡើង មកដល់ដើមសតវត្សទី ១៣ នេះ អាណាចក្រ ឃ្មួន និង ចាម់ តំណាងអរិយធម៌ ចិននិង ឥណ្ឌា នៅតែប្រយុទ្ធគ្នាទៅឡើយ ។ ប៉ុន្តែប៉ុណ្ណោះ ចាម. អាចទៀតមកធ្វើសង្គ្រាមនិង ខ្មែរ ជាបន្តបន្ទាប់ ធ្វើឲ្យអរិយធម៌ ឥណ្ឌា ស្លុតទៅក្នុងសភាពគ្រោះថ្នាក់ ។ នៅប្រទេស ភូមា ក្នុងឆ្នាំ ១១៩០ មានផ្សាយព្រះពុទ្ធសាសនាថេរវាទ តាមរយៈពុទ្ធសាសនិកជាតិមន ម្នាក់ ធ្វើឲ្យប្រពៃណីពុទ្ធសាសនាមហាយាននិងព្រហ្មញ្ញសាសនា មានការរុះរើរដួលដែរ ។ វប្បធម៌សំស្ក្រឹត ដែលធ្លាប់ប្រើប្រាស់ជាផលអស់រយៈពេលយ៉ាងយូរមកហើយនោះ ក៏ធ្លាក់អំណាចនៅចំពោះស្ពៃដៃសៀវភៅ

ទាំងឡាយ ដែលសរសេរជាភាសា បាលី ។ ទីប្រជុំ គោរ ថ្វា ដែលធ្លាប់ជាគជាំទៅដោយវប្បធម៌ពុទ្ធសាសនា បានធ្លាក់ទៅក្នុងឥទ្ធិពល នៃសាសនា អ៊ីស្លាម យ៉ាងឆាប់ រហ័ស ៗ

ជាមួយគ្នា នឹងការផ្លាស់ប្ដូរខាង សាសនា អក្សរសាស្ត្រ, សិល្បៈ ក៏អន់ថយដែរ ព្រោះនៅខាងដើម សតវត្សទី ១៧ គេមិនសូវឃើញមានសង់ប្រាសាទច្រើន ទេ អាស្រ័យដោយសារការបះបោរនៃពួកឈ្លើយសង្គ្រាម នេះម្ដង និងម្ដងទៀត ទំនងនៃដុំប្រាសាទនានា ដែលត្រូវស្ថាបនាក្នុងរាជ្យស្ដេច សូរ្យវរ្ម័នទី ២ និង ជ័យវរ្ម័នទី ៧ បានធ្វើឲ្យប្រជារាស្ត្រមានការនឿយណាយ យ៉ាងច្រើន ៗ ព្រមជាមួយនេះ ការទន្ទ្រានពីពួក មិនមុំងគោល បានញាំងឲ្យឥទ្ធិពលវណ្ណាថយចុះជា លំដាប់ ៗ

## ១៤- ការលុកលុយនៃពួកម៉ុងគោលនៅលើ តំបន់យុនណាន

ជនជាតិ ម៉ុងគោល ជាជនជាតិពនេចរអន់អាចក្លាហាន ។ គេធ្លាប់បានពង្រីកត្បាតលើពិភពលោកមួយចំហៀងធំ ៗ ក្រោយដែលពង្សវង្ស ស៊ុង នៃប្រទេសចិន បានកើតចលាចល ជនជាតិម៉ុងគោល ដែលធ្លាប់រស់នៅជាមួយចិនជាយូរមកហើយនោះ ក៏បានវាយដណ្តើមអំណាចគ្រប់គ្រងលើប្រទេសចិនកាន់តែខ្លាំងឡើង ។ អធិរាជ គូប៊ីឡាយខាន់ ( KoubilaiKhan ) បានបន្តនយោបាយរបស់ ហ្សង់ហ្ស៊ីខាន់ ( Gengis-Khan ) ហើយគ្រប់គ្រងប្រទេសចិនទាំងមូល ពី គ.ស. ១២៦០ ដល់ គ.ស. ១៣៦៨ ។

នៅឆ្នាំ គ.ស. ១២៥៣ កងទ័ព គូប៊ីឡាយខាន់ បានវាយយកតំបន់ យុនណាន ធ្វើឲ្យជនជាតិសៀម រត់ភៀសខ្លួនចុះមកដល់ចំកណ្តាលតាមទន្លេមេណាម និង

ទន្លេមេគង្គ ។

ជនជាតិសៀមនេះសោត ក៏បានអនុវត្តន៍យោបាយរកកើតដីដូចម៉ុងគោលដែរ ។ ស្តេច រាមាកំហែង បានបះបោរដណ្តើមយកក្រុង សុខោទ័យ រំដោះប្រទេសសៀមឲ្យផុតពីការត្រួតត្រារបស់ខ្មែរ ហើយដណ្តើមយកដីមួយភាគធំនៃជនជាតិមន-ភូមានិងម៉ាឡាយូ ។ គឺស្តេចនេះហើយដែលបានរៀបចំការគ្រប់គ្រងថ្មី បង្កើតអក្សរសៀមដោយយកបែបបទតាមអក្សរខ្មែរតែតាំងពីអស់ ។

ពេលដែល រាមាកំហែង កំពុងស្ថាបនាអំណាចសៀមនៅតំបន់ឥណ្ឌូចិនកណ្តាលប មេដឹកនាំជាតិហៅម្នាក់ ឈ្មោះ "ម៉ង់រ៉ាយ" បានបង្កើតរដ្ឋមួយទៀតនៅភាគខាងជើងឈ្មោះថារដ្ឋ សៀងរ៉ាយ (១២៦២) ព្រមទាំងបានដណ្តើមយកតំបន់ ហារិបុញ្ជ័យ ដែលភូមាបានត្រួតត្រា ដោយបានចងសម្ពន្ធមិត្តជាមួយស្តេច

រាមាកំហែង មិនបានបង្កើតរដ្ឋថ្មីមួយទៀត ឈ្មោះ ឡានណា ( lan Na ) ដោយយកក្រុង សៀងម៉ៃ ជារាជធានី ។ ប៉ុន្តែនៅក្នុង គ.ស ១២៩៦ ពួកសៀមបានផ្ដើមយកក្រុង សៀងម៉ៃ ពីលាវទៅ ។

ក្រោយដែលស្ដេច រាមាកំហែង សុគតទៅ គ្មានក្សត្រអង្គណាមួយ មានសមត្ថភាពអាចគ្រប់គ្រងដែនដីសៀមដ៏ធំទូលាយបានឡើយ ដូច្នេះហើយបានជានៅក្នុង គ.ស ១៣៥០ ផ្ទៃសៀមបានធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃស្ដេចមួយអង្គមកពីតំបន់ ឱ្យរ៉ាវតី នាមថា "រាមាធិបតី ។

## ១៥ ពួកម៉ុងគោល ទន្ទ្រានដែនដីអាស៊ីភាគអគ្នេយ៍

ក្រោយដែលបានវាយយកប្រទេស ណានចៅ ហើយ ជាតិចិន ម៉ុងគោល បានបង្កការលុកលុយ ទៅលើ

ប្រទេស ភូមា ទៀត ។ សង្គ្រាមដ៏តឹងតែងបានកើតឡើងនៅតំបន់ បាម៉ូ ។ មកដល់គ.ស. ១២៨៧ រាជធានីបគន ត្រូវពួក ម៉ុងគោល វាយយកបាន ។ ប៉ុន្តែពួកនេះបានលើកស្ដេចភូមាមួយអង្គ នាម Kyawswa ឲ្យគ្រប់គ្រងរដ្ឋភូមាដូចដើមវិញ ។

ឆ្លៀតឱកាសដែលជនជាតិ ភូមា ភាគខាងលើធ្លាក់ទៅលើដៃ ម៉ុងគោល ជនជាតិ មន ដែលច្រើនតែនៅភាគខាងក្រោម បានច្បាំងប្រកាសឯករាជ្យ ។ រីឯពួកភ្នំ សាន និង ថៃ ក៏បានចូលទៅវាយលុក ហូតដល់តំបន់ គៀវកៀ ដែរ ។ ពួកនេះបានដុតតោលក្រុងបគន ឆេះអស់គ្មានសល់ (១២៩៩) ។ ពួកចិនម៉ុងគោល បានចូលមកជួយ ប៉ង់យកតំបន់នេះឡើងវិញ ប៉ុន្តែត្រូវបរាជ័យ ។ ពួក សាន ក៏បានគ្រប់គ្រងប្រទេសភូមាខាងជើង ហើយតាំងរាជធានីមួយថ្មី

ឈ្មោះ **អាវ៉ា** ( Ava ) ក្នុងរវាង គ.ស. ១៣៦៤ ។

ជាតិចិន **ម៉ុងគោល** ពុំគ្រាន់តែលើកទ័ព កុកលុយភូមាប៉ុណ្ណោះទេ គេបានល្ហានពានប្រទេសយួនរហូតដល់ប្រទេសចាម់និងប្រទេសកម្ពុជាទៀតផង ក្នុងបំណងនឹងបើកផ្លូវទៅកាន់ប្រទេសជ្វា ។

នៅ គ.ស. ១២៨២ មេទ័ព **ម៉ុងគោល** ឈ្មោះ **សាគាតូ** ( Sagatou ) លើកទ័ពជើងទឹក មកឡោមព័ទ្ធរាជធានីចម្ប៉ា ។ ចាមវាយតបទៅវិញ ដោយអនុវត្តនូវសង្គ្រាមទ័ពព្រៃ ។ ពីរឆ្នាំក្រោយមក កងទ័ព **ម៉ុងគោល** បានដកថយទៅវិញ រីឯទ័ពជំនួយពីមិនហាន នៅក្នុងដែនដីចម្ប៉ាទៀតដែរ ។ ពួកនេះមានបំណងវាយលុកប្រទេសចម្ប៉ាទៀតតាមផ្លូវគោក ដោយដើរកាត់តាមប្រទេសយួន ។ ប៉ុន្តែជនជាតិយួន បានលើកទ័ពទប់ទល់យ៉ាងខ្លាំងនៅ **ថាញ់ហ្វា** បណ្ដាលឲ្យទ័ព

ម៉ុងគោល ថយទៅវិញ ។

ក្រោយពីការលុកលុយ នៃពួក ម៉ុងគោល ប្រទេសយួន និងប្រទេសចាមកើតទំនាស់និងគ្នាបន្តទៅទៀត ។ ប្រទេសចម្ប៉ា ក្នុងមុនរាជស្តេច ចេប៉ុងង៉ា បានតាមទារខេត្តទាំងឡាយដែលយួនដណ្តើមយកទៅ តែមិនបានសម្រេច ព្រោះយួននៅពេលនោះ មានកម្លាំងខាងយុទ្ធសាស្ត្រពូកែសម្បើម ដែលគេរៀនរបស់ពីប្រទេសចិនមក ។ លុះមកដល់រាជស្តេច ចេប៉ុងង៉ា ទើបពេលដែលប្រទេសយួនកំពុងមានចលាចល ចាមបានលើកទ័ពចូលរហូតដល់រាជធានីយួនចំនួនបីលើក លើកទី ១ ក្នុង គ.ស. ១៣៦១ លើកទី ២ គ.ស. ១៣៧១ និងលើកទី ៣ គ.ស. ១៣៧៩ ។ ជ័យជំនះនេះបានសម្រេចដោយមានជាតិពារ៉ៃ ជួយវាយជួបពីខាងលិចផង ។ ហេតុការណ៍នេះបានធ្វើឲ្យប្រទេសយួនអន្តរាយទ្រព្យសម្បត្តិ និងមនុស្ស

អស់ជាច្រើន បណ្ដាលឲ្យប្រទេសធ្លាក់ចុះអន់ថយ ។ ការបះបោរនៃប្រជារាស្ត្រក៏កើតមានឡើងពេញប្រទេស ។ រាជវង្ស ត្រាន ( Tràn ) ត្រូវមន្ត្រីយួនម្នាក់ ឈ្មោះ ហ្វូគ្វីលី រំលំចោល (១៤០០) ហើយរៀបចំប្រទេសយួនមានឯកភាពឡើង ។

កងទ័ព ម៉ុងគោល បានមកដល់ប្រទេសកម្ពុជាក្នុងរាជ្យស្ដេច (ជ័យវរ្ម័នទី៨) រវាង គ.ស. ១២៨៣ ។ ពីរឆ្នាំក្រោយមកមានការបញ្ជូនសួយសារ ទៅថ្វាយស្ដេចក្រុងចិន ។ ជាង ១០ ឆ្នាំក្រោយមកទៀត មានទូតចិនម្នាក់ នាម "ជូតាក្វាន់" បានមកដល់មហានគរ ហើយបានសរសេររៀបរាប់អំពីទំនៀមទំលាប់ខ្មែរយ៉ាងវែង ។

ពួកម៉ុងគោល បានបញ្ជូនកងទ័ពមួយចំនួនឆ្លងសមុទ្រ ទៅកាន់ប្រជុំកោះហ្វីលីពីន និងកោះឥណ្ឌូនេស៊ី ដែរ ។

ត្រូវជ្រាបថា នៅ គ.ស. ១២២២ អាណាចក្រ កឌិរី នាកោះជ្វា បានធ្លាក់អំណាច ក្រោមកំលាំងនៃពួក សិង្ហាសរី (Singha sari) ។ ស្តេចចុងក្រោយបង្អស់នៃពួកនេះ នាម ក្រឹតណាគរៈ ( Kritanagara ) សោយរាជ្យពីឆ្នាំ ១២៦៨ ដល់ ១២៩២ ។ គឺស្តេចអង្គនេះហើយ ដែលមិនទទួលគោរពតាមពាក្យសុំរបស់ស្តេច មុងគោល គូប៊ីឡាយខាន់ ហើយក្រោយមក បានត្រូវពួកបះបោរសម្លាប់ចោល ។ ពេលនោះកងទ័ពចិនមុងគោលក៏បានមកដល់ដែរ ដើម្បីសងសឹកចំពោះការប្រមាថលើស្តេចខ្លួន ។ ឆ្លៀតពេលនោះ ស្តេច វិជ័យ ដែលសោយរាជ្យតមកទៀត បានសុំកងទ័ពចិនឲ្យជួយក្នុងការកំចាត់ពួកបះបោរ តែបន្ទាប់មកក៏រំដោះខ្លួនពីសម្ពន្ធមិត្រ ហើយសោយរាជ្យនៅ ម៉ូជូប៉ាហ៊ីត ( Mcjopahit ) នាជ្រលង់ ខាងក្រោមនៃទន្លេ ប្រាន់តាស (១២៩៣) ។

ក្រោយបែកទីក្រុងនេះ ក៏ក្លាយទៅជាមជ្ឈមណ្ឌលមួយដ៏សំខាន់នៃ អាស៊ីអាគ្នេយ៍ពីកោះ ។ ការបែកទីនេះជាស្នាដៃនៃមហាមន្ត្រីម្នាក់នាម គស្សមទ្ទះ ( Gajah-Mada ) ( ១៣៣០-១៣៦៤ ) ដោយបានគ្រួតត្រា លើតំបន់កោះ ជ្វា ស៊ូម៉ាត្រា ឧបទ្វីប ម៉ាឡេ រហូត ដល់កោះ ហ្វីលីពីន ។ គឺជាអធិរាជាណាចក្រ ខាងសមុទ្រមានទំហំធ្លាយជាងប្រទេសឥណ្ឌូនេស៊ីសព្វថ្ងៃ ហើយមានការទាក់ទងខាងពាណិជ្ជកម្មជាមួយនឹងចិនរាជវង្ស មីង ( Ming ) និងប្រទេសឥណ្ឌាសម័យ ម៉ុយស៊ុលម៉ាំង ។ ប៉ុន្តែអនុត្តរភាពខាងសមុទ្រនៃរដ្ឋ ម៉ូស្សប៉ាហ៊ីត បានត្រូវយាយីដោយសារសន្ទុះនៃពាណិជ្ជកម្មទៅ ម៉ាឡេស៊ី ហើយជាពិសេសដោយឥទ្ធិពលដ៏ខ្លាំងពូកែនៃ សាសនាអ៊ីស្លាម ដែលបានគ្របសង្កត់យ៉ាងខ្លាំង ទៅលើមូលដ្ឋានអរិយធម៌ឥណ្ឌានៅលើកោះជ្វា ។

## ១៦- ដំណើរមកដល់ នៃសាសនាអ៊ីស្លាម

តាំងពីសតវត្សទី៩មក អ្នកដំណើរនិងអ្នកភូមិវិទ្យាជាតិ អារ៉ាប់ បានពិពណ៌នាយ៉ាងច្រើន អំពីឧបទ្វីបឥណ្ឌូចិន និងប្រជុំកោះ ម៉ាឡេ ។ ប៉ុន្តែសាសនាអ៊ីស្លាមដែលបានមកដល់អាស៊ីអាគ្នេយ៍ មិនសូវបានមកដោយសារពួក អារ៉ាប់ ទេ តែដោយពួក ហ៊ុយស៊ុលប៉ង់ មកពីឥណ្ឌាវិញ ។ ពួកនេះបានមកទាក់ទងនឹងមហាគ្រួសារខ្លះនៅលើកោះ ដែលពួក ម៉ូស្ទប៉ាហ៊ីត មិនអាចត្រួតត្រាបាន ហើយដល់ប្រើពួកនេះជាឧបករណ៍សំរាប់ការប្រយុទ្ធរបស់ខ្លួនខាងនយោបាយនិងខាងសាសនា ប្រឆាំងនឹងទឹកជាធិបតេយ្យឥណ្ឌូជន ។ ក្នុងឆ្នាំ ១៤២០ ពួកអ៊ីស្លាមបានតាំងនៅម៉ាឡាកា ដែលជាកំពង់ផែសមុទ្រដ៏ធំ នៅអាស៊ីអាគ្នេយ៍ និងទីក្រុង ទែណាត (Ternate) ជាកន្លែងគ្រឿងទេស ហូតដល់កោះ មិនដាណាវ ប្រទេសហ្វីលីពីន ។

ប៉ុន្តែនៅកោះជ្វា ជ័យជំនះនៃពួកអ៊ីស្លាមទៅលើអធិរាជាណាចក្រ ម៉ូស្លូប៉ាហ៊ីត បានសំរេចពិតប្រាកដនៅ គ.ស. ១៥២០ ។

ការប្រែប្រួលខាងនយោបាយដ៏ឆាប់ហ័ស ដែលកើតមានឡើងចំពោះរដ្ឋទាំងឡាយ ដែលប្រកាន់អារិយធម៌ឥណ្ឌានោះ បាននាំមកក្នុងវិស័យវប្បធម៌ នូវការផ្លាស់ប្តូរមួយយ៉ាងធំទូលាយ ។ ហេតុការណ៍នេះមិនមែនបណ្តាលមកពីពួកម៉ុងគោលប៉ុន្មានទេ តែមកពីសាសនាព្រាហ្មណ៍និងពុទ្ធសាសនាមហាយាន ដែលធ្វើឡើងសំរាប់តែគោរពស្តេចគោរពបុគ្គល មិនមែនជាសាសនាសំរាប់មហាជនឡើយ ។ ការនេះបញ្ជាក់ឲ្យឃើញនូវការស្រុះចិត្តទទួលយក ពីសំណាក់ប្រជារាស្ត្រ ចំពោះពុទ្ធសាសនាហិនយានយ៉ាងឆាប់ ហើយឆាប់ហ័សផង ។

## ជំពូកទី៤

# សង្គ្រាមទាត់ទឹកដីនៃពួកអឺរ៉ុប
# សៀម-យួន-ភូមា

[ ពីសតវត្សទី ១៦ ដល់សតវត្សទី ១៨ ]

---

១៧- ជាតិយួនដណ្តើមយកប្រទេសចម្ប៉ា ។ ១៨- ជាតិសៀមរាតអំណាចនៅលើឥណ្ឌូចិនភាគកណ្តាល ។ ១៩- ការរាតដណ្តើមទឹកដីនៃពួកព័រទុយកេ អេស្ប៉ាញ៉ុល និងពួកហូឡង់ ។ ២០- សង្គ្រាមរវាងប្រទេសភូមា សៀម និងលាវ ។ ២១- សង្គ្រាមរវាងប្រទេសកម្ពុជា - សៀមនិងយួន ។

---

ពេលដែលប្រទេសកម្ពុជា ប្រទេសចម្ប៉ា ដែលមានធ្លាក់ចុះអន់ថយទៅលើធាតុនយោបាយ ជនជាតិយួន សៀមនិងភូមា បានចាប់ផ្តើមរាតត្បាតអំណាចរបស់ខ្លួនយ៉ាងខ្លាំងក្លា ។ សង្គ្រាមរីករាលនេះ បានទទួលការគាំទ្រចិន

ញុះញង់ពីពួកសេណាធិបតីនិយម ពីរក្សុយកែ អេស្ប៉ា ញ៉ុល ហ្លួឡង់ ដែលពេលនោះបានមកដណ្ដើមត្រួតត្រាទៅភូមិភាគ ប្រជុំកោះនានា រួចស្រេចទៅហើយ ។

## ១៧- ជាតិយួនដណ្ដើមយកប្រទេសចម្ប៉ា

ចក្រភពប្រទេសយួន « ដាយវៀត » ម្ដង ទទួលជ័យជំនះលើជនជាតិចិន ប៉ុងគោល ដែលបានកកកុញក្នុងទៅត្រាំដែនខាងជើងយ៉ាងណាក៏ដោយ ក៏រាជវង្ស ត្រាន ( Tràn ) មិនអាចពង្រីកនូវទំហំដែនដីរបស់ ជនជាតិខ្លួនបានឡើយ ។

ព្រោះពួកក្លុំនៅទ្វីបខាងជើង បានបះបោរយ៉ាង ខ្លាំង ។ ចំណែកជនជាតិចាមនិងជនជាតិលាវក៏បាន ចូលជ្រៀតមិនឈប់ឈរដែរ ដើម្បីដណ្ដើមយកទឹកដី ខ្លះដែលប្រទេសយួនបានទន្ទ្រាន ។ នៅ គ.ស. ១៣០៦ មានការចុះហត្ថលេខាមួយ ដើម្បីសន្តិភាពនៅ

ទីក្រុង ហ្វេ ។ ពោះបីយ៉ាងនេះក្តី សង្គ្រាមនៅតែឆាប ឆេះរោលរាលដល់ចុងភាគខាងកើតដដែល ។

ម៉្យាងទៀតការកេណ្ឌមនុស្សទៅច្បាំង ការដំឡើងពន្ធ ដា បានធ្វើឲ្យប្រជារាស្ត្រយួនមិនសប្បាយចិត្ត ។ នៅពេល គ.ស. ១៣៤៤-៦០ មានការបះបោរមួយយ៉ាងធំ នៃ ប្រជាជនយួននៅតំបន់ដីសណ្ត ដើម្បីប្រឆាំងនឹងស្តេច ត្រាញ់ដែលជិះជាន់រាស្ត្រជាយូរមកហើយ ។

នៅក្នុងកាលៈទេសៈដ៏រើបរំជួលនេះ មានមន្ត្រី យួនម្នាក់ឈ្មោះ ហូគ្វីលី ( Ho Quil Ly ) បានដឹក នាំពលទាប្រឆាំងនឹងរាជវង្ស ត្រាន ដរាបដល់បានជ័យ ជំនះ (១៤០០) ។ ហូគ្វីលី ក្រោយដែលបានក្តាប់យក អំណាចហើយ បានរៀបចំប្រទេសយួនជាថ្មីដោយ ប្រកាសនូវការកែទម្រង់ដីធ្លី ជាពិសេសគឺការរៀបចំ សិក្សាធិការជាតិនិងវប្បធម៌ជាតិទៅតាមសម័យថ្មី ។

ប៉ុន្តែនៅ គ.ស. ១៤០៦ ប្រទេសយួន « ដាយវៀត » បានត្រូវផងជាតិចិនសន្តតិវង្សថ្មីឈ្មោះ មីង (Ming) លុកលុយ ដោយយកលេសថាខឹងជួយរៀបចំសន្តតិវង្ស ត្រាន់ ឲ្យចំរើនឡើងវិញ ។ ពួក «ហ្វូ» បានដាក់អាវុធចុះចាញ់ ហើយការតស៊ូទប់ទល់ចុងក្រោយបន្តស់នៃរាជវង្ស ត្រាន ក៏ត្រូវអស់អំណាច នៅលើប្រទេសយួនដែរ (១៤១៤) ។

បួនឆ្នាំក្រោយមក គឺនៅក្នុង គ.ស. ១៤១៨ ទើបមានមេដឹកនាំថ្មីម្នាក់ឈ្មោះ ឡេឡយ (Lê Loi) មកបង្រួបបង្រួមប្រទេសយួន ឲ្យមានរបៀបឡើងវិញ ។ ដំបូង ឡេឡយ បានបង្កើតពលនានៅ ឡាំសុន ក្បែរថាញហ្វា ដើម្បីរំដោះប្រទេសពីការត្រួតត្រារបស់ចិន ។ រួចហើយទើបមេដឹកនាំនេះ កសាងរាជវង្សមួយថ្មីឈ្មោះ « ឡេ » (១៤២៨) ដើម្បីគ្រប់គ្រងលើវៀតណាមទាំងមូល ។

រាជវង្ស ខ្មែរ បានបំបាត់ចោលជាលើកដំបូងនូវរបប ទាសភាព រៀបចំការកែទម្រង់ផ្សេងៗជំរុញសេដ្ឋកិច្ច ល្អគួរសម ពិសេសគឺកិច្ចដំណើរការផលកសិករជាមួយផ្លូវ ។

ផ្ទុយទៅវិញហើយ បានជាប់ទៅក្នុងរាជ្យ ព្រះបាទអង្គដួង (១៨៤៨-១៨៦០) ប្រទេសវៀតណាម បានស្គាល់នូវឯក ភាពនិងសម្បូណ៌ភាពរុងរឿងដល់កំពូល ។

ពីមុនក្នុងសម័យនេះហើយ ដែលប្រទេសយួនបាន ដណ្ដើមយកទឹកដីតាមតំបន់មួយ ៗ ។ មូលហេតុដែល ជំរុញឲ្យជាតិយួនមិនស្កប់ចិត្តនៅ ហើយចាប់លេបទឹកដី មកពីប្រ- ជាជនយួនមានចំនួនច្រើនលើសលប់ ៗ ក៏ទឹកដីស្រុក ដែលឈមមុខក្នុងឈានានេះច្រើនតែពួកគេកាន់កាប់ ។ ពួក ម្នាក់ៗគ្មានការងារធ្វើ ដែលក៏ទឹកដីបានបញ្ជូនឲ្យជ្រៀតចូល នៅទៅទឹកដីខ្មែរដែលគ្មានជនជាតិយួនរស់នៅ ឬក៏ទៅ ប៉ុន្តែរកការងារជាបញ្ញើក្អែកក្នុងចំណោមអ្នកស្រុកតាម ៗ

ជួនកាលជនជាតិចាម មិនអាចព្រមរស់នៅជាមួយគ្នាបាន ក៏ដកខ្លួនទៅរស់នៅទីទួលខ្ពស់ៗ ។

ជាមួយគ្នានឹងការជ្រៀតចូលបែបនេះ ទំនាស់រវាងចាមនិងយួន នេះតែមានបន្តបន្ទាប់គ្នាក្លាយទៅជាសង្រ្គាមមិនឈប់ឈរ ។ ទីបំផុតនៅក្នុង គ.ស. ១៤៧១ ពួកយួនបានវាយសំរុករហូតដល់ក្រុង វិជ័យ ។ គ្រួសារចាមមួយចំនួនបានរត់ទៅកាន់ប្រទេសម៉ាឡាយូ ខ្លះមកប្រទេសកម្ពុជា ហើយខ្លះទៀតបានរត់ឡើងទៅលើភ្នំធ្វើការតស៊ូជាបន្តទៀត ។ ប្រទេសយួនបានជ័យជំនះលើប្រទេសចម្ប៉ាមែន តែគេទុកឲ្យមានអ្នកគ្រប់គ្រងជាជនជាតិចាមដដែល ។ ក្រៅពីនេះជនជាតិយួនបានត្រួតត្រាលើតំបន់ខ្លះនៃរាជាណាចក្រលាវផង ។

ក្រោយដែល ឡេថាញ់តុង បានសុគតទៅ ស្តេចវង្ស ឡេ ដែលបានបន្តនយោបាយវាតទឹកដីទៀត ។ បាន

អនុវត្តន៍សកទ់គេក ជាហេតុបណ្តាលឲ្យមានការបះបោរ ប្រឆាំងយ៉ាងខ្លាំង ។

នៅដើមសតវត្សទី ១៦ រវាង គ.ស. ១៥៤៧ មានពួកយួនមួយក្រុមឈ្មោះថា ម៉ាក់ (Mac) បានរំលំរាជវង្សឡេ ដើម្បីកាន់អំណាច ។ ប៉ុន្តែនៅ គ.ស ១៥៩២ មានក្រុមមួយទៀតឈ្មោះ ទ្រិញ (Trinh) បានចេញមុខជួយរាជវង្ស ឡេ ដណ្តើមយកអំណាចមកវិញ ។ ក្រោយមកស្តេចត្រាញ់ "ម៉ាក់" បានទៅពឹងមហាអំណាចចិនប៉ងយកជ័យជំនះលើពួក ឡេ ទៀត ។ តែត្រូវពួក ទ្រិញ បង្ក្រាបបានទាំងអស់ ។ នៅពេលជាមួយនេះមានស្តេចត្រាញ់មួយក្រុមទៀតនៅតំបន់ ហ្វេ ឈ្មោះថា ង្វៀង (Nguyèn) ក៏ចេញមុខដណ្តើមអំណាចដែរ ។ ការបះទង្គិចគ្នារវាងគូសត្រូវពីរពួកគឺពួក ង្វៀង និងពួក ទ្រិញ មិនអាចជៀសផុតឡើយ ។ ទីបំផុតគេបានសម្រេចចែក

ប្រទេសយួនជាពីរ គឺប្រទេសយួនខាងជើងនៃស្តេចត្រាញ់ «ទ្រិញ» និងប្រទេសយួនខាងត្បូង នៃស្តេចត្រាញ់ង្វៀង ដោយយកទន្លេ គ្យាញ់ (Glanh) ជាព្រំដែន ។

គឺពួក ង្វៀង នេះហើយ ដែលបានបន្តដំណើរទៅភាគខាងត្បូងទៀត ដើម្បីដណ្តើមយកដែនដីគូ ពីប្រទេសកម្ពុជា ។

## ១៤ ជាតិសៀមទាត់អំណាចលើតំបន់កណ្តាល

ពេលដែលជាតិវៀតណាមកំពុងទាត់អំណាចយ៉ាងពេញទំហឹង ទៅតាមសមុទ្រចិនភាគខាងកើត ជាតិសៀមក៏បានវាយដណ្តើមយកទឹកដីប្រទេសជិតខាង នៅភាគកណ្តាលនៃតំបន់ដែរ ។

ស្តេច រាមាធិបតី ដែលត្រូវជាបុត្រប្រសា នៃក្សត្រ ឈៀងសែន ទាម មួង រ៉ូ-ថោង បានបន្តកិក

ពី រាមាកំហែង ហើយគ្រប់គ្រងប្រទេសសៀម តាំងមូល (១៣៥០) ។ រាជបុត្រ រាមាកំហែង នាម ឮថៃ និង ល្យូថៃ ដែលតាំងនៅក្រុង សុខោទ័យ ក៏បានចំណុះ រាមាធិបតី ដែរ ព្រមតាំងយកក្រុង អយុធ្យា (Ayuthia) ធ្វើជារាជធានីថ្មី ។

សម័យ អយុធ្យា ជាសម័យមួយដ៏រុងរឿងក្នុងប្រវត្តិ-សាស្ត្រនៃជនជាតិសៀម ដែលបានស្គាល់នូវការរីកចំរើនយ៉ាងខ្លាំង ជាពិសេសគឺការចំរើនខាងពាណិជ្ជកម្មសមុទ្រជាមួយប្រទេសជិតខាង ។ ក្នុងរវាង ១៩ ឆ្នាំគឺពី គ.ស. ១៣៥០ ដល់ គ.ស. ១៣៦៩ រាមាធិបតី បានរៀបចំច្បាប់ថ្មីប្រើប្រាស់ក្នុងប្រទេស ដោយស្រង់តាមច្បាប់ដើមនៃជនជាតិសៀមសម័យ "ឈានចៅ" ។ ក្នុងនយោបាយពង្រីកដែនដីស្តេចអង្គនេះ បានបញ្ជាឲ្យលើកទ័ពទៅច្បាំងនឹងប្រទេសកម្ពុជា ។ ប៉ុន្តែចំបាំងនេះមិនបានយូរ

ប៉ុណ្ណោះទេ ពីព្រោះនៅក្នុងក្រុងសៀម មានវត្ថុតូច ៗ ជាច្រើនបានបះបោរប្រឆាំងនឹងស្តេចផែនដី ពិសេសគឺរដ្ឋ សុខោទ័យ ។

ប៉ុន្តែពេលពលប្រឆាំងទាំងប៉ុណ្ណោះ បានត្រូវស្តេច បរមរាជាទី ១ (១៣៧០-៨៧) បង្ក្រាបស្ងប់ស្ងាត់ទៅវិញ ។ ក្រោយដែលស្តេចអង្គនេះសុគតទៅ រាមេសួន ដែលជាកូនប្រុសស្តេច រាមាធិបតី បានឡើងកាន់អំណាច រហូតដល់ គ.ស. ១៣៩៥ ។

នៅដើមសតវត្សទី ១៥ ពិសេសក្នុងរាជ្យបរមរាជាទី២ ដែលបានគ្រប់គ្រងប្រទេសសៀម រហូតមកដល់ គ.ស. ១៤៤៨ ការអនុវត្តនយោបាយពង្រីកទឹកដី បានឈានដល់កំរិតខ្ពស់បំផុត ។ ប្រទេសសៀមបានបើកផ្លូវទៅកាត់សមុទ្រប៉ាសិគាល ដោយដណ្តើមយកភាគខាងជើងនៃឧបទ្វីបម៉ាឡាយូ រួមទាំងទីក្រុង តាវយ មែគ្គីផង មិនតែប៉ុណ្ណោះប្រទេសសៀម

បានវាយដណ្តើមយកខេត្តខ្លះនៃប្រទេសកម្ពុជា ( ១៤៧៦ ) និងក្រុង **ឈៀងម៉ៃ** ភាគខាងជើងនៃប្រទេសឡាវផង ។ **ឈៀងម៉ៃ** ជាក្រុងសំខាន់បំផុត ព្រោះជាច្រកភ្ជាប់ពាណិជ្ជកម្មយ៉ាងសកម្មរវាងប្រទេសចិន ប្រ. ភូមា និងប្រទេសឡាវ **ឡានឆាង** ។

ប្រទេសសៀមមានឯកភាពសុខស្ងាត់ នៅក្នុងរាជ្យស្តេច **បរមត្រៃលោកគណាត់** ( ១៤៤៨.៨៨ ) រីឯសេដ្ឋកិច្ចវប្បធម៌ក៏បានលូតលាស់ចំរើនយ៉ាងខ្លាំងក្លាដែរ ។

លុះមកដល់ដើមសតវត្សទី ១៦ សង្គ្រាមកើតមានឡើងពាសពេញនគរ ពិសេសបណ្តាលមកពីការបះបោរនៅ **ឈៀងម៉ៃ** នេះតែម្តង ។ ពួក **ឈៀងម៉ៃ** បានចូលមកវាយដណ្តើម រហូតដល់ក្រុង **សុខោទ័យ** ( ១៥១៥ ) នៅក្នុងរាជ្យ **រាមាធិបតីទី ២** ( ១៤៩១-១៥២៩ ) តែត្រូវបរាជ័យថយទៅវិញ ហើយប្រកាស

ឯករាជរបស់ខ្លួនដាច់ពីអំណាចសៀម ។ នៅឆ្នាំ ១៥៤៣ ស្ដេចក្រុង ឈៀងម៉ៃ បានត្រូវគេធ្វើគត រួចគ្មានរាជបុត្រសោយរាជ្យស្នងសោះ ។ ពេលនោះក្សត្រលាវនៅ "ឡានឆាង" ក៏បានធ្វើនយោបាយ ដាក់ជំនួសរាជបុត្រមួយអង្គនាម សេដ្ឋាធិរាជ ដោយមានរាជានុសិទ្ធស្រីនាម មហាទេវី ជួយដឹកនាំផង ។

គួរកត់សំគាល់ថាប្រទេសលាវ "ឡានឆាង" បានត្រូវស្ដេចលាវមួយអង្គ នាម "ហ្វាង៉ុំ" បង្រួបបង្រួម គឺនៅ គ.ស. ១៣៥៣ ដោយយក "ហ្លួងប្រាបាង" ធ្វើជារាជធានី ។ ក្សត្រដែលសោយរាជ្យតពី ហ្វាង៉ុំ មកទៀតបានខិតខំពង្រីកអាណាចក្ររបស់ខ្លួនយ៉ាងរឹងប៉ឹង ហើយអាចទប់ទល់ជាមួយនឹងជនជាតិយួន "ដាយវៀត" (១៤៧៦) ទៀតផង ។ ក្រោយមកប្រទេសនេះ បានដណ្ដើមយក ឈៀងម៉ៃ មកគ្រប់គ្រង ។ សេដ្ឋាធិរាជ គ្រងរាជ្យ

ឯ ពេហ្គូវ៉ៃ វិញប៉ុន្មាន ក៏បានយកទ្រព្យមក ហ្លួងប្រាបាង វិញ រីឯពួកនាម៉ឺននៅ ពេហ្គូវ៉ៃ ក៏បានជ្រើសរើសក្សត្រនៃក្រុមជនជាតិ សាន (ភូមា) នាម មេរ៉ុទិ ឲ្យឡើងគ្រងរាជ្យជំនួស ។ វិស្គុបសៀមឃើញដូច្នេះ ក៏បានលើកទ័ពទៅវាយយកក្រុង ពេហ្គូវ៉ៃ តែទទួលបរាជ័យត្រឡប់មកវិញ ។

## ១៩ ការទាតដណ្ដើមទឹកដីនៃពួកព័រទុយហ្គេ អេស្ប៉ាញ៉ុលនិងពួកហូឡង់

នៅខាងដើមសតវត្សរ៍ទី ១៦ ពួក ព័រទុយហ្គេ បានមកដល់ អាស៊ីភាគអាគ្នេយ៍ មុនគេ ក្រោយដែលបានទាក់ទងជាមួយប្រទេស ឥណ្ឌា រួចហើយ ។ គ.ស ១៥០៩ ពួកនេះបានមកដល់ ម៉ាឡាកា រួចបន្តដំណើរ ទៅដល់ប្រជុំកោះ ឥណ្ឌូនេស៊ី ក្នុងបំណងបើកផ្លូវពាណិជ្ជកម្មគ្រឿងទេស ជាមួយបណ្ដាកោះនេះ តែបានជួបប្រទះនឹងការ

បះទង្គិចគ្នាជាមួយពួក អារ៉ាប់ និងពួក ចិន ជាខ្លាំង ។ ដើម្បីសំរេចគោលបំណង ពួកនេះបានបញ្ចូនទូកជាច្រើន ទៅកាន់ប្រទេស ជប៉ុន និងប្រទេសនានានៅឧបទ្វីបឥណ្ឌូចិនមានប្រទេស សៀម ជាដើម ព្រមទាំងបានផ្សាយគ្រិស្តសាសនា ផង ។ គេបានត្រួតត្រាលើកោះ ម៉ូលុក (Moluqucs) រួចដណ្តើមយកកោះ ទែណាត ទីឌ័រ និង អំប៊ិស (Ternate, Tidore, Amboise) ដែលជាមជ្ឈមណ្ឌលខាងផលិតផលគ្រឿងទេស ។

បន្ទាប់ពីការធ្វើដំណើរនៃលោក ម៉ាសេឡង់ មក ពួក អេស្ប៉ាញ៉ុល ក៏បានតាំងអាណានិគមនៅលើកោះ សេប៊ូ (Cebu) ក្នុង គ.ស. ១៥៧១ ព្រមទាំងដណ្តើមយកក្រុង ម៉ានីល និងកោះ មិនដាណាវ នៃប្រទេស ហ្វីលីពីន ក្រោយពីមានការប្រយុទ្ធតស៊ូពីពួកអ្នកស្រុកដើមអស់រយៈពេលជាច្រើនឆ្នាំ ។

ប្រទេស ហ្វីលីពីន ជាប្រទេសទីមួយដែលបានបញ្ចូល ការផ្សាយគ្រិស្តសាសនាច្រើនជាងគេ ដោយមានបង្កើត មហាវិទ្យាល័យ (១៦១១) មុនគេផង ។ ពួក អេស្ប៉ាញ៉ុល ក៏បានទាក់ទង ក្រៅពីប្រទេស ហ្វីលីពីន ជាមួយប្រទេស ខ្មែរ សៀម ចិន និង ជប៉ុន ដែរ ។

ក្នុងការប្រកួតប្រជែងជាមួយ អេស្ប៉ាញ៉ុល ពួក ហូឡង់ ក៏បានពង្រីកឥទ្ធិពលរបស់ខ្លួនមកដល់ប្រជុំ កោះស៊ុង (Ilesde la Sonde) ដោយបានបង្កើតក្រុមហ៊ុន ឈ្មោះ វេ អូ-សេ- VOC (Vorrenigde Oostindèsche-compagnie) ទៀតផង ។ ក្នុងឆ្នាំ ១៦១៩ ពួកហូឡង់ បានបង្កើតក្រុង បាតាវីយ៉ា (Batavia) ដែលជាអនាគត ក្រុង ជាការតា សព្វថ្ងៃ ។ ចាប់តាំងពីក្រុងនេះទៅ ពួក ហូឡង់ បានដណ្តើមយក ម៉ាឡាកា (១៦៤១) ពក អំណាចរហូតដល់កោះ គូរីល (i.e.: Kourlles) នៃប្រ-

ទេស ជប៉ុន (១៦៤៣) និងធ្វើជាម្ចាស់នៃកោះ ម៉ូលុក ( Molluques ) ក្នុងឆ្នាំ ១៦៥៦ រួចកោះ ទេរទៃឡប (១៦៥៧) ធ្វើឲ្យឥទ្ធិពលពួក ព័រទុយហ្គេ ថយចុះយ៉ាងខ្លាំង នៅសល់តែក្រុង ម៉ាកាវ និង ទីម័រ ប៉ុណ្ណោះ ។

ប៉ុន្តែមកដល់សតវត្សទី ១៨ ឧត្តមភាពនៃពួក ហូឡង់ បានថយទៅវិញ នៅចំពោះមុខមហាអំណាច អង់គ្លេស ដែលសម្បូរដោយកងនាវាយ៉ាងច្រើនជាងគេ ។

ដូច្នេះ នៅក្នុងពេលពាក់កណ្ដាលសតវត្សទី ១៦ ពេលដែលប្រទេសសៀម កំពុងរៀបចំប្រទេសឲ្យបានរឹងប៉ឹង ព្រមជាមួយនឹងដំណើរមកដល់នៃពួកអឺរ៉ុប ប្រទេសកម្ពុជាក៏បានស្គាល់ឯកភាពឡើងវិញ ហើយសង្គ្រាមរវាងរដ្ឋកម្ពុជា រដ្ឋសៀម និង លាវ ក្នុងបញ្ហាកតទឹកដី ក៏មិនអាចជៀសផុតបានឡើយ ។

## ២) សង្គ្រាមរវាងប្រទេសភូមា-សៀម និងចិន

ពេលដែលអាណាចក្រ បគាំ បានធ្លាក់ចុះទន់ខ្សោយ ប្រទេសភូមាបានបែងចែកជារដ្ឋ ៣ សំខាន់ៗ ។

រដ្ឋទី ១ - ស្ថិតនៅភាគខាងជើង គ្រប់គ្រងដោយជាតិ សាន ដែលមានរាជធានីតាំងនៅ អាវ៉ា (១៣៦៤)។

រដ្ឋទី ២ - នៅភាគខាងត្បូង ជាដែនដីរបស់ពួក មន ដែលមានរាជធានីតាំងនៅ ប៉េគូ (១៣៦៩) ហើយ ដែលបានភ្ជាប់ធ្វើពាណិជ្ជកម្ម ជាមួយប្រទេសឥណ្ឌា និងជាផ្លូវដឹកនាំលទ្ធិពុទ្ធនិយមពីសិរីលង្កាមកកាន់ឥណ្ឌូចិន ។

រដ្ឋទី ៣ - នៅភាគកណ្ដាល ជាដែនដីគ្រប់គ្រងដោយជាតិភូមាដែលហៅក្រុង ទុង្គូ ជារាជធានី ។ ក្រុងថ្មីនេះបានរីកលូតលាស់យ៉ាងឆាប់រហ័ស ពេលដែលក្រុង អាវ៉ា និងក្រុង ប៉េគូ អន់ថយ ។

នៅក្នុងសតវត្សទី ១៦ ក្រោមការគ្រប់គ្រងនៃស្ដេច មិនក្យិនយ៉ូ (Minkyinyo) ពី ១៤៨៦ ដល់ ១៥៣១ និងកូនប្រុសនាម តាប៊ិនស្វេទី (Tabinshwehti) (១៥៣១-៥០) ពិសេសនៅក្នុងរជ្ជកាលស្ដេច បាយិនណូង (Bayin Naung) (១៥៥១-៨១) ប្រទេសភូមាបានស្គាល់ឯកភាព បន្តិចម្ដងៗឡើង ដោយបានវាយដណ្ដើមយកក្រុង ប៉េហ្គូ (១៥៣៩) ក្រុងម៉ាតាបាន ក្រុងមូលម៉ែន និងក្រុង ប្រូម (១៥៤២) វាយកំចាត់ពួក សាន ពីក្រុងអាវ៉ា និងបង្ក្រាបពួក មន នៅប៉េហ្គូ ដែលធ្វើការបះបោរប្រឆាំងនឹងភូមា ។

គឺចាប់តាំងពីពេលនេះហើយ ដែលសង្គ្រាមដណ្ដើមទឹកដី សឹងសឹកគ្នាទៅវិញទៅមករវាងប្រទេសភូមា ប្រទេសសៀម និង លាវ បានចាប់ផ្ដើមឡើង ។ ក្រោយដែលបានរៀបចំ ប្រទេសប្រកបដោយសេរីភាពហើយ បាយិនណូង បាន លើកទ័ពចូលទៅវាយប្រទេសសៀមសម័យស្ដេច ចក្រពត្តិ

ដើម្បីដណ្ដើមយកក្រុង **ជៀងម៉ៃ** (១៥៥៦) រួច ៨ ឆ្នាំក្រោយមក បានចូលលុកប្រទេសសៀមទៀត រហូតដល់ក្រុង **អយុធ្យា** ព្រមទាំងចាប់ស្ដេច ចក្រពត្តិ ជាឈ្លើយមកប្រទេសភូមាផង ។ ពេលនោះ ជនជាតិសៀម មានសេចក្ដីឈឺចាប់ក្រៃលែង ហើយប៉ុនប៉ង ក្រោកឡើងទប់ទល់នឹងពួកភូមា ដែលចូលមកលុកលុយ ប្រទេស តែត្រូវកងទ័ពភូមាបង្ក្រាបទៅវិញ យ៉ាងសាហាវ ។ ពួកនេះបានចូលលុកទីក្រុង **អយុធ្យា** ជាលើកទីពីរទៀត (១៥៦៩) ដោយបានដុតបំផ្លាញផ្ទះសំបែង និង នាំពួក សៀមជាឈ្លើយរាប់ម៉ឺនសែននាក់ ទៅកាន់ប្រទេសភូមា-ខាងក្រោមទៀតផង ។ ចាប់ពីពេលនោះមក ប្រទេសសៀម បានស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសភូមា អស់រយៈពេល ១៥ ឆ្នាំ ។

ប្រទេសលាវ "**លានឆាង**" ក៏បានទទួលផលអា-

ក្រុមហ៊ុនហោចពីសង្គ្រាមនេះដែរ ព្រោះប្រទេសកម្ពុជាពុំ
គ្រាន់តែលុកលុយប្រទេសសៀមប៉ុណ្ណោះទេ តែវាយប្រ-
ទេសលាវ ដោយបានចូលលុករហូតដល់ក្រុង វៀងច័ន្ទ
(១៨៣៤) ដែលជាកន្លែងទីជួររបស់លាវផង ។ ជួរខ្មែរប្រទេស
លាវបានទៅពឹងប្រទេសកម្ពុជាអស់រយៈពេល ១៧ ឆ្នាំ ។
ពេលនោះស្ដេចលាវនាម ណ្ឌោកែវ ល្បងរំដោះប្រទេស
ឲ្យផុតពីអាណានិគមកម្ពុជាដែរ តែមិនបានសម្រេច ។

ដូច្នេះប្រទេសកម្ពុជាបានកាត់ព្រំដែនយ៉ាងឆ្ងាយបំផុតលាយ
សម្បើម ។ កន្លងទីបើគូរទៅក្រុងថ្មី បានឡើងជាក្រុង
សំខាន់បំផុតនៅភ្នំពេញ ។ អ្នកដំណើរជាតិអឺរ៉ុប ដែល
បានធ្វើការទាក់ទងនៅភ្នំពេញសម័យនោះ បានតាម
ការកម្មណាលើក្រុង ប៉ៃញ៉ូ ក្រៃលែង ។

ថ្វីត្បិតដោយសារសង្គ្រាមជាញឹកញយ ប្រទេស
កម្ពុជាមិនកើតទៀតផុតពីការផុងដាបបានឡើយ ។ ការទាក-

ខានធ្វើស្រែចំការ មកពីការកេណ្ឌមនុស្សទៅធ្វើសង្គ្រាម បណ្ដាលឲ្យមានការក្ដៅក្រហាយយ៉ាងខ្លាំង ។ ក្នុង គ.ស. ១៥៦៧ ទុរ្ភិក្សបានកើតឡើងពេញប្រទេស ។ ជាមួយគ្នានឹងស្ថានការណ៍តានតឹងបែបនេះ ពួក ម៉ន ក៏នាំគ្នាបះបោរ រីឯឈ្លើយសង្គ្រាម មានជាតិ សាន និង ជាតិ សៀម ជាដើម ក៏បានបះបោរម្ដងដែរ ហើយដុតបំផ្លាញក្រុង ប៉េគូ ទាំងមូលផង ។ នន្ទបាយិន ត្រូវជាកូនបុត្រស្ដេច បាយិនណូង បានបង្ក្រាបការបះបោរទាំងនេះ ហើយលើកទ័ពទៅវាយប្រទេសសៀម ចំនួន ២ លើកទៀត តែបានទទួលបរាជ័យយ៉ាងដំណំ ។

ឆ្លៀតពេលដែលប្រទេសភូមាកំពុងមានកង្វល់ ក្នុងស្រុក ប្រទេសសៀមក្រោមការដឹកនាំនៃស្ដេច ព្រនាត-នរេស៊ បានរំដោះខ្លួនពីកណ្ដាប់ដៃភូមា ។ មិនតែប៉ុណ្ណោះ បានលើកទ័ពសងសឹកវាយប្រទេសភូមាផង ។ ស្ដេច

នរេសួរ (១៥៩០-១៦០៥) បានវាយដណ្ដើមយកក្រុង ត: ឃ ដើម្បីភ្ជាប់ផ្លូវជំនួញជាមួយប្រទេសឥណ្ឌានិងយុរ៉ុប ។ គួរកត់សំគាល់ថា ស្ដេចអង្គនេះបានលើកទ័ពទៅកេលុះយកក្រុង លង្វែក នៃប្រទេសកម្ពុជា (១៥៩៤) ដើម្បីបន់យកប្រទេសនេះធ្វើជាខេត្តរបស់សៀមផង ។

នៅក្នុងសតវត្សទី ១៧ ឥណ្ឌូចិនភាគកណ្ដាល និង ភាគខាងលិច បានស្គាល់នូវសន្តិភាពឡើងវិញ ។ ប្រទេសភូមា បានប្ដូររាជធានីពីក្រុង ប៉េគូ ទៅតាំងនៅក្រុង អាវ៉ា ។ ការនេះបានបណ្ដាលឲ្យប្រទេសភូមាពុំសូវមានការលូតលាស់ទេ ព្រោះផ្ដាច់ពីការទាក់ទងខាងពាណិជ្ជកម្មខាងសមុទ្រជាមួយបរទេស ។ ផ្ទុយទៅវិញប្រទេសសៀមបានទាក់ទងខាងផ្លូវជំនួញជាមួយអឺរ៉ុប យ៉ាងជិតស្និតបំផុត ពិសេសគឺប្រទេសបារាំង ប្រទេសហូឡង់ ។ ចំណែកប្រទេសលាវ ក៏បានស្គាល់សន្តិភាពដោយស្ដេច

ស្ដេចលីញ៉ោវវៀងឡាវ ព្រមទាំងបានធ្វើការទាក់ទងជាមួយប្រ-ទេស ផាយវៀត ក្រុមហ៊ុន ហុល្លង់ (Indes néerlandaises) (១៦៤១) ។ ន ៗ

ជនជាតិអឺរ៉ុបទាំង ៣ ដើរតួយ៉ាងសំខាន់ ក្នុងការផ្គត់ផ្គង់សម្ភារៈកាំភ្លើងដល់ពួក ... ហោរទិន្នគុរបដិបក្ខវៀង ។ ខ្ទង់ បណ្ដាលឲ្យភ្លើងសង្គ្រាមនៅតែឆួលឆេះ ដោយពុំចេះឈប់ឈរ ។

ដូច្នេះហើយបានជាមកដល់សតវត្សទី ១៨ សង្គ្រាមបានកើតឡើងវិញ ។ ប្រទេសលាវក្រោយស្ដេច វង្សា សុគតទៅ បានបែកជាបីផ្នែក : ផ្នែកទីមួយតំបន់ ល្វាង-ព្រះបាង នៅខាងជើង ផ្នែកទី ២ តំបន់ វៀងច័ន្ទ ភាគកណ្ដាលនិងផ្នែកទី ៣ តំបន់ ចំប៉ាសក្ដិ ខាងត្បូង ។ តំបន់ទាំងបីនេះ តែងឈ្លោះប្រកែកគ្នាបង្កើតជាសង្គ្រាម ស្រាកជាច្រើនឆ្នាំ ។ ក្រៅពីកាលនេះ ប្រទេសសៀម

ក៏បានចូលមកលុកលុយនៅក្នុង គ.ស. ១៨២៧ ។

រីឯនៅប្រទេសភូមា ពួកមនក៏បានបះបោរម្ដងទៀតដែរ ប៉ុន្តែត្រូវស្ដេច **អាឡោងផាយ៉ា** បង្ក្រាបទៅវិញ ហើយបានធ្វើឲ្យប្រទេសមានឯកភាពជាថ្មីឡើង ។ រាជធានីបានផ្លាស់ពីក្រុង **អាវ៉ា** មកតាំងនៅ **ប៉េគូ** ជាទីដែលប្រទេសភូមាគាប់ចាក់ទន្លេនិងសមុទ្របានស្រួល ។ រាជវង្សនេះបានអនុវត្តនយោបាយវាតទីកដីទៀត ។ នៅក្នុង គ.ស. ១៧៦៧ ប្រទេសភូមា បានចូលទៅកំទេចក្រុង**អយុធ្យា** ព្រមទាំងនាំយកសៀមជាឈ្លើយរាប់ម៉ឺននាក់ទៅប្រទេសភូមាផង ។ ប្រទេសសៀមស្ថិតនៅក្រោមការត្រួតត្រា របស់ជនជាតិភូមាអស់រយៈពេលជាច្រើនឆ្នាំ ។

ប៉ុន្តែ នៅក្នុងប្រទេសសៀម មានមេទ័ពម្នាក់ឈ្មោះ **ផាយ៉ា តាកស៊ីន** បានរំដោះប្រទេសឲ្យផុតពីកណ្ដាប់ដៃភូមា ដោយបណ្ដេញទៅកកងទ័ព នៅទំនាបមេណាម ជ្រែក

ទាន់កើតមាត់សមុទ្រសៀម ដោយមានផនជាតិចិនខ្លះ ផ្សំជាតិសៀមខ្លះផង ហើយដេញកំចាត់ពួកភូមា ចេញពីក្រុង អយុធ្យា គេសជាស្តេចសោយរាជ្យ នៅធុន-បុរី ។ ស្តេច តាក់ស៊ិន បានបង្ក្រាបពួកបះបោរ ទទួលនូវជ័យជំនះគ្រប់ទិសទី ជាហេតុបណ្តាលឲ្យទៅជាឆ្កួត ។

កំណោបផ្តាច់ការរបស់ក្សត្រអង្គនេះ បានធ្វើឲ្យមេទ័ពហានបះបោរប្រឆាំង ។ នៅក្នុង គ.ស. ១៧៨១ មេទ័ពសៀមម្នាក់ឈ្មោះ ចក្រីរាមាទី១ (១៧៨១–១៨០៩) បានដណ្តើមរាជ្យពី តាក់ស៊ីន ហើយគ្រប់គ្រងលើប្រទេសសៀមទាំងមូល ។ គឺស្តេចអង្គនេះហើយដែលបានបង្កើតរាជវង្សក្សត្រសៀមសព្វថ្ងៃ ហើយបានលើករាជធានីពីធុនបុរី មកគង់នៅក្រុង បាំងកក ។ នៅដើមសតវត្សទី ១៩ ប្រទេសសៀម បានស្គាល់ការលូតលាស់ ហើយអនុវត្តនូវនយោបាយរាតត្បាតដី លើប្រទេសភូមា ប្រទេស

ឡាវ ប្រទេសម៉ាឡាយូ ពិសេស លើប្រទេសកម្ពុជា ដែល បានបាត់បង់នូវទឹកដីមួយភាគធំ ។

## ២១- សង្គ្រាមរវាងប្រទេសកម្ពុជា សៀម និងយួន

ក្នុងសង្គ្រាមពង្រីកទឹកដីនៃប្រទេសយួន ប្រទេសសៀម និងប្រទេសភូមាដ៏សាហាវយូរអង្វែងនេះ ប្រទេសកម្ពុជា ដែលពីដើមជាប្រទេសមួយដ៏សំខាន់ នៅអាស៊ីអាគ្នេយ៍ បានទទួលរងគ្រោះ រហូតដល់បាត់បង់ទឹកដីមួយភាគធំ ទៅលើប្រទេសជិតខាង ពិសេសប្រទេសសៀមនិងប្រទេសយួន ។ ប្រជារាស្ត្រខ្មែរបានធ្វើការតស៊ូប្តូរជាជីវិត យ៉ាងស្វិតស្វាញដើម្បីការពារបូរណភាពដែនដីរបស់ខ្លួន ស្ទើរតែអស់មនុស្សពីប្រទេស ។

នៅដើមសតវត្សទី ១៤ ប្រទេសកម្ពុជាទំនងជាមាន កើតការវឹកវរយ៉ាងធំសម្បើម ។ វិបត្តិនៅក្នុងផ្ទៃប្រទេស

បណ្ដាលមកពីការផ្លាស់ប្ដូរសាសនា ដណ្ដើមយកសម្បត្តិ ដំណើរការបះបោរនៃពួកឈ្លើយសង្គ្រាមសៀម បានបណ្ដាលឲ្យប្រទេសកើតអសន្តិសុខ គ្មានរបៀបរៀបរយ ។ ដូច្នេះហើយបានជាស្ដេចសៀម ធាប អ៊ូថោង អាចចូលលុក-លុយក្នុងប្រទេសជាលើកដំបូង - រហូតដល់កំពែងក្រុងអង្គរបានដោយងាយ ។ ស្ដេចខ្មែរ លំពង្សរាជា (១៣៤២-៤៧) ដែលគ្រប់គ្រងក្នុងរាជធានីអង្គរ ក៏បានចូលទិវង្គតក្នុងសង្គ្រាមនោះ ។ រាជធានីបានធ្លាក់ទៅក្នុងកណ្ដាប់សៀម ដោយសៀមបានប្លន់យកទ្រព្យសម្បត្តិមាសប្រាក់ រូបសំណាកព្រះគោគម្ពីរដីកា ព្រមទាំងនាំឈ្លើយកប់ម៉ឺននាក់ទៅប្រទេសសៀមផង ។ ប៉ុន្តែព្រះខាចរាជ្យលះពៃងជ័យបានត្រូវស្ដេច សុរិយោទ័យ រួមជាមួយពួកបក្ខពួកបាកនរក្សាស្ដេច រំដោះវេញបាន ។

ស្ដេចសៀម រាមាធិបតី បានចុះក្រប់អង្គរ ឲ្យ

គ្រប់គ្រងលើក្រុងអង្គរនោះ ប៉ុន្តែរាជបុត្រទី ៣ បានត្រូវប្រជារាស្ត្រខ្មែរដឹកនាំដោយស្តេច សុរិយោទ័យ ធ្វើគត់ នៅក្នុង គ.ស ១៣៥៧ ។ ពុំគ្រាន់តែដេញសៀមឲ្យចេញពីក្រុង អង្គរ ប៉ុណ្ណោះទេ ខ្មែរថែមទាំងលើកទ័ពកំចាត់សៀមពីខេត្តនគររាជ ក្ត ប្រាជិម និង ឧប៊ុន ទៀតផង ។

លុះមកដល់ចុងសតវត្សទី ១៤ ក្រុង អង្គរ បានត្រូវសៀមក្នុងរាជ្យស្តេច រាមាស្វិន ចូលមកឈ្លានពាន លុកលុយម្តងទៀត ។ ឈ្លើយខ្មែរ ៧ ម៉ឺននាក់បានត្រូវសៀមចាប់យកទៅ ហើយស្តេចសៀមបានដាក់រាជបុត្រនាម អង្គពួ ឲ្យសោយរាជលើក្រុងអង្គរ (១៣៩៤) ប៉ុន្តែត្រូវប្រជារាស្ត្រខ្មែរធ្វើគតភ្លាម ៗ ។

ស្តេចសៀមនាម បរមរាជាទី ២ បានលើកទ័ពមកសង្សឹកខ្មែរម្តងទៀត ដើម្បីដណ្តើមយកខេត្តខ្មែរ ភាគខាងលិចទៅគ្រប់គ្រង តម្រូវទៅលើនយោបាយពង្រីកដីរបស់ខ្លួន ។ ក្នុង គ.ស ១៤១៦ ទ័ពសៀមបានព័ទ្ធទីក្រុង

អង្គរជាប់រយៈពេល ៧ ខែ ។ ទីបំផុតដោយមានមន្ត្រីខ្មែរពីរនាក់ចូលដៃនឹងសៀមក្រុងអង្គរក៏ត្រូវសៀមចូលលុកលុយលួចប្លន់ទ្រព្យសម្បត្តិអស់ជាច្រើនឥតគណនា ។ ពញាយ៉ាត មានព្រះជន្ម ១៨ វស្សាទៅហើយ បានគៀសខ្លួនរួចពីកណ្ដាប់សៀម ហើយទៅដឹកនាំប្រជារាស្ត្រនៅតាមខេត្តនានាដើម្បីរៀបចំរំដោះប្រទេស ពីសត្រូវ ។ ក្នុងរយៈពេល ៩ ឆ្នាំទ័ពសៀមបានត្រូវខ្មែរកំចាត់អស់គ្មានសល់ ។

នៅក្នុង គ.ស. ១៤២៧ ស្ដេចអង្គនេះ ក្រោយដែលបានឡើងគ្រងរាជ្យសម្បត្តិជាស្ថាពរលើក្រុងអង្គរ ហើយបានធ្វើយល់ឃើញថា ក្រុងអង្គរនៅជិតក្រុងអយុធ្យាពេក ហើយម្យ៉ាងទៀតនៅខេត្តខាងលិចមិនសូវមានមនុស្សច្រើនអាចជារបាំងជួយការពារផង ក៏បញ្ជាឲ្យចាកចោលក្រុងអង្គរ ទៅតាំងនៅក្រុង ស្រីសន្ធរ ( ១៤៣១ ) រួច « ចតុមុខពការ » ក្រុង ភ្នំពេញ សព្វថ្ងៃ ( ១៤៣៦ )

ការវាយលុកលើក្រុងអង្គរនេះ អាចឲ្យសៀមគ្រប់គ្រងខេត្តខ្មែរភាគខាងជើងនិងខាងលិចបានដោយងាយ ។ ម៉្យាងទៀត រាជបុត្រនិងរាជនត្តាស្តេច ពញាយ៉ាត ដែលបានឡើងសោយរាជបន្តបន្ទាប់មកទៀត បានដណ្តើមរាជសម្បត្តិគ្នារហូតដល់ទៅបែងចែកប្រទេស ជាបីផ្នែក ( ១៤៨០ ):

- ផ្នែកឥសាន (ក្រចេះ ស្ទឹងត្រែង ម្លូព្រៃ) បានទៅ ស្រីសុរិយោព័យ គ្រប់គ្រង ។
- ផ្នែកខាងលិច (បាត់ដំបង អង្គរ ចន្ទបុរី នគររាជ) គ្រប់គ្រងដោយ ស្រីរាជា ។
- ផ្នែកខាងត្បូង (ពីចតុមុខរហូតដល់ព្រៃនគរ) ត្រូវ ធម្មរាជា គ្រប់គ្រង ។

ដើម្បីបានគ្រប់គ្រងលើប្រទេសកម្ពុជាទាំងមូល ធម្ម-រាជា បានទៅពឹងស្តេចសៀមនាម ត្រៃលោកគពភាត់

ឲ្យមកជួយ ។ ទ័ពសៀមបានលើកចូលបកទន្ទ្រានក្រុងអង្គរ
ចន្ទបុរី ជាពីរផ្នែក : ផ្នែកទី ១ មកតាមសមុទ្ររហូតដល់
ពាម ផ្នែកទីពីរតាមផ្លូវខេត្តបាត់ដំបង ។ សៀមចាប់
ស្រីរាជា និង ស្រីសុរិយោទ័យ យកទៅឃុំទុកឯស្រុក
សៀម រួចលើកស្តេច ធម្មរាជា ជាមហាក្សត្រលើប្រ-
ទេសកម្ពុជាតាំងមូល (១៤៨៥-១៥០៤) ។ សៀមអាច
គ្រួតត្រាលើប្រទេសកម្ពុជា ព្រមទាំងយកខេត្ត នគររាជ
ខេត្ត ចន្ទបុរី ភ្ជាប់ទៅក្នុងខេត្តសៀមផង ។

តាំងពីពេលនោះមក ស្តេចខ្មែរត្រូវថ្វាយដំរីស ទៅ
ស្តេចសៀមរៀងរាល់ឆ្នាំ ។ បើពុំបានដង្វាយនេះទេ
សង្គ្រាមមុខជាកើតឡើងរវាងសៀម ខ្មែរមិនខាន ។ ដូច្នេះ
ហើយបានជានៅក្នុងរាជ្យស្តេច អង្គចន្ទទី ១ (១៥២៩-
១៥៦៧) ទ័ពសៀមបានចូលមកកាត់ក្បាលក្រុង លង្វែក
ដោយយកលេសថា អង្គច័ន្ទទី ១ មិនព្រមយក

ដ៏រស់នៅថ្វាយព្រះស្ដេចស្រុកសៀមតាម **ពព្រាពត្តិ** ។ ប៉ុន្តែ ពេលនោះ កងទ័ពខ្មែរបានទប់ទល់យ៉ាងសមរម្យ ត្រាតែបានជ័យជំនះ ព្រមទាំងបានកំទេចទ័ព **អង្គរុង** ដែលជាកូនបុត្រ **ស្រីរាជា** កាលដែលសៀមចាប់យកទៅ ហើយដែលមានបំណងចង់គ្រងគ្រាភាគខាងជើង ប្រទេសកម្ពុជា ក្រោមការឧបត្ថម្ភពីសៀម ។ ពិសេសទៅទៀត នៅគ.ស. ១៥៥៩ ពេលដែលប្រទេសសៀមកំពុងជាប់ដៃធ្វើសង្គ្រាមជាមួយប្រទេសភូមា **អង្គច័ន្ទ** ទ្រង់បញ្ជាឲ្យវាយដណ្ដើមយកខេត្ត **ចន្ទបុរី** និងខេត្ត **នគររាជ** មកវិញ ។

ដើម្បីដោះស្រាយបញ្ហាព្រំដែន ប្រទេសកម្ពុជានិងប្រទេសសៀមបានចុះហត្ថលេខាសម្ពន្ធមិត្តមួយ ។ ក្នុងរជ្ជកាលស្ដេច **បរមរាជាទី ៤** (១៥៦៨ ១៥៧៩) ប្រទេសកម្ពុជាបានទប់ទល់នឹងកងទ័ពលាវ ដែលបានចូលមកវាយលុកនៅភាគខាងជើង ដល់ទៅពីរលើកដែរគឺៈ លើក

ទី ១ គ.ស. ១៥៧៤ លើកទី ២ គ.ស. ១៥៧៨ ប៉ុន្តែ ទ័ពលាវត្រូវបរាជ័យទាំងអស់ ៗ

ប្រទេសសៀម ដែលបានបង់សម្ពន្ធមិត្តនឹងខ្មែរ គឺ ដើម្បីដោះដៃទៅធ្វើសង្គ្រាមនឹងប្រទេសភូមាសិនប៉ុណ្ណោះ ៗ កងទ័ពខ្មែរក្នុងពេលនោះ ក៏បានចូលទៅជួយទ័ពសៀមដែរ ។ ក្រោយដែលបានទទួលជ័យជំនះហើយ ស្ដេចនរេសួរ ក៏បានលើកទ័ពមកសងគុណខ្មែរវិញ ក្នុងរជ្ជស្ដេច សត្ថាទី ១ ឬ មហិន្ទរាជា (១៥៧៩-១៥៩៤) ដោយបាននាំទ័ពចំនួន ១០ ម៉ឺននាក់ មកទន្ទ្រានលើខេត្តបាត់ដំបង ខេត្តពោធិសាត់និងខេត្តអង្គរ ប៉ុន្តែមិនអាចយកក្រុង លង្វែក បានឡើយ ៗ មួយឆ្នាំក្រោយមក សៀមបានលើកទ័ពមកម្ដងទៀតយ៉ាងធំអស្ចារ្យ ដោយវាយយកខេត្តកំពង់ស្វាយ ធ្លងកាត់តាមទន្លេសាប បញ្ចុះបញ្ចូលជាតិចាមសេនៅតាមទន្លេមេគង្គឲ្យបះបោរ ប្រឆាំង

ទឹកដីខ្មែរ ។ ទ័ពសៀមពេលនោះក៏យកជ័យជំនះគ្រប់សមរភូមិទាំងអស់ ។ ទីបំផុតក្នុង គ.ស ១៥៩៤ រាជធានី លង្វែក ក៏ត្រូវទ័ពសៀមព័ទ្ធជាប់ ហើយដុតបំផ្លាញ នាំយកគម្ពីរដីកា អ្នកប្រាជ្ញរាជគ្រូ ទៅស្រុកសៀមអស់គ្មានសល់ ។

ការបាត់បង់បន្ទាយ លង្វែក ជាសញ្ញាមួយ នៃការអាប់ឱនចុះដុនដាបនៃប្រទេសខ្មែរ ។ ចលាចលបានកើតពាសពេញប្រទេស ។ អំណាចគ្រប់យ៉ាងស្ថិតនៅលើកណ្តាប់ដៃសៀមពេញទី ។ គឺក្នុងស្ថានភាពដ៏លំបាកនេះហើយដែលប្រទេសកម្ពុជា បានងាកទៅរកប្រទេសយួន ដើម្បីចងសម្ពន្ធមិត្រជួយកំចាត់សៀមពីប្រទេស និងដើម្បីជាបង្អែកទៅអនាគត ។

នៅពេលនោះ ពី គ.ស. ១៦៦៧ ដល់ គ.ស. ១៦៧៦ នៅស្រុកយួនមានជំទាស់ រវាងពួកយួន

ខាងជើងនិងពួកខាងត្បូងយ៉ាងសាហាវអស្ចារ្យ ។ ក្នុងរឿងនេះរាជវង្ស **ង្វៀង** ដែលបានត្រួតត្រា នៅភាគខាងត្បូង ( រាជធានីនៅហ្វេ ) មានបំណង ចង់ចងមិត្តនឹងខ្មែរដែរ ។ ដូច្នេះហើយបានជាស្តេចក្រុង **អាណាម** បានរៀបចំអភិសេកបុត្រីខាប់ **អង្គចូវ** មកជាអគ្គមហេសីស្តេច **ជ័យជេដ្ឋាទី ២** ។ រាជធានីត្រូវលើកទៅតាំងនៅ **ឧដុង្គមានជ័យ** ។

ដោយសារសម្ពន្ធមិត្រយួន **ជ័យជេដ្ឋាទី ២** អាចទប់ទល់នឹងកងទ័ពសៀម ដែលបានចូលមកពីរលើក គឺលើកទី ១ នៅក្នុង គ.ស. ១៦២១ និងលើកទី ២ នៅ គ.ស. ១៦២៣ ។ ប៉ុន្តែគេយល់ថាសម្ពន្ធមិត្តជាមួយជាតិយួន បណ្តាលឲ្យមានគ្រោះថ្នាក់ទៅវិញ ព្រោះនៅឆ្នាំ គ.ស. ១៦២៣ មានរាជទូតក្រុងហ្វេ បានមកដល់ក្រុង **ឧដុង្គ** ដើម្បីសុំច្បាប់ប្រកបកសិកម្ម និងពាណិជ្ជកម្ម

នៅតំបន់ ព្រៃនគរ ។ ក្នុងបញ្ហានេះដោយអគ្គមហេសី អង្គច្រូវ បានជួយសុំផងនោះ ជ័យជេដ្ឋាទី ២ ក៏បាន យល់ព្រមតាម ។ គឺចាប់តាំងពីពេលនេះហើយដែលជនជាតិយួនបានជ្រៀតចូលមកជាច្រើន រស់នៅក្នុងចំណោមប្រជាជនខ្មែរ ។

ក្រោយដែល ជ័យជេដ្ឋាទី ២ សុគតទៅ (១៦២៨) មានការវិវាទគ្នាយ៉ាងខ្លាំងរវាងរាជបុត្រនិងអនុជបណ្ដាលឲ្យមានការព្យាបាទធ្វើគតស្ដេចឡើងសោយរាជបន្តបន្ទាប់គ្នា ៗ ក្នុងរឿងនេះមានអន្តរាគមន៍ពីពួកព័រទុយហ្គេ និងពួកបារាំងផង ។ ទីបំផុតនៅក្នុង គ.ស. ១៦៤២ រាជបុត្រ ជ័យជេដ្ឋាទី ២ នាម អង្គចន្ទ បានដណ្ដើមយកអំណាចបាន ។

ក្សត្រអង្គនេះ បានរៀបអភិសេកជាមួយស្រីចាម រួចចូលជាតិឥស្លាម ដូរឈ្មោះហើយបានជាមាននាមជា ចន្ទបុល-

សាស្ត្រ ។ គួរកត់សំគាល់ថា ជនជាតិយាមមិនដែលដាក់ថា ដែលរត់គេចពីការរុករាននៃជាតិយួន មានចំនួនច្រើន ណាស់ក្នុងប្រទេសកម្ពុជា តាមដងទន្លេមេគង្គមិនទៅត្បូង ឃុំជាដើម ។ ពួកនេះតែងទទួលការប្រោសប្រណីពី **អង្គច័ន្ទក្នុងសាស្ត្រ** ជាមិត្ត ។ មានខ្លះបានឡើងជាមន្ត្រី ប៉ុន្មានដងៗ ។ ក្សត្រខ្មែរខ្លះ ឃើញស្ដេចនោះមិនពេញចិត្តក៏ ដោះបំបាត់ប្រជាករស្ដ្រឲ្យប្រឆាំងនឹងស្ដេច ។

ឆ្លៀតឱកាសនេះក្សត្រ **អង្គអុំ** បានសុំស្ដេចយួន តេណាមខាម **ហ្វេវឿង** ( Hué Vuong) ឲ្យមកជួយការ ការ ។ ស្ដេចអាណាមដែលមានបំណងចង់ពង្រីក អាណាចក្រយួនដែរនោះ ក៏បានបញ្ជូនកងទ័ពយួនមក ប៉ះនឹងច្រើនហួតដល់ដីសណ្តនៃទន្លេមេគង្គ ដោយមាន មេទ័ពម្នាក់ឈ្មោះ **ភូយ យេន** ( phu yen ) ជាមេ បញ្ជាការ ។ សង្គ្រាមរវាងខ្មែរ-យួនក៏បានផ្ទុះឡើងទៅ

ក្នុង គ.ស ១៦៥៨ ។ **អង្គចន្ទពុលសាស្ត្រ** ត្រូវមេទ័ព **វ្ញយ-យៀន** ចាប់យកទៅស្រុកយួន ប៉ុន្តែត្រូវបានស្តេចយួនដោះលែងមកវិញ ដោយបានយល់ព្រមប្រគល់តំបន់ **ព្រៃនគរ** និង **បៀនហ្វា** ទៅជាទឹកដីយួន ។

ចាប់តាំងពីពេលនេះ ប្រទេសកម្ពុជាបានជួបនឹងព្យុះការណ៍ដ៏សែនច្របូកច្របល់ ។ ស្តេចខ្មែរដែលបានឡើងសោយរាជ្យតមកទៀត មិនអាចគង់នៅបានយូរឡើយ ។

—

នៅក្នុង គ.ស. ១៦៨០ មានហេតុការណ៍មួយបណ្តាលមកពីអ្នកចំណោលស្រុកជាតិចិនជាច្រើន ដែលបានគេចចេញពីការត្រួតត្រានៃសន្តតិវង្សថ្មី ឈ្មោះ **ម៉ាន់ជូ** (Mandchous) ។ ពួកចិនខ្លះបានមកដល់តំបន់ **ពាមឡឿង** ក្រោមការដឹកនាំនៃ **ម៉ាកគឺ** (Mac cuu) ហើយបានអនុញ្ញាតពីស្តេចប្រទេសកម្ពុជាផង ។ ខ្លះទៀតបានសុំចត

សំពៅទៅតំបន់ ទូរ៉ាន ត្រូវស្តេច ញៀនវឿង បញ្ជូនមក
រស់នៅក្នុងតំបន់ព្រៃនគរ ។ គឺជនជាតិចិននេះហើយ
ដែលនាំគ្នាប្រួចសំកប់ដណ្តើមយកទឹកដីខ្មែរ ។

ក្នុងរជ្ជស្តេច ជ័យជេដ្ឋាទី ២ ( ១៦៧៣-១៧០៦ ) ទ័ពយួនបានចូលមកក្នុងប្រទេសកម្ពុជា រហូតដល់ទីក្រុងភ្នំពេញ តែត្រូវប្រជាករស្តេចខ្មែរវាយរុញច្រានទៅវិញ ។ ពេលនោះទ័ពយួនបានតាំងទីបញ្ជាការនៅតំបន់ ធៀវៀ ព្រៃនគរ យ៉ាងមាំដែលគ្មានកងទ័ពខ្មែរ អាចដេញកំចាត់បានឡើយ ។

ក្នុង គ.ស. ១៧០៨ មានពួកជនចិន ម៉ាកគ្វ មួយក្រុមបានមកសុំជ្រកកោនក្នុងប្រទេសកម្ពុជាហើយធ្វើការបះបោរយ៉ាងខ្លាំង ។ ដើម្បីទប់ទល់នឹងការបះបោរនេះសម្តេច កែវហ្វាទី៣ ( ១៧១០-១៧២២ ) បានទៅពឹង កងទ័ពយួនឲ្យមកជួយ ។ ពេលនោះកងទ័ពសៀមក៏មកដល់

ដែរ ៗ ដើម្បីជៀសវាងទឹងសង្គ្រាម ពែរប៉ារអ៊ីប តាម នាំផ្កាយផ្កាមាសផ្កាប្រាក់ ទៅថ្វាយស្តេចវៀតដែលជា សញ្ញានៃការចុះចូល ៗ

មានជនជាតិលាវម្នាក់ទៀត តាំងខ្លួនជាព្រះពុទ្ធបានបះ-បះបោរ ប្រឆាំងស្តេចខ្មែរ (១៧៣០) ដើម្បីកំចាត់យួនឲ្យ ចេញពីប្រទេស ... ៗ អធិកផកណ្តាំមពីកេត យ៉ាងខ្លាំង ហើយបញ្ជាឲ្យលើកទ័ពមកសង្សឹក ព្រមទាំងតាំងទ័ព លើខេត្ត រិញបុរី បីថ្ងៃ ហូតដល់ បាពៃព្រៃ សុព្រ-ត្រាង ៗ

ដូច្នេះរាល់មួយសតវត្សប៉ុណ្ណោះ ជាតិយួនបានទៅជា ម្ចាស់ទឹកដីខ្មែរ តំបន់កូសាំងស៊ុនសព្វថ្ងៃ ៗ គេមានបំណង ទឹងយកប្រទេសខ្មែរទាំងមូល តែចំពេលនោះមានការ បះបោរពីពួក តៃសឺន ( Tay-Son ) ៗ

ការបះបោរនេះកើតឡើងនៅក្នុង គ.ស. ១៧៧៣

ដោយមេដឹកនាំបងប្អូនបីនាក់ ។ ពួកនេះ បានធ្វើគត់ស្តេច អាណាម វ៉ូវឿង ( Vo-vuong ) ។ **ង្វៀងអាញ់** ដែលប្រុសសោយរាជ្យស្នង បានភៀសខ្លួនទៅកូសាំងស៊ីន ។ នៅក្នុង គ.ស. ១៧៨៣ ដោយមានពួកចិនទៅកូសាំងស៊ីន និងពួកពរទុយហ្គេ ផ្តល់អាវុធជួយឧបត្ថម្ភផង **ង្វៀងអាញ់** ក៏បានធ្វើការតស៊ូតបតនឹងពួក **តៃសឺន** វិញ ។ តែមិនបានសំរេចហើយភៀសខ្លួនទៅគង់នៅប្រទេសសៀម ។ ពួក **តៃសឺន** បានដណ្តើមយកក្រុង **ហ្វេ** កំចាត់ពួក **ទ្រិញ** ហើយវាយយកក្រុង **ហាណូយ** ថែមទៀត (១៧៨៦) ព្រមទាំងបានដាក់ស្តេចមួយអង្គឲ្យសោយរាជ្យទីនោះ នាមថា **ង្វៀងវ៉ាន់ហ្វេ** រហូតមកដល់ គ.ស. (១៧៩០) ។

ក្នុងរយៈពេលនេះផងជាតិយួន មិនបានឈានចូលមក កៀរទឹកដីខ្មែរ នៅព្រំដែនខាងកើតទេ តែទៅព្រំដែនខាងលិចវិញ ស្តេចសៀម **ចក្រីរាជាទី ១** ក្រោយដែល

ប៉ុន្តែដោះខ្លួនពីប្រទេសសក្ដមហើយ បានពញាច័ក្រលើកទ័ព មកវាយខ្មែរដើម្បីយកស្រុកខ្មែរធ្វើជាចំណុះរបស់សៀម ។ នៅក្នុងពេលនោះមន្ត្រីខ្មែរបីនាក់ ឈ្មោះ ឬ ស៊ី ម៉ង់ ប៉ែន បះបោរហើយសម្លាប់គ្នាជាបន្តបន្ទាប់ ដើម្បីដណ្តើមរាជសម្បត្តិ ។ មន្ត្រី ប៉ែន បានជ័យជំនះ ហើយភៀសខ្លួនទៅកាន់ប្រទេសសៀមជាមួយ អង្គអេង ដើម្បីសុំសេចក្តីអនុញ្ញាតឡើងគ្រងរាជ្យពីស្តេចសៀម ។ ទីតាំងសៀមក្រោមបញ្ជាការរបស់ ប៉ែន ក៏បានមកកាន់នៅខេត្ត បាត់ដំបង និងខេត្ត អង្គរ ។ ក្រោយដែល អង្គអេង បានសុគត ទៅរាជបុត្រនាម អង្គច័ន្ទទី ២ (១៨០៦-៣៤) បានសោយរាជ្យស្នងក្រោមការអនុញ្ញាតនៃស្តេចសៀមផង ។

ព្រឹត្តិការណ៍នេះបានធ្វើឲ្យអធិរាជអាណាម មានការព្រួយបារម្ភយ៉ាងខ្លាំង ។ ស្តេច ង្វៀងអាញ់ ដែលបានភៀសខ្លួនទៅកាន់ប្រទេសសៀម បានត្រឡប់មកកាន់

ប្រទេសយួន ហើយដណ្ដើមយកអំណាចពីពួក តៃសឺន ដោយមានព្រះសង្ឃ កាតូលិក អាដ្រង់ (Eveque d' Adran) ជួយផ្ដល់គ្រឿងសាវុធផង ។ ង្វៀងអាញ់ បានប្រកាសជាស្ដេចដអាណាម មាននាមថា យ៉ាឡុង (Gia-Long) នៅ គ.ស. ១៨០២ ។ នៅចំពោះមុខអំណាចដ៏ខ្លាំងក្លានៃក្រុងអាណាម អង្គចន្ទទី ២ បាននាំផ្កាយទៅថ្វាយជាសញ្ញានៃការចុះចូល ។ ស្ដេចសៀមឃើញដូច្នោះ ក៏បញ្ជាឲ្យលើកទ័ពចូលលុកប្រទេសកម្ពុជាភ្លាម ប៉ុន្តែត្រូវត្រូវទ័ព យ៉ាឡុង កំចាត់ឲ្យចេញទៅវិញ ។ ពេលដែលបានជោគជ័យ ទ័ពសៀមបានត្រួតត្រាលើខេត្តខ្មែរជាច្រើន ដូចជាខេត្ត ស្ទឹងត្រែង ទន្លេរពៅ មូលព្រៃ ពិសេសខេត្ត សៀមរាប បាត់ដំបង និង ស៊ីសុផុន ។ នៅក្នុង គ.ស. ១៨៣៦ ទ័ពសៀមផ្ទុះទៀត ក្រោមបញ្ជាការនៃមេទ័ព បូឌិន បានលុកលុយប្រទេសកម្ពុជា តាំងពីទី

ក្រុង ឧដុង្គ រហូតដល់ បាត់ជ្រំ និង វិញឡុង ប៉ុន្តែត្រូវទ័ពយួនទប់ជាប់ ហើយក៏រុញច្រានត្រឡប់មកវិញ ក្រោមបញ្ជាការនៃមេទ័ព ត្រឿងមិញយ៉ាង ។ ពេលចូលមកដល់ប្រទេសកម្ពុជាហើយ មេទ័ពយួននេះបានដណ្តើមអំណាចខ្មែរមកត្រួតត្រា ចាប់បញ្ជូនក្សត្រី អង្គមី ទៅឃុំនៅអាណាម បញ្ជាឲ្យមន្ត្រីខ្មែរស្លៀកពាក់ដូចភាសាតាមយួន ព្រមទាំងផុតបំផ្លាញវត្តអារាមខ្មែរផង ។ នៅចំពោះអំពើដ៏ឃោរឃៅនេះ ប្រជាកសិករខ្មែរបានបះឡើង ហើយសម្លាប់យួនក្នុងស្រុក អស់គ្មានសល់ ។ នាម៉ឺនសព្វមុខមន្ត្រីក៏បានទៅយាង អង្គឌួង ពីប្រទេសសៀមមកគ្រប់គ្រងលើរាជាណាចក្រកម្ពុជា គ.ស. ១៨៤៧ ។

សន្តិភាពបានកើតឡើងវិញខ្លះ ដោយសៀមនិងយួនបានព្រមព្រៀងគ្នាធ្វើជាមេបាលើប្រទេសកម្ពុជា ។ ម៉្យាងទៀតអន្តរាគមន៍នៃពួកអឺរ៉ុប មានជនជាតិបារាំងនិង

អង់គ្លេសជាដើមបានបង្អាក់ដំណើររីកចំរើន នៃប្រទេស សៀមនិងយួននៅលើឥណ្ឌូចិន ។

មកដល់ទីសតវត្សទី ១៨ នេះ ដែនដីអាស៊ីអា-គ្នេយ៍មួយភាគ បានស្ថិតនៅក្រោមការត្រួតត្រារបស់ អាណានិគមអឺរ៉ុប ព័រទុយហ្គេ អេស្ប៉ាញ៉ុល ហូឡង់ រួចស្រេចទៅហើយ ។ រីឯរដ្ឋទាំងឡាយនៅឧបទ្វីប ឥណ្ឌូចិន ពិតមែនតែពួកអឺរ៉ុប មិនទាន់វាយដណ្តើមយកបាន ហើយក៏ដោយ តែស្ថិតនៅក្នុងការហែកហួរច្បាំងដណ្តើម គ្នាឥតឈប់ឈរ ដើម្បីពង្រីកអំណាចត្រួតត្រារបស់ខ្លួន ៗ ក្នុងសង្គ្រាមបំផ្លិចបំផ្លាញដ៏សាហាវ ដែលកើតមានឡើង តាំងពីសតវត្សទី ១៤ មកនោះ បានបណ្តាលឲ្យរដ្ឋមន និង ចម្ប៉ា ត្រូវបាត់បង់ពីផែនទីពិភពលោក ដោយមានរដ្ឋ ក្រុមសៀមនិងយួនជំនួសវិញ ។ ក្នុងបណ្តាប្រទេសទាំង ទាំងឡាយ មានតែប្រទេសកម្ពុជាមួយទេ ដែលរស់

បានមានជីវិតក្នុងព្រំដែន ដ៏គួរឲបង្អៀត សេសសល់ពីការលេបត្របាក់បន្តិចម្តងៗ ពីសំណាក់អាណានិគមនិយមសៀមនិងយួនមកលើព្រំដែនខាងលិចនិងកើត ។

# សេចក្តីបញ្ចប់

សេចក្តីបរិយាយដូចបានរៀបរាប់មកហើយនេះ បានបង្ហាញឲ្យឃើញនូវកំណើតនៃវត្តទាំងឡាយ ព្រមទាំងអារ្យធម៌រឿង ៗ ខ្លួន ដែលបានបដិសន្ធិឡើងប្រកបដោយកំលាំងខ្លាំងក្លាក្រៃ នៅលើដីសណ្ត ឬ តំបន់ឆ្នេរសមុទ្រនៃដែនដីអាស៊ីអាគ្នេយ៍ ៗ ព្រោះចំកន្លែងនេះហើយដែលគេអាចបង្កើនផ្ទៃក្រឡាដីដាំដំណាំ ជីកព្រែកប្រឡាយសំរាប់បាចទឹកបញ្ចូលស្រែ សំរាប់ការលូតលាស់ខាងវិស័យសេដ្ឋកិច្ច ខាងកំណើនចំនួនមនុស្ស និង ភាពរុងរឿងនៃអារ្យធម៌ ។

អារ្យធម៌ទាំងនោះ ច្រើនទទួលឥទ្ធិពលពីប្រទេសឥណ្ឌា ហើយបានស្គាល់ការរុងរឿងរហូតដល់សតវត្សទី ១៣ លើកលែងតែប្រទេសយៀកណាមចេញ ព្រោះបានពាក់ព័ន្ធនឹងអារ្យធម៌ចិន ច្រើន ។ ផ្ទុយទៅវិញអារ្យ

ផលិតផល និងសៀវភៅ ណាស់ ក៏ត្រូវតែមានលើប្លង់ផ្សព្វផ្សាយទំនិញ យ៉ាងណា ក៏មានការផ្លាស់ប្តូរលាយឡំគ្នា ជាមួយអរិយធម៌ ខ្មែរ បារាំង អាមេរិក ជប៉ុន បង្កើតជាអរិយធម៌មួយថ្មី ចាប់តាំងពី សតវត្សទី ៤ រហូតមកដល់សតវត្សទី ១៩ គឺនៅមុនពេល ដែលអឺរ៉ុបចាប់ផ្តើមរុករកអាណានិគមមកដល់ ។ សង្គ្រាមលោក សតវត្សនេះ ក៏បញ្ចប់នៅក្នុងភាពនេះ ជាកត្តាចម្បង ដែល បានជំរុញឲ្យមានការផ្លាស់ប្តូរលាយឡំគ្នាបែបនេះ ។

ការផ្លាស់ប្តូរបញ្ចូលប្រែ មានតួនាទីមិនគ្រាន់តែក្នុងវិស័យ សេដ្ឋកិច្ចប៉ុណ្ណោះទេ តែមានសារៈសំខាន់ខាងផ្នែក សង្គម កិច្ច និងនយោបាយដែរ ។ ព្រោះការទំនាក់ទំនងដែលជួបប្រ- ទ្បាយ ជាភ្ញៀវ បានបង្កើតឲ្យមានមនុស្សការជាតិឯក- ភាព និងក៏ការពារពលរដ្ឋផង ដែលអាចចូលរួមក្នុងការរុក- រកយកធនធានធម្មជាតិរបស់ខ្លួនបាន ។ ម្យ៉ាងទៀតការផ្លាស់ ប្តូរបញ្ចូលប្រែ បានជំរុញឲ្យមានការជាតិនិយម សន្តិភាព

ផ្តាច់ការ ព្រមជាមួយនឹងការបះបោរប្រឆាំងនឹងស្តេចផែនដីជានិច្ចជាកាល ពីសំណាក់កសិករនានាផង ។ ព្រោះពពួកកសិករដែលជាអ្នកបង្កើតផល មិនអាចទ្រាំទ្រនឹងពន្ធដា និងកំណែនគ្រប់បែប ដោយកាត់តាំងកំណែនទៅធ្វើបម្រើផង ។ ការបះបោរនៃប្រជារាស្ត្រ ដែលមិនបានមានមេនាំគម្រប់ផ្លូវនយោបាយច្បាស់លាស់នេះ តែងជួបប្រទះនឹងបរាជ័យជានិច្ច មិនតែប៉ុណ្ណោះថែមទាំងត្រូវពួកនិយមស័ក្តិភូមិតែតែមានកំលាំងខ្លាំងក្លា. ហើយធ្វើបាបកាប់សំលាប់រាស្ត្រ ធ្វើឲ្យពួកនេះក្លាយទៅជាទាសៈទាសី សំរាប់ស្តេចផង ។ គឺពួកជនជំពូកនេះហើយដែលគេកេណ្ឌឲ្យទៅសង់ប្រាសាទអង្គរ ប្រាសាទបូរ៉ូប៊ូឌួវិហារនៅក្រុងអយុធ្យា និងនៅក្រុងវ៉ង់គួន ឬសង់វាំងប្រាសាទដ៏ល្អប្រណិតសំរាប់ស្តេច និងមន្ត្រីធំៗ ។

ហេតុការណ៍ដែលកើតមាន៖ នៅអាស៊ីអាគ្នេយ៍

បែបនេះ មិនអាចធ្វើឲ្យប្រទេសស្គាល់នូវការរុងរឿង រហូតទេ ថ្វីត្បិតតែមានការទាក់ទងខាងពាណិជ្ជកម្មជា អន្តរជាតិ ជាមួយប្រទេសចិន ឥណ្ឌា បស្ចិមប្រទេស យ៉ាងណាក៏ដោយ ព្រោះរដ្ឋទាំងនោះ ដំបូងបានលូត លាស់ធាត់ធំឡើងដល់កំពូល រួចទន់ខ្សោយចុះទៅវិញ ៗ មានរដ្ឋខ្លះទៀតដួលជា ចាម្ប៉ា បន ជាដើម បានបាត់ សូន្យតែម្ដងនៅចំពោះកណ្ដាលសក្ដិនៃរដ្ឋថ្មី ៗ មានរដ្ឋ យួន សៀម លាវ និង ភូមា ៗ ក្នុងចំណោម រដ្ឋទាំងអស់នេះគ្មានប្រទេសណាមួយ ដែលអាចបង្កើត វណ្ណៈ មូលធនគហបតី (Bourgeoisie) ដូចនៅអឺរ៉ុប ខាងចុងបង្ហើយសម័យទេ ព្រោះតែខ្វះការប្រមូលទុកមូល ធននានា មកពីសេដ្ឋកិច្ចមានលក្ខណៈ ជាសេដ្ឋកិច្ចធម្មជាតិ (économie naturelle) មិនមែនជាសេដ្ឋកិច្ចរូបិយវត្ថុ (économie monétaire) និងមកតែពីការគាបសង្កត់ខាង

ប្រើផ្លូវកិច្ចពីសំណាក់វណ្ណៈសក្តិភូមិទេះឯង ។ ម្យ៉ាងទៀត ឆន្ទានទ្រព្យសម្បត្តិទាំងប៉ុន្មានត្រូវចំណាយ សំរាប់តែកសាងប្រាសាទព្រះវិហារទិនកំនែស្ដេច អស់មួយភាគធំទៅហើយ ។ ដូច្នេះមកទល់និងសតវត្សទី ១៦ ទើបអង្គរមានល្បឿន ខាងស្តារៈយឺតជាងទ្វីបអាស៊ីជាច្រើន តែចាប់តាំងពីសតវត្សទី ១៧ ១៨ ១៩ អង្គរមានសន្ទុះលឿនជាងទៅវិញ អាស្រ័យដោយសារមានការបដិវត្តខាងឧស្សាហកម្ម រីឯទ្វីបអាស៊ីក៏ស្ថិតនៅទីជ្រុលក្នុងវិស័យ ជាព្រោះសក្តិភូមិជាក់ជានិរន្តរ៍ដដែរ ។

# កាលបពង្សាវលី

៤០-២៣០ មុន គ.ស : ចិន, សម័យរាជាណាចក្រប្រយុទ្ធគ្នា ។

២៣០ ២០៦ មុន គ.ស. : ចិន; សន្តតិវង្ស ស៊ីន ។

២២១ មុន គ.ស. : ចិន, សម័យស្តេចស៊ីនឆេហ្វាងទី ។

៣២៦ មុន គ.ស. : ឥណ្ឌា, ស្តេចក្រិកអាឡិកសង់ឌ្រ៍ មក ដល់ប្រទេសឥណ្ឌា ។

៣២៥-១៨៥ មុន គ.ស. : ឥណ្ឌា, សម័យសន្តតិវង្ស ម៉ូរិយៈ ។

២៧៤-២៣៦ មុន គ.ស. : ឥណ្ឌា, រជ្ជកាលស្តេចអាសោក ។

២០៦ មុន គ.ស. - ២២០ : ចិន, សម័យសន្តតិវង្ស

២២១ ក្រោយ គ.ស. : ហាន ។

១៧៤ មុន គ.ស. – ដល់ : ឥណ្ឌា, ក្រោមការត្រួតត្រា

២៤២ ក្រោយ គ.ស. : នៃពួកសុគន្ធពួកគូសង់ ។

១២៨ មុន គ.ស. : គូមា, ចិនបើក "ផ្លូវគូមា" ។

១១១ មុន គ.ស. : យៀកណាម, ចិនត្រួតត្រា

: តំបន់យួនណាំវៀត ។

១-១០០ នៃគ.ស, : ឥណ្ឌានិយកម្មដំបូងមកលើ

: អាស៊ីភាគអាគ្នេយ៍ ។

៥០ : កម្ពុជា, កំណើតកេណ្ឌាំ

ចក្រភ្នំ ។

១៤៤–១៧២ : ឥណ្ឌា, រជ្ជកាលស្តេច

កនិស្ក ។

១៩២ : កំណើតលិនយីនៃប្រទេស

ចម្ប៉ា ។

២២១ ២៨០ : ចិន, សម័យអាណាចក្រទាំង ៣ ។

២២៥ កម្ពុជា, ស្តេចភ្នំ ហ្វាន់ចេម៉ន សុគត ។

២៤៣ : កម្ពុជា, បញ្ជូនកងទូតទៅប្រទេស ចិន ។

២៥០ : កូហ, កំណើត អាណាចក្រក្រុស : នៅអ៊ីកាតៃ ។

២៧០–២៨១ : ចាមវាយលុកយួនគាវឈឺ ។

២៧០-៧០០ : ឥណ្ឌា , សន្តតិវង្ស គុប្ត ។

២៨០-៥៨៩ : ចិន, សន្តតិវង្ស ស៊ុី ។

៣៥៧ : កម្ពុជា, រជ្ជកាលស្តេច ចាន់ តាន់ ។

៤៤៦ : សេនាបតីចិន តាហូជីវាយលុកចម្ប៉ា ។

៤៨៤ . កម្ពុជា, ស្តេចកៅណ្ឌិន្យជ័យវរ្ម័ន បញ្ជូនព្រះសង្ឃនាគសេន ទៅ ប្រទេសចិន ។

៤៤៦ : ស្តេចចិនឲ្យគរវរ៉ម លើកទ័ព វាយក្រុង នគរភ្នំ ។

៦០៥ : សេនាបតីចិន លីវហ្វាង វាយលុកចម្ប៉ា ។

៦១៦ : កម្ពុជា, ទូតទី ១ នៃស្តេចឥសានវរ្ម័នទៅ គាល់ប្រទេសចិន ។

រវាង ៦៥០ : កម្ពុជា, លើករាជធានីមកតាំងនៅអង្គរបុរី ។

: ភូមា, អាណាចក្រ ស្រីក្សេត្រ ។

: ថៃ, វឌ្ឍនភាពនៃអាណាចក្រទ្វារាវតី ។

: ចម្ប៉ា, កំណើត មីសឺន ។

៥៨៩-៦១៨ : ចិន, សន្តតិវង្ស ស៊ុយ ។

៦១៨-៩០៧ : ចិន, សន្តតិវង្ស ថង់ ។

៧០០-១៥២៦ : ឥណ្ឌា, ក្រោមការត្រួតត្រារបស់ពួក ម៉ុយស៊ុលម៉ង់ ។

៧០០ : ឥណ្ឌូនេស៊ី, ខាងដើមនៃអាណាចក្រ

ស្រីវិជ័យនៅស៊ុមាត្រា ។

: ភូមា, ប្រាសាទពុទ្ធសាសនានៅព្រូមេ ។

: ថៃ, កំណើតអាណាចក្រណភារៈទៅ ។

៧៦០ : កម្ពុជា, ចែកជាកម្ពុជា ទឹកលិច និង កម្ពុជាដីគោក ។

៧៥០ : ឥណ្ឌូនេស៊ី, ការកសាងសន្តតិវង្សសៃល្រ្ទា នៅកោះជ្វា ។

៧៧៧-៧៨ : ពួកជ្វាគ្រួតគ្រា លើចិនម្ចាទឹកលិច និងលើឆ្នេរសមុទ្រឥណ្ឌូចិន ។

៧៧៦,៧៨ : ឥណ្ឌូនេស៊ី, កសាងប្រាសាទ បូរ៉ូប៊ូឌួ នៅកោះជ្វា ។

៧៨០ : ទឹពតាម ចូលមកចូននៅព្រៃនគរខ្មែរ ។

៨០០-៨៥០ : កម្ពុជា, ជ័យវរ្ម័នទី ២ រៀបពិធីទេវរាជានៅលើភ្នំគូលែន ។

៨៣២ " : ក្រុងចំប៉ាសេ ត្រូវពួកសៀមវាយលុក ។

៨២៥ : ភូមា, កំណើតក្រុងបេគូ ។

៨៧៧ : កម្ពុជា, កសាងបារាយណ៍នៅហ-
រិហរាល័យ ។

៨២០-៨៥៣ : ចាប់លើកទ័ពមកវាយខ្មែរ ។

៨៨៩-៩០០ : កម្ពុជា, យសោវរ្ម័ន លើករាជធានី
មកទៅអង្គរ, កសាងបារាយណ៍
ខាងកើត ។

: ជ្វា, ដើមដំបូងនៃសន្តតិវង្ស ម៉ា-
តារ៉ាម ។

៩២១ : កម្ពុជា, ជ័យវរ្ម័នទី ៤ ជ្រៀករាជ្យ
ហើយបង្កើតរាជធានីនៅកោះកែ ។

: ចម្ប៉ា, សម័យចេងចេង ។

: ឥណ្ឌូនេស៊ី, ការទិពន្ធរៀនកបាយ

ណាថ្វា ។

៩៣៩ : វៀតណាម, ការរំដោះប្រទេសផុតពី-
ការត្រួតត្រារបស់ចិន ។

៩៤៤-៩៦៨ : កម្ពុជា, រាជេន្ទ្រវរ្ម័នគ្រងរាជ្យបកអង្គរ
វិញ ។

៩៤៣-៩៤៦ : កងទ័ពខ្មែរ វាយប្រទេសចំប៉ាហើយ
ដណ្តើមយកបដិមាមាសនៅពោនគរ ។

៩៦០-១២៧៩ : ចិន, សន្តតិវង្សសុង ។

៩៦៧ : កម្ពុជា, កសាងប្រាសាទបន្ទាយស្រី ។

៩៧១ : ចំប៉ា, ជ័យឥន្ទ្រវរ្ម័នទី ១ កសាងពោ
នគរនៅញ៉ាត្រាងឡើងវិញ ។

១០០០ : វៀតណាម, កំណើតសន្តតិវង្សវៀត
ខាងដើម ។ ការប្រយុទ្ធគ្នារវាងចំប៉ា
ចិនវៀតណាម ។ ពួកថ្វាវាយលុក

នគរស្រីវិជ័យ ។

: ចម្ប៉ា, ក្រុងវិជ័យធ្លាក់ផងឆាំប.

១០០៣–១០១១ : កម្ពុជា, សង្គ្រាមដណ្ដើមរាជសម្បត្តិ
នៅអង្គរ, សូរ្យវរ្ម័នទី១ឡើងសោយ
រាជ្យនៅក្រុងអង្គរ ។

១០២៥ : ឥណ្ឌូនេស៊ី, ពួកចូឡាត្រួតត្រាតំបន់
ស៊ូម៉ាត្រា ។

១០៣៥ : ឥណ្ឌូនេស៊ី, វង្សកាលស្ដេចអៃលង្គា
នៅកោះជ្វា ។

១០៤៤ ១០៧៧ : ភូមា, សម័យស្ដេចអនោរធ: ។

១០៥១–១០៦៥ : កម្ពុជា, ពួកបះបោរក្នុងសម័យឧទយា
: ទិត្យវរ្ម័នទី ២ បង្ក្រាបដោយមេទ័ព
: សង្គ្រាម ។
: ភូមា, ពុទ្ធសាសនថេរវាទ ។

១០៧៤-១០៨១ : ចម្ប៉ា, សម័យហរីវរ្ម័នទី ៤ ។

១០៨០-១១០៧ : កម្ពុជា, សម័យជ័យវរ្ម័នទី ៦ ។

១០៨៤-១១១៦ : ភូមា, សម័យក្យាន់ស៊ីថា, កសាងវិហារអានន្ទនៅបគន ។

១០៨១-១១១៣ : ចម្ប៉ា, សម័យជ័យឥន្ទ្រវរ្ម័នទី ២ ។

១១១៣-១១៥០ : កម្ពុជា, រជ្ជកាលសូរ្យវរ្ម័នទី ២, សង្គ្រាមក្នុងស្រុក ។

១១២៨ : ខ្មែរលើកទ័ពទី ១ ទៅវាយយួនដាយវៀត ។

១១៣៨ : ខ្មែរលើកទ័ពទី ២ ទៅវាយយួនដាយវៀត ។

១១៤៥ : ខ្មែរលុកលុយចម្ប៉ា ដណ្ដើមយកក្រុងវិជ័យ, បរាជ័យក្នុងសង្គ្រាមជាមួយដាយវៀត ។

១១៤៩ : ចម្ប៉ា, ស្តេចជ័យហរិវរ្ម័នរំដោះប្រទេស ពីអំណាចខ្មែរ ។

១១៥០ : ថៃ, រជ្ជកាលស្តេចអទិត្យរាជ ។

១១៦៥ : កម្ពុជា, ស្តេចយសោវរ្ម័នទី ២ ត្រូវមន្ត្រីនាមត្រីភូវនាទិត្យដណ្តើមរាជ្យ ។

: ភូមា, ការកសាងធម្មាយគ្គនៅបគន ។

១១៧៧ : កងទ័ពចាម់ចូលលុកក្រុងអង្គរ ។

១១៨០ : ចំបាំងនៃសិង្ហលចំពោះប្រទេស ភូមា ។

១១៧៣-១២១០ : ភូមា, សម័យនរបតីសិទ្ធ ។

១១៨១-១២១៨ : កម្ពុជា, រជ្ជកាលស្តេចជ័យវរ្ម័នទី ៧ ។

: សង្គ្រាមជាមួយប្រទេសចម្ប៉ា និង

: ប្រទេសយួនដាយវៀត ។

១២០៣ : ប្រទេសចម្ប៉ាក្លាយជាខេត្តខ្មែរ ។

៥២០ : ការដកទ័ពខ្មែរចេញពីប្រទេសចម្ប៉ា

៦២០-១២៨០ : ភូមា, កសាងព្រះវិហារមហាពុទ្ធ
នៅបគន ។ ការវិវត្ត នៃចម្ប៉ា និង
ពវស្ស យួនឈ្មោះត្រាន ។ ឥណ្ឌូ-
នេស៊ី , កំណើតរាជាណាចក្រ
សិង្ហសារី ក្រោយពីការធ្លាក់ចុះអំ-
ណាចនៃអាណាចក្រគឌីរី ។
ថៃ , ឯកភាពនៃពួកសៀមនៅតំបន់
ទន្លេមេណាម ។

១២៦០-១៣៦៣ : ចិន, ក្រោមការត្រួតត្រានៃពួកម៉ុង-
គោល ។

១២៨៧-១២៦០ : ការលុកលុយនៃពួកម៉ុងគោល មក
លើអាស៊ីអាគ្នេយ៍ ។ ដំណើរមក
ដល់នៃពួកអ៊ីស្លាម មកលើប្រទេស

ឥណ្ឌូនេស៊ី ។

១២៨៣-១២៨៤ : បរាជ័យ នៃការលុកលុយពួកម៉ុងហ្គោល មកលើប្រទេសចម្ប៉ា និងប្រទេសកម្ពុជា ។

១២៧៦-១៣១០ ថៃ,រាមាកំហែង ស្តេចវង្សសុខោទ័យ

១២៨៣ : ថៃ, ការបង្កើតអក្សរ សៀម ។

១២៨៧ : ភូមា, ពួកម៉ុងហ្គោលវាយយកក្រុងបគន ។

១២៩៣ : ឥណ្ឌូនេស៊ី, កំណើត អាណាចក្រម៉ូស្ហប៉ាហ៊ីត នៅកោះជ្វា ។

១២៩៤ : ថៃ, កំណើតក្រុងឈៀងម៉ៃ ។

១២៩៦ : កម្ពុជា, ការស្នាក់អាស្រ័យនៅក្រុងអង្គរនៃអ្នកការទូតចិន ឈ្មោះជូតាក្វាន់ ។ ឥណ្ឌូនេស៊ី, ទីបំផុតនៃរា

ណាចក្រស្រីវីជ័យ ។

១៣៣០-១៣៦៤ : ឥណ្ឌូនេស៊ី, សម័យស្តេចគស្សមទ្ធៈ

១៣៦៣-១៦៤៤ : ចិន, រាជវង្ស មីង ។

១៣៥០ : កម្ពុជា, និញានបាង ស្តេចខ្មែរទី ៤ ក្តុងកំរង៍ ពង្សាវតា ។

១៣៥០-១៣៦៩ : ថៃ, ការបង្កើតអាណាចក្រអយុធ្យាដោយស្តេចរាមាធិបតី ។

១៣៥៣ : ពួកសៀមវាយលុកក្រុងអង្គរ ។

: កំណើតអាណាចក្រ លាវឡានឆាង

១៣៦៤ : ភូមា, អាណាចក្រជាតិសាននៅ អាវ៉ា ។

១៣៨៣-១៣៩៥ : ថៃ, សម័យរាមេសួន ។

១៣៩៤ : សៀមលុកលុយក្រុងអង្គរ ។

១៤០២ : កំណើតក្រុងម៉ាឡាកា ។

| | | |
|---|---|---|
| ១៤១៦ | : | សៀមវាយលុកក្រុងអង្គរ ។ |
| ១៤១៧-១៤៦០ | : | កម្ពុជា, សម័យស្ដេចពញាយ៉ាត ។ |
| ១៤៣០ | : | សៀមកាន់កាប់ក្រុងអង្គរ ។ |
| ១៤៣១-៣៤ | : | កម្ពុជា, ការចាកចោលក្រុងអង្គរ ទៅតាំងនៅ "ចតុមុខ" ភ្នំពេញ ។ |
| ១៤៣៨ | : | ថៃ; ទីបំផុតនៃអាណាចក្រសុខោទ័យ ។ |
| ១៤៤៤ | : | ម៉ាឡាយូ, អ៊ីស្លាមមកដល់ក្រុងម៉ាឡាកា ។ |
| ១៤៤៨-១៤៨៨ | : | ថៃ, សម័យត្រៃលោកណាត ។ |
| ១៤៧១ | : | ចម្ប៉ា, ទីបំផុតនៃនគរចម្ប៉ា ។ |
| ១៤៧៩ | : | កម្ពុជា, ការទាក់ទងជាមួយយួន ដាយវៀត ។ |
| ១៤៦០-១៤៩៧ | : | យៀកណាម, សម័យឡេថាញ់តុង ។ |

១៥១១ : ម៉ាឡាយូ, ពួកព័រទុយហ្គេ ដណ្តើមយកក្រុងម៉ាឡាកា ។

១៥២១ ហ្វីលីពីន : ម៉ាសេឡង់ធ្វើដំណើរមកដល់កោះហ្វីលីពីន ។

១៥២៥ ១៥៦៦ : កម្ពុជា, សម័យស្ដេចអង្គចន្ទទី ១ ។

១៥៣០ ១៧០៧ : អណ្ណាម, ក្រោមការត្រួតត្រានៃពួកម៉ុងគោល ។

១៥៦៩ : ពួកភូមាវាយយកក្រុងអយុធ្យា ។

១៥៦៧ : លាវ, សម័យសិត្ថាធិរាជ ។

១៥៥១-១៥៨១ : ភូមា, សម័យស្ដេចបាយិនណូង ។

១៥៩០-១៦០៥ : ថៃ សម័យនរេសូរ ។

១៥៩៣-៩៤ : សៀម លុកបុកវាយលង្វែក ។

១៦១១ : ហ្វីលីពីន ពួកអេស្ប៉ាញ៉ុល បង្កើតមហាវិទ្យាល័យ ។

១៦១៥ : ពួកភូមាលើកទ័ពវាយប្រទេសសៀម ។

១៦១៩ : ឥណ្ឌូនេស៊ី, កំណើតក្រុងបាតាវីយ៉ា ។

១៦៤១ : ពួកហូឡង់ ចាត់ចងនឹងក្រុងមាឡាកា,

ប្រទេសបារាំងចូលប្រទេសសៀម ។

១៦១៨-១៦២៨ : កម្ពុជា, សម័យស្តេចជ័យជេដ្ឋាទី ២ ។

១៦៤៤-១៩១១ : ចិន, សម័យរាជវង្សម៉ាន់ជូ ។

១៦៥៨ : ភូមា, ការលុកលុយនៃពួកចិន ។

១៦៧៤-១៧០៤ : កម្ពុជា, សម័យជ័យជេដ្ឋាទី ៤ ។

១៧៦០-១៧៨៩ : វៀតណាម, សម័យបែបហៀនតុង

លឹម ។

១៧៥៧-១៩៤៧ : ឥណ្ឌា, ក្រោមការត្រួតត្រារបស់អង់

គ្លេស ។

១៧៦០ : ភូមា, សម័យអាឡោងផាយ៉ា ។

១៧៥៨-១៧៧៥ : កម្ពុជា, សម័យឧទ័យទី ២ ។

១៧៣៨-១៧៥៧ : ថៃ, សម័យបរមកោដ ។

១៧៦៦-៦៧ : ពួកភូមាវាយយកក្រុងអយុធ្យា ។

១៧៦៧-១៧៨៣ : ថៃ, សម័យស្ដេចតាកស៊ីន, សៀម
លុកលុយប្រទេសលាវ ។

១៧៧៩-១៧៩៦ : កម្ពុជា, សម័យអន្តរគមន៍ ។

១៧៨៣-១៨២០ : វៀតណាម, ការបះបោរនៃពួក
តៃស៊ឺន ។

១៧៩៥ : អាណានិគមអង់គ្លេស ដណ្ដើម
យកម៉ាឡាកា ។

១៧៨២-១៨០៩ : ថៃ សម័យចក្រីមាទី ១ ។

១៨០៩-១៨២៤ : ថៃ, សម័យចក្រីមាទី ២ ។

១៨០៦-១៨៣៤ : កម្ពុជា, សម័យអង្គចន្ទទី ២ ។

១៨០២-១៨១៩ : វៀតណាម, សម័យយ៉ាឡុង ។

ဝ
ဝ ဝ

# ឯកសារពិគ្រោះសង្ខេប


Grousset (R) : Histoire de l'Asie, Paris, P-UF, 1956

Coedès (G) : les Etats hindouisés d'indochine et d'Indonésie, Paris 1948

Coedès (G) : les Peuples de la péninsule indochinoise, histoire et civilisations, paris, Dunod 1962

Lê thành khôi : histoire de l'Asie du Sud-Est, PUF 1967

Giteau (M) : histoire du cambodge, paris, D  ier. 1957

Dauphin-Meunier (A) : histoire du cambodge  P-U-F, 1961

Bruhat (J) : histoire de l'Indonésie P-U-F  958

Fistié (P) : Singapour et la Malaisie P-U.F 1960

Willoquet (G) : histoire de philippines P-UF 1961

Fistié (P) : la thailande, paris, P-U-F 1963

Masson (A) : histoire du vietnam, paris, P-U  967

Chesneaux (J) : contribution à l'histoire de la  ion vietnamienne. paris 1955

# មាតិការឿង

សេចក្តីផ្តើម

ជំពូកទី ១ – កំណើតនគរធំៗ នៅក្នុងអាស៊ីអាគ្នេយ៍ (សតវត្សទី១-ទី៨)

១ អាស៊ីអាគ្នេយ៍ជាផ្លូវឆ្លងនៃនាវាចិន, ឥណ្ឌា និងរ៉ូម៉ាំង, ១២ ។

២– នគរភ្នំ ចម្ប៉ា មន ម៉ាឡាយូ, ១៨ ។

៣– អាណាចក្រផ្សារស្រីវិជ័យ, ២៤ ។

៤– នគរចេនឡានិងចម្ប៉ា, ២៧ ។

៥– វឌ្ឍនសង្គម, ៣១ ។

ជំពូកទី ២ – សង្គ្រាមពង្រីកអំណាច នៃជនជាតិខ្មែរ-ចាម-យួន ភូមា (សតវត្សទី ៩-ទី ១២)

៦– ខ្មែររំដោះខ្លួនពីជ្វា ហើយកសាងឯកភាពឡើងវិញ, ៣៧ ។

៧– ការរីកតាមព្រំដែន រវាងខ្មែរនិងចាម, ៣៩ ។

៨– ជាតិយួនរំដោះខ្លួនពីចិនហើយវាយដណ្តើមទឹកដីចាម, ៤១ ។

៩- ចំបាំងរវាងខ្មែរ-ចាម-យួន, ៤៦ ។

១០– ការបះបោរនៃពួកមុខនិងសៀម; ៥៥ ។

១១– កុមារលេបយកដើមន, ៥៨ ។

១២- សំខុះនៃកោះថា, ៦៣ ។

## ជំពូកទី ៣ - វិបត្តិនៅអាស៊ីភាគ អគ្នេយ៍នាសតវត្សទី ១៣

១៣– ការធ្លាក់ចុះនៃអរិយធម៌ឥណ្ឌា, ៦៩ ។

១៤– ការលុកលុយនៃពួកម៉ុងគោល ទៅលើគំបុងយុនណាន (សៀម) ៧១ ។

១៥ – ពួកម៉ុងគោលទន្ទ្រានដែនដីអាស៊ីភាគអគ្នេយ៍, ៧៣ ។

១៦ - ដំណើរមកដល់នៃសាសនាអ៊ីស្លាម, ៨០ ។

ជំពូកទី ៤ – សង្គ្រាមរវាងទឹកដី នៃពួកអឺរ៉ុប សៀម-យួន-ភូមា ( សតវត្សទី ១៤ ដល់ទី ១៨ )

១៧- ជាតិយួនដណ្ដើមយកប្រទេសចម្ប៉ា, ៨៣ ។

១៨- ជាតិសៀមវាតអំណាច នៅលើឥណ្ឌូចិនភាគកណ្ដាល, ៨៩ ។

១៩- ការវាតដណ្ដើមទឹកដីនៃពួកព័រទុយហ្គេ អេស្ប៉ាញ៉ុល និងពួកហូឡង់, ៩៤ ។

២០- សង្គ្រាមរវាងប្រទេសភូមា សៀមនិងលាវ, ៩៨

២១- សង្គ្រាមរវាងប្រទេសកម្ពុជា សៀមនិងយួន, ១០៧ ។

សេចក្ដីបញ្ចប់ . . . . . . . . ១២៨

ភាគកំណត់សព្ទាវលី . . . . . . ១៣៣

ឯកសារពិគ្រោះសង្ខេប . . . . . ១៥០

ផែនទីអាស៊ីភាគអាគ្នេយ៍ . . . . . . . ១៥១

# សេចក្ដីជូនដំណឹង

សៀវភៅ «ប្រវត្តិសាស្ត្រនៃប្រទេសខ្មែរ» កំពុងពិនិត្យកែតម្រូវជាថ្មី ឲ្យបានច្បាស់លាស់ ស្របតាមកម្មវិធីសិក្សា ។ សៀវភៅនេះបំរុងរៀបចំបោះពុម្ពជាលើកទី ២ ដោយបែងចែកជា ៤ ផ្នែក ។

ដូច្នេះ សូមរង់ចាំអានផ្នែកនិមួយៗ តាមត្រូវការ ដែលនឹងចេញផ្សាយជាបន្តបន្ទាប់គ្នា ក្នុងពេលខាងមុខនេះ ។

អ្នកនិពន្ធ

---

បោះពុម្ពលើកទី ១ ចំនួន ២៥០០ ច្បាប់

នៅរោងពុម្ព ពន្លឺពេជ្រ លេខ ៣៩៩ វិថីកម្ពុជាក្រោមភ្នំពេញ

តម្កល់ទុកតាមលេខ ៨១៨ ចុះថ្ងៃទី ២៥-៨-១៩៧២